ISSN 1560-7615

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី៨ លេខ ៤ | តុលា - ធ្នូ ឆ្នាំ២០០៤ | តម្លៃ ១.៥០០៛

# ជម្រើសសំរាប់ការអភិវឌ្ឍន៍ពីដំបូងនៃឃុំ/សង្កាត់ ចំណូលពីប្រភពផ្ទាល់នៅកម្ពុជា

កម្មវិធីស្រាវជ្រាវផ្តោតលើគោលនយោបាយខាងវិមជ្ឈការ (PORDEC) នៅ វបសអ បានធ្វើការសិក្សាមួយស្តីពីចំណូលពីប្រភពផ្ទាល់របស់ឃុំ/សង្កាត់ លោកស្រី អេង នេត្រា ជាអ្នកស្រាវជ្រាវផ្នែកអភិបាលកិច្ច និងវិមជ្ឈការ បានបូកសរុប ពីលទ្ធផលដែលបានរកឃើញ ។*

## ហេតុអ្វីបានជាសិក្សាពីចំណូលពីប្រភពផ្ទាល់?

ក្រុមប្រឹក្សាឃុំ/សង្កាត់ (ហៅកាត់ថា ឃុំ) នៅកម្ពុជា ក៏ដូចជាអាជ្ញាធរមូលដ្ឋានក្នុងប្រទេសឯទៀតដែរ ត្រូវអភិវឌ្ឍចំណូលប្រភព មូលដ្ឋាន ទើបអាចដំណើរការបានយ៉ាង សក្តិសិទ្ធ ។ ការផ្ទេរថវិកាក្នុងរដ្ឋាភិបាល ដូចជា ថវិកាផ្តល់តាមរយៈមូលនិធិឃុំ/សង្កាត់ជាដើម គឺជាប្រភពចំណូលដ៏ចាំបាច់នៅក្នុងប្រទេសភាគច្រើន ។ ចំណូលប្រមូលយកបាននៅនឹងមូលដ្ឋាន ក៏សំខាន់ផងដែរសំរាប់បំពេញបន្ថែមលើថវិកាផ្ទេរពីកំរិតជាតិ ហើយវាជាមធ្យោបាយសំរាប់ឱ្យប្រជាពលរដ្ឋចូលរួមចំណែកចេញថ្លៃសេវាសាធារណៈដែលខ្លួនបានទទួលនៅក្នុងមូលដ្ឋាន ។




*សមាជិកក្រុមប្រឹក្សាឃុំ កំពុងចុះបញ្ជីអត្រានុកូលដ្ឋាន នៅឃុំព្រែកត្នោត ខេត្តកំពត ។*

គោលដៅចំបងនៃការសិក្សានេះគឺ ជួយដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ក្រសួងហិរញ្ញវត្ថុ) ក្នុងការអនុវត្តន៏សាកល្បងចំណូល ពីប្រភពផ្ទាល់មួយចំនួនរបស់ឃុំ ដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ និងដែលសម្តេចនាយករដ្ឋមន្ត្រីបានគាំទ្រ ។ម្យ៉ាងទៀតគេរកឃើញថា ការអភិវឌ្ឍន៏ចំណូលពីប្រភពផ្ទាល់របស់ឃុំ គឺជាសមាសភាគមួយដ៏សំខាន់នៃកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលរដ្ឋាភិបាលទើបបានអនុម័តថ្មីៗ ។

ផ្អែកលើទិន្នន័យប្រមូលបានពី ៧ឃុំ ក្នុង ៤ខេត្ត (ត្រាំកក់ និងជំរះពេន នៅតាកែវ, សំរោង និងគោកចក នៅសៀមរាប, ព្រៃនប់ នៅក្រុងព្រះសីហនុ, បឹងព្រលិត និងអូឡាំពិច នៅភ្នំពេញ) ការសិក្សា ១)បានរកឃើញជំរើសល្អៗដែលអាចធ្វើកើតសំរាប់ចែករំលែក និងបែងចែកឡើងវិញនូវចំណូលពីខេត្ត-ក្រុង (ហៅកាត់ថា ខេត្ត) ទៅឃុំ និង ២) បានពិនិត្យពិចារណាពីប្រភពថ្មីៗនៃចំណូលរបស់ឃុំ ។ ការងារចុះដល់កន្លែងរួមមានបទសំភាសន៏រៀបរយ និងពាក់កណ្តាលរៀបរយ ជាមួយអ្នកពាក់ព័ន្ធនៅតាមកំរិតផ្សេងៗក្នុងជួររដ្ឋាភិបាល ហើយនិងការពិភាក្សាក្រៅផ្លូវការជាមួយម្ចាស់អាជីវកម្ម និងប្រជាជននៅមូលដ្ឋាន ។

អត្ថបទនេះផ្អែកលើរបាយការណ៏មួយដែល វបសអ បានរៀបចំឡើង ដោយធ្វើសហប្រតិបត្តិការជាមួយក្រសួងហិរញ្ញវត្ថុ និងគណៈកម្មាធិការជាតិ

* អត្ថបទនេះដកស្រង់ចេញពីរបាយការណ៏ពេញលេញមួយដែល វបសអ នឹងបោះពុម្ពផ្សាយជាឯកសារពិភាក្សានាពេលឆាប់ៗ ។

## មាតិកា

ជំរើសសំរាប់ការអភិវឌ្ឍន៍ពីដំបូងនៃឃុំ/សង្កាត់ចំនូលពីប្រភពផ្ទាល់នៅកម្ពុជា...១
ឥណទានស្ថាប័ននៅជនបទកម្ពុជា ....................................................៤
ការព្យាយាមស្វែងយល់ពីកិច្ចការពារខាងសង្គមកិច្ចនៅកម្ពុជា ..................... ៩
តាមដានសេដ្ឋកិច្ច— ស្ថានភាពក្រៅប្រទេស ........................................ ១៣
— ស្ថានភាពក្នុងប្រទេស ........................................ ១៦
— សន្ទស្សន៍សេដ្ឋកិច្ច ........................................ ១៨
ព័ត៌មានថ្មីៗពី វបសអ .................................................. ២០

គាំទ្រឃុំ/សង្កាត់ (NCSC) ។ អត្ថបទនេះក៏មានផ្តល់យោបល់ និងអនុសាសន៍នានាដែលទទួលបាននៅក្នុងសិក្ខាសាលាជាតិ ស្តីពីប្រភពចំណូលផ្ទាល់របស់ឃុំនៅខែកក្កដា ២០០៤ ដែលក្នុងនោះ អ្នកពាក់ព័ន្ធ និងស្ថាប័នទាំងអស់ បានពិភាក្សាពី ១) ប្រភពថ្មីៗជាសក្តានុពលនៃចំណូលសំរាប់ឃុំ និង ២) ជំរើសនិងឧបករណ៍ជាក់លាក់មួយចំនួនដែលត្រូវអនុវត្តសាកល្បង ។ ផ្អែកទៅលើពតិមាននេះ គេសង្ឃឹមថា ក្រសួងហិរញ្ញវត្ថុ អាចចាប់អនុវត្តសាកល្បងនូវគំនិតផ្តួចផ្តើមនានា និងអាចកសាងនូវគោលនយោបាយទូទៅ និងបទប្បញ្ញត្តិផ្សេងៗទៀតបាន ។

## ប្រភពចំណូលបច្ចុប្បន្ន

គេមិនអាចពិភាក្សានូវចំណូលពីប្រភពផ្ទាល់របស់ឃុំបានទេ បើសិនពុំមានការយល់ដឹងពីរចនាសម្ព័ន្ធចំណូលជាទូទៅរបស់រដ្ឋាភិបាល ។ ប្រភពចំណូលបច្ចុប្បន្នរបស់ខេត្ត (បញ្ចូលក្នុងខ្ទង់សាលាខេត្ត) មានជាប់ទាក់ទិនខ្លាំងបំផុតនិងប្រហែលមានលទ្ធភាពច្រើនជាងគេសំរាប់ចែករំលែកទៅឱ្យឃុំ ។ ប្រភពចំបងៗនៃចំណូលពន្ធដែលបច្ចុប្បន្នបែងចែកទៅឱ្យខេត្ត គឺមាន: ១) ពន្ធលើដីមិនបានប្រើប្រាស់ ២) ពន្ធលើការផ្ទេរកម្មសិទ្ធិ (ពន្ធប្រថាប់ត្រា) ៣) ពន្ធលើមធ្យោបាយដឹកជញ្ជូន ៤) ពន្ធប៉ាតង់[១] ៥) ពន្ធលើសត្តឃាតដ្ឋាន ៦) ពន្ធលើការបំភ្លឺសាធារណៈ ។ ខេត្តមានប្រមូលចំណូលមិនមែនពន្ធផ្សេងៗ ដូចជាភាស៊ី[២] និងកំរៃលើអ្នកប្រើប្រាស់ ។ ជាទូទៅចំពោះ ៤ ខេត្តដែលបានលើកមកសិក្សា ចំណូលភាគច្រើនបំផុត បានពីពន្ធលើការផ្ទេរកម្មសិទ្ធិ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងពន្ធប៉ាតង់ ។ ការប្រមូលពន្ធប៉ាតង់ និងពន្ធលើការផ្ទេរកម្មសិទ្ធិ តាមធម្មតាអាចសំរេចបានគ្រប់ផែនការ[៣] រីឯពន្ធលើមធ្យោបាយដឹកជញ្ជូនបានតិចជាងផែនការមួយកំរិត ។

## ជំរើសនៃប្រភពចំណូល

ផ្អែកលើការចុះសិក្សាដល់ឃុំគំរូតាង និងទិន្នន័យដែលយកបានពីការប្រមូលពន្ធខេត្ត បានរកឃើញជំរើសមួយចំនួនសំរាប់សាកល្បងអនុវត្តចំណូលពីប្រភពផ្ទាល់របស់ឃុំ ជាអាទិ៍ ១) ការចែករំលែកចំណូលពីពន្ធលើមធ្យោបាយដឹកជញ្ជូន និងពន្ធប៉ាតង់, ២) ការបែងចែកឡើងវិញមួយភាគ ឬការចែករំលែកប្រភពចំណូលមិនមែនពន្ធមួយ (ភាស៊ី) ពីខេត្តទៅឱ្យឃុំ ៣) ការអនុម័តនូវការយកកំរៃជាក់លាក់មួយចំនួនលើអ្នកប្រើប្រាស់សេវាកម្ម និង ៤) ការបង្កើតពន្ធសំរាប់សេវាទូទៅរបស់ឃុំ ដោយផ្អែកទៅលើលក្ខណៈបែបសាមញ្ញៗនៃដីធ្លី និងទ្រព្យសម្បត្តិ សំរាប់ជួយចេញតំលៃសេវាផ្សេងៗដែលមិនអាចទារយកកំរៃដោយផ្ទាល់បាន ។ ជំរើសទាំងនេះ មានទាំងហេតុផលជាមូលដ្ឋានក្នុងការជ្រើសរើសយកវា របៀបរៀបចំផ្សេងៗ និងតួនាទីដែលឃុំអាចជួយបំពេញ ត្រូវបានពិភាក្សានៅខាងក្រោម ។ ក្នុងករណីមួយចំនួនជំរើសទាំងនេះ នឹងមានផលប៉ះពាល់គួរកត់សំគាល់លើចំណូលខេត្ត ដូច្នេះត្រូវគិតគូររកអ្វីមកជំនួសការបាត់បង់ចំណូលរបស់ខេត្ត នៅក្នុងកំណែទំរង់វិស័យហិរញ្ញវត្ថុសាធារណៈជាទូទៅ ។

### *ពន្ធលើមធ្យោបាយដឹកជញ្ជូន*

*ហេតុផលនៃការជ្រើសយក:* ជាទូទៅ ឃុំបានជួយប្រមូលពន្ធនេះរួចហើយ ទោះបីតាមរបៀបមិនផ្លូវការក្តី ។ ការប្រមូលពន្ធនេះសាមញ្ញគួរសមហើយមូលដ្ឋានយកពន្ធក៏មានសក្តានុពលបន្តរីកលូតលាស់ ។ ឃុំអាចទទួលខុសត្រូវមួយចំនួនលើការថែទាំផ្លូវថ្នល់ក្នុងមូលដ្ឋានដោយប្រើចំនូលពន្ធនេះ ។

*របៀបរៀបចំចែករំលែកពន្ធ:* ថ្វីបើក្នុងខេត្តខ្លះ ឃុំបានជួយប្រមូលក្រៅផ្លូវការនូវពន្ធលើមធ្យោបាយដឹកជញ្ជូនក្តី ប៉ុន្តែ ដើម្បីក្លាយជាប្រភពចំណូលពិតៗរបស់ឃុំ គឺត្រូវមានវិធានច្បាប់កំណត់ជាមូលដ្ឋានមិនមែនផ្អែកលើការចរចាក្រៅផ្លូវការនោះទេ ។ NCSC ដោយពិគ្រោះយោបល់ជាមួយក្រសួងជាប់ទាក់ទិន ត្រូវធ្វើសេចក្តីសំរេចពីភាគរយថេរនៃពន្ធប្រមូលបានដែលត្រូវចែករំលែកឱ្យឃុំ ។ ចំណែកអាចចែងយ៉ាងសាមញ្ញដោយកំណត់នូវចំនួនភាគរយដែលអាចផ្តល់ចំណូលទំហំណាមួយទៅឱ្យឃុំ ឬក៏អាចចងភ្ជាប់វាដោយជាក់លាក់ទៅនឹងបន្ទុកចំណាយប៉ាន់ស្មាននៃការថែទាំផ្លូវ ។ ក្នុងករណីចងភ្ជាប់ដូច្នេះ គឺអាចជូនពតិមានដល់អ្នកជាប់ពាក់ពន្ធថា ចំណែកពន្ធមួយភាគរបស់ឃុំ នឹងត្រូវយកទៅប្រើក្នុងគោលដៅនេះ ។

*តួនាទីឯទៀតដែលឃុំអាចទទួលអនុវត្ត:* ការអនុវត្តន៍សាកល្បងនូវការចែករំលែកពន្ធ នឹងមានការរួមសហការរវាងការិយាល័យពន្ធដារស្រុក និងក្រុមប្រឹក្សាឃុំ ។ អាចមានការតំរូវឱ្យឃុំ បំពេញមុខងារមួយចំនួនដូចតទៅ:

- រៀបចំ និងកាន់កាប់បញ្ជីកត់ត្រាទាន់ពេលល្អនៃការចុះបញ្ជីយានយន្តនិងធ្វើការចុះបញ្ជីយានយន្ត
- ជូនពតិមានពីរឿងពន្ធដល់អ្នកភូមិ តាមរយៈការប្រជុំក្នុងភូមិ និងការបិទប្រកាសជាសាធារណៈនូវបទប្បញ្ញត្តិ និងសេចក្តីណែនាំ មានជាប់ទាក់ទិននានា
- ប្រមូលពន្ធដោយផ្អែកលើបញ្ជីនៃការចុះបញ្ជី
- រៀបចំរបាយការណ៍ប្រមូលចំណូល និងមានទុកដាក់វាសំរាប់ឱ្យសាធារណជនសើរើពិនិត្យ និងសំរាប់ការធ្វើសវនកម្ម
- ផ្ញើចំណូលនៅរតនាគារខេត្ត ឬនៅក្នុងគណនីឃុំនៅធនាគារ
- ពង្រឹងការប្រមូលពន្ធ ។

### *ពន្ធប៉ាតង់*

*ហេតុផលនៃការជ្រើសយក:* បច្ចុប្បន្នអាជីវកម្មគ្រប់ប្រភេទ និងគ្រប់ខ្នាតត្រូវបង់ប៉ាតង់ ហើយឃុំងាយស្រួលនឹងសំគាល់ឃើញនូវអាជីវកម្មនានាក្នុងឃុំ ។ មូលដ្ឋានយកពន្ធមានស្ថិរភាពល្អ និងច្រើនតែរីកធំពីមួយឆ្នាំទៅមួយឆ្នាំ ។ ការយកចំនូលនេះទៅបំរើសេវាក្នុងមូលដ្ឋានដែលអាចមើលឃើញអាចជួយកែលំអ ការប្រតិបត្តិច្បាប់ដែលសព្វថ្ងៃនៅអន់ខ្សោយនៅក្នុងឃុំផ្សេងៗជាច្រើន ។

*របៀបរៀបចំចែករំលែកពន្ធ:* ក្នុងតំបន់នានាដែលបានចុះអង្កេត ពន្ធប៉ាតង់ ត្រូវបានចែករំលែកក្រៅផ្លូវការរួចហើយ ក្នុងករណីដែលឃុំបានជួយប្រមូល វាឱ្យការិយាល័យពន្ធដារស្រុក ។ ការចែករំលែកអាចកំណត់ជាផ្លូវការនៅក្នុងថវិការបស់ឃុំដោយមានវិធានច្បាប់ច្បាស់លាស់ ។ ជំរើសមួយ គឺអាចបែងចែកមូលដ្ឋានយកពន្ធនៃអាជីវកម្មក្រោមរបប "ម៉ៅការ"[៤] (គឺអាជីវកម្មតូចៗ) ទាំងអស់ ពីខេត្តទៅឱ្យឃុំដោយទុករបប "ពិត" (គឺអាជីវកម្មធំៗ) ឱ្យខេត្ត ។ ជំរើសមួយទៀតគឺអាចចែករំលែកចំណូលរបប "ម៉ៅការ" និងរបប "ពិត" មួយភាគទៅឱ្យឃុំ ។

*តួនាទីឯទៀតដែលឃុំអាចទទួលអនុវត្ត:* ការអនុវត្តសាកល្បងនូវការចែករំលែកពន្ធ នឹងមានការរួមសហការរវាងការិយាល័យពន្ធដារស្រុក និងក្រុមប្រឹក្សាឃុំ ។ គេអាចតំរូវឱ្យឃុំ បំពេញមុខងារដូចតទៅ:

- រៀបចំ និងកាន់កាប់បញ្ជីប៉ាតង់ដែលបានកត់ត្រាទាន់ពេលល្អ ដោយធ្វើការជាមួយការិយាល័យពន្ធដារស្រុក ដើម្បីធ្វើចំណាត់ថ្នាក់អាជីវកម្មនានាទៅតាមប្រភេទប៉ាតង់

- ប្រមូលពន្ធប៉ាតង់ ដោយផ្អែកលើបញ្ជីធ្វើចំណាត់ថ្នាក់
- ប្រគល់ឱ្យអ្នកជាប់ពន្ធនូវ ប័ណ្ណប៉ាតង់ដែលចេញដោយការិយាល័យពន្ធដារខេត្ត
- រៀបចំរបាយការណ៍ប្រមូលចំណូល និងមានទុកដាក់វាសំរាប់ឱ្យសាធារណជនសើរើពិនិត្យ និងសំរាប់ការធ្វើសវនកម្ម
- ផ្ញើចំណូលនៅរតនាគារខេត្ត ឬនៅក្នុងគណនីឃុំនៅធនាគារ
- ពង្រឹងការប្រមូលពន្ធ ។

*ភាស៊ី និងការយកកំរៃលើអ្នកប្រើប្រាស់ សំរាប់សេវាឃុំ*

*ហេតុផលនៃការជ្រើសយក:* ខេត្តសព្វថ្ងៃបានម៉ៅការការគ្រប់គ្រងផ្សារក្នុងនេះមានទាំងការប្រមូលភាស៊ីផង ទៅឱ្យវិស័យឯកជន ។ ឃុំអាចទទួលគ្រប់គ្រង ឬក៏ធ្វើជាម្ចាស់កម្មសិទ្ធិនៃផ្សារតូចៗ ។ ភាស៊ី គឺជាចំណូលសាមញ្ញងាយប្រមូល ហើយអាចបានច្រើនគួរសមនៅតាមកន្លែងដែលផ្សារមានសកម្មភាពមមាញឹក ។ ភាស៊ីបង្កើតផងដែរនូវចំណងទាក់ទងរវាងចំណូល និងចំណាយ ដោយសារប្រាក់ប្រមូលបានមួយភាគ អាចយកទៅដោះស្រាយសេវាបំរើផ្សារក្នុងមូលដ្ឋាន ដូចជា បោសសំអាត ប្រមូលសំរាម និងរក្សាសណ្តាប់ធ្នាប់ជាដើម ។

*ការបែងចែកចំណូលឡើងវិញ:* ជំរើសមួយគឺអាចចែករំលែក ឬបែងចែកឡើងវិញទៅឱ្យឃុំនូវចំណូលភាស៊ី ដែលប្រមូលបានពីផ្សារតូចតាច ឬផ្សារគ្មានចុះបញ្ជី ដោយទុកឱ្យខេត្តនូវចំណូលពីផ្សារធំៗ ។ ជំរើសមួយទៀតគឺ ផ្ទេរទ្រព្យសម្បត្តិជាផ្សារតូចៗទៅឱ្យឃុំ និងអនុញ្ញាតឱ្យឃុំគ្រប់គ្រងផ្សារដោយខ្លួនឯង ឬក៏ដោយម៉ៅការការងារនេះទៅឱ្យអ្នកផ្សេង ។ វាអាចមានប្រយោជន៍ដែរ បើសិនជាពិចារណាចែករំលែកចំណូលប្រមូលបានពីផ្សារធំៗរបស់ខេត្ត ទៅឱ្យឃុំ ពីព្រោះឃុំអាចរកចំណូលបានតិចពេកពីផ្សាររបស់ខ្លួន ឬក៏គ្មានផ្សារក្នុងទឹកដីរបស់ខ្លួន ។

*តួនាទីឯទៀតដែលឃុំអាចទទួលអនុវត្ត:* ទោះបីត្រូវគ្រប់គ្រង ឬធ្វើជាម្ចាស់ផ្សារក្តី ឃុំនឹងត្រូវទទួលបន្ទុក:

- ផ្តល់សេវាផ្សេងៗដើម្បីធានាសុវត្ថិភាព សណ្តាប់ធ្នាប់ និងអនាម័យនៅទីផ្សារ
- ប្រមូលភាស៊ីប្រចាំថ្ងៃពីអ្នកលក់ដូរគ្រប់គ្នា ទៅតាមបែបបទដែលបានកំណត់ហើយ
- បែងចែកភាស៊ីឱ្យដាច់ពីចំណូលផ្សេងទៀតរបស់ឃុំ ដើម្បីធានាថាប្រាក់នេះត្រូវបានរក្សាការពារ ទុកសំរាប់ដោះស្រាយចំណាយដែលជាប់ទាក់ទងនឹងផ្សារ
- បង្កើតបរិស្ថានផ្សារមួយដែលអំណោយផលដល់ការកែលំអ និងរីកលូតលាស់អាជីវកម្ម
- កសាងកំណត់ត្រា និងទុកដាក់វាឱ្យបានត្រឹមត្រូវ ដើម្បីឱ្យសាធារណជនសើរើពិនិត្យ និងសំរាប់ការធ្វើសវនកម្ម
- ផ្ញើចំណូលនៅរតនាគារខេត្ត ឬនៅក្នុងគណនីឃុំនៅធនាគារ
- ពង្រឹងការប្រមូលពន្ធ ។

ក្រៅពីភាស៊ីដែលបែងចែកមកឱ្យនេះ ឃុំក៏អាចអនុវត្តយកកំរៃលើអ្នកប្រើប្រាស់ ចំពោះសេវាផ្សេងៗដែលអាចប្រមូលយកកំរៃដោយផ្ទាល់ ដូចជាការផ្គត់ផ្គង់ទឹកស្អាត និងទឹកស្រោចស្រពជាដើម ។ កំរៃលើអ្នកប្រើប្រាស់ចំពោះសេវាដ៏ជាក់លាក់ គឺគួរប្រមូលយកពីអ្នកប្រើសេវាទាំងនោះ ។ ឃុំត្រូវកំណត់ពីសេវានានាដែលអាចប្រមូលយកកំរៃដោយផ្ទាល់បាន ព្រមទាំងកំណត់ថ្លៃសេវាឱ្យសមស្របតាមតំរូវការចំណូលក្នុងស្រុក ដោយគោរពតាមគោលការណ៍ណែនាំពីថ្នាក់ជាតិ ។

*ការយកពន្ធសំរាប់សេវាទូទៅរបស់ឃុំ*

*ហេតុផល:* ពន្ធសំរាប់សេវាទូទៅរបស់ឃុំ អាចយកមកអនុវត្តដើម្បីជួយផ្តល់ហិរញ្ញប្បទានដល់សេវាផ្សេងៗ ដែលឃុំពិបាកនឹងប្រមូលយកកំរៃផ្ទាល់លើអ្នកប្រើប្រាស់ ។ ពន្ធនេះអាចបង្កើនចំណូលគួរកត់សំគាល់ និងអាចជាប្រភពចំណូលចំបងតែមួយសំរាប់ឃុំខ្លះ ។

*របៀបរៀបចំសំរាប់ការគ្រប់គ្រង និងការប្រមូល:* ពន្ធសំរាប់សេវាទូទៅរបស់ឃុំ អាចប្រមូលយកពីគ្រប់គ្រួសារ និងអាជីវកម្មនៅក្នុងឃុំ ក្នុងលក្ខណៈជាប្រាក់កំរៃថេរប្រចាំឆ្នាំដែលផ្សារភ្ជាប់នឹង ១) ប្រភេទដីប្រើប្រាស់ (កសិកម្ម ការស្នាក់នៅ ពាណិជ្ជកម្ម) ២) ចំណាត់ថ្នាក់តាមទំហំដីប្រើប្រាស់, និងអាចថែមនូវ ៣) លក្ខណៈសំគាល់មួយចំនួនតូចនៃការប្រើប្រាស់ដី (ដីអភិវឌ្ឍន៍ ឬមិនទាន់អភិវឌ្ឍន៍, ទំហំនិងគុណភាពរចនាសម្ព័ន្ធ...) ។ ពិតហើយ នៅមានការងារច្រើនត្រូវធ្វើដើម្បីកសាងប្រព័ន្ធធ្វើចំណាត់ថ្នាក់សមស្របមួយ និងបែងចែកបន្ទុកចំណាយឱ្យបានសមស្របទៅលើប្រភេទនីមួយៗ ។

*តួនាទីឯទៀតដែលឃុំអាចទទួលអនុវត្ត:* គឺអាចមាន:

- កត់ត្រា និងធ្វើបច្ចុប្បន្នភាពបញ្ជីដីឃុំយ៉ាងទៀងទាត់ ដោយមានការជួយឧបត្ថម្ភពីគំរោងគ្រប់គ្រង និងរដ្ឋបាលដីធ្លី និងបញ្ជីដីធ្លីបច្ចុប្បន្ន
- ធ្វើចំណាត់ថ្នាក់ដីឡូតិ៍សំរាប់ការប្រមូលពន្ធ ដោយផ្អែកលើបទប្បញ្ញត្តិរបស់ក្រសួងហិរញ្ញវត្ថុ និងបញ្ជីនៃការចុះបញ្ជីរបស់ឃុំ ។
- ធ្វើការកំណត់ និងប្រមូលប្រាក់បង់ផ្សេងៗឱ្យបានសមស្របពីអ្នកបង់នីមួយៗដែលមានកាតព្វកិច្ច
- រៀបចំកំណត់ត្រា និងធ្វើរបាយការណ៍ប្រមូលកំរៃ សំរាប់ឱ្យសាធារណជនសើរើពិនិត្យ និងសំរាប់ការធ្វើសវនកម្ម
- ផ្ញើចំណូលនៅរតនាគារខេត្ត ឬនៅក្នុងគណនីឃុំនៅធនាគារ
- ពង្រឹងការប្រមូលពន្ធ ។

## ជំហានបន្ទាប់

នៅក្នុងសិក្ខាសាលាជាតិកាលពីខែកក្កដា មានការគាំទ្រយ៉ាងទូលំទូលាយដល់ការអនុវត្តន៍សាកល្បងនូវការចែករំលែកជំរើសចំណូលខេត្តមួយចំនួន និងការពិចារណាពីបែបបទដែល ឃុំអាចដាក់អនុវត្តការយកកំរៃលើអ្នកប្រើប្រាស់ ។ ពន្ធលើសេវាអាចទទួលយកបាន ប៉ុន្តែយោងតាមភាពរសើបនៃពន្ធដីនៅកម្ពុជា ការពិភាក្សាបានបង្ហាញច្បាស់ថា ត្រូវមានការស្រាវជ្រាវថែមទៀត មុននឹងគិតគូរយកជំរើសនេះមកអនុវត្តសាកល្បង ។ មតិផ្សេងទៀតស្តីពីការចែករំលែកចំណូលទៅឱ្យឃុំ ដូចជាពន្ធលើដីមិនបានប្រើប្រាស់ជាដើម ក៏មានលើកឡើងដែរ ។

ក្រសួងហិរញ្ញវត្ថុ ចង់អនុវត្តសាកល្បងចំណូលពីប្រភពផ្ទាល់របស់ឃុំយ៉ាងឆាប់តាមអាចធ្វើបាន ប៉ុន្តែត្រូវពិភាក្សា និងធ្វើការងារជាច្រើនទៀតទាក់ទិននឹងគំនិតផ្សេងៗដែលបានលើកឡើងសំដៅចែករំលែក និង/ឬបែងចែកជំរើសចំណូលមួយចំនួនរបស់ខេត្តទៅឱ្យឃុំ ។ បញ្ហាចំបងៗត្រូវយកមកពិភាក្សា គឺជាប់ទាក់ទងនឹងរបៀបរៀបចំខាងរដ្ឋបាលសំរាប់ចំណូលប្រភព

*តទៅទំព័រទី ១៤*

# និន្នាការរយៈពេលខ្លី ឬការផ្លាស់ប្តូររយៈពេលវែង? ឥណទានស្ថាប័ននៅជនបទកម្ពុជា

**គេសង្កេតឃើញថា មានប្រជាជនកាន់តែច្រើនទៅខ្ចីប្រាក់ពីប្រភពស្ថាប័ន ។ ក្នុងអត្ថបទនេះ លោក Brett Ballard ពិនិត្យពីការប្រែប្រួលក្នុងរចនាសម្ព័ន្ធទីផ្សារឥណទានជនបទ ដូចជា ប្រភព ការប្រើប្រាស់ និងទំហំកំចី ។**

## សេចក្តីផ្តើម

ការសិក្សារបស់ វិបសអ ថ្មីៗចំនួនពីរបង្ហាញថា ប្រជាជនដែលប្រកបរបរកសិកម្ម និងពាណិជ្ជកម្ម បន្តពឹងផ្អែកជាបឋមទៅលើធនធានផ្ទាល់ខ្លួន សំរាប់ការចំណាយ និងវិនិយោគ បន្ទាប់មកគឺការខ្ចីបុលពីគ្រួសារ និងញាតិមិត្ត និងពីប្រភពស្ថាប័ន (Ballard and So, 2004 and Kang, forthcoming) ។ របៀបរបបប្រើ ឥណទានក្រៅផ្លូវការមកពីប្រភពគួរទុកចិត្ត និងទុនប្រភពផ្ទាល់ខ្លួនអាចផ្តល់ទុនបានគ្រប់គ្រាន់សំរាប់ធ្វើហិរញ្ញប្បទានដល់សកម្មភាពខ្នាតតូចៗ ប៉ុន្តែជាញឹកញយគេត្រូវការទុនច្រើនៗដើម្បីកែលំអផលិតភាពកសិកម្ម និងពង្រីកពាណិជ្ជកម្ម ។ ទោះបីកំណើនសេដ្ឋកិច្ចក្នុងកំរិតណាមួយ អាចកើតមានឡើង ដោយពុំចាំបាច់មានប្រព័ន្ធធនាគារដែលអភិវឌ្ឍល្អក្តី (Kang, forthcoming) ប៉ុន្តែសមាហរណកម្មកំរិតទាបរវាងឥណទានស្ថាប័ន និងអ្នកវិនិយោគ ជាឧបសគ្គមួយដល់ការរីកចំរើនប្រកបដោយសមធម៌ក្នុងរយៈពេលវែង និងការកាត់បន្ថយភាពក្រីក្រ ។

ប៉ុន្តែមានអាំងឌីកាទ័រមួយចំនួនបង្ហាញថា សព្វថ្ងៃកាន់តែមានអ្នកខ្ចីច្រើនឡើងដែលទទួលបានឥណទានពីប្រភពស្ថាប័ន ។ រឿងនេះអាចជាសញ្ញាសំខាន់មួយឈានទៅរកការអភិវឌ្ឍន៍ទីផ្សារឥណទានស្ថាប័ននៅជនបទកម្ពុជា ទោះជាវិសាលភាព និងទំហំនៃនិន្នាការនេះនៅមិនទាន់ច្បាស់លាស់ក្តី ។ អន្តរកាលបែបនេះ អាចចោទសំនួរសំខាន់ៗលើការធ្វើកម្មវិធី និងគោលនយោបាយដល់អ្នកធ្វើផែនការរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយស្តីពីវិសាលភាព និងល្បឿនដែលគួរលើកទឹកចិត្តកសិករឱ្យខ្ចីឥណទានតាមវិស័យផ្លូវការ ។ សំនួរមួយទៀតជាប់ទាក់ទងនឹងលក្ខខណ្ឌដែលអាចសំរេចគោលដៅទាំងនេះ ដោយមានប្រសិទ្ធភាពខ្ពស់បំផុត ។

អត្ថបទនេះ ពិនិត្យពីការប្រែប្រួលក្នុងរបបទីផ្សារឥណទានជនបទ ដូចជាប្រភពការប្រើប្រាស់ និងទំហំនៃកំចី ។ អត្ថបទបានកត់សំគាល់ថាក្រុមសញ្ជ័យ និងឥណទានខ្នាតតូចរបស់ NGO និងស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs) ព្រមទាំង ធនាគារពាណិជ្ជ និងធនាគារឯកទេសផង សុទ្ធតែមានតួនាទីសំខាន់ក្នុងការ ដោះស្រាយតំរូវការឥណទានរបស់អ្នកវិនិយោគនៅជនបទ ។ ប៉ុន្តែត្រូវប្រឹង ប្រែងថែមទៀត ដើម្បីឱ្យមានឥណទានថោកៗ ដែលប្រជាជនកាន់តែច្រើន នៅជនបទអាចប្រើប្រាស់បាន ទើបអាចសំរេចបាននូវគោលនយោបាយ សង្គមកិច្ច និងសេដ្ឋកិច្ចជួយទ្រទ្រង់ដល់អ្នកក្រ ។

## ប្រភពឥណទាននៅកម្ពុជា

ប្រភពឥណទានស្ថាប័ន និងក្រៅផ្លូវការនានា មានលំនាំដូចបង្ហាញក្នុងក្រាហ្វិក ១ ។ អ្នកស្រាវជ្រាវបានរកឃើញប្រភពជាច្រើនក្នុងវិស័យក្រៅផ្លូវការ (Murshid, 1998) ដូចជា គ្រួសារ និងញាតិមិត្ត, អ្នករកស៊ីចងការប្រាក់ និងពាណិជ្ជករ/ឈ្មួញ ។ បែបបទឥណទានជាមួយគ្រួសារ និងញាតិមិត្ត មានលក្ខណៈសំគាល់ជាអត្រាការប្រាក់ទាប ឬគ្មានសោះ, មានដាក់វត្ថុធានាតិចតួច ឬគ្មានដាក់ និងលក្ខខណ្ឌទន់ភ្លន់លើការប្រើប្រាស់និងបង្វិលសង ។ អ្នករកស៊ីចងការប្រាក់ អាចផ្តល់លក្ខខណ្ឌទន់ភ្លន់ខ្លះៗក្នុងការបង្វិលសង និងការប្រើប្រាស់ ប៉ុន្តែគេតែងយកការប្រាក់ខ្ពស់ក្នុងលំដាប់ពី ១០-២០%/ខែ និងអាចតំរូវឱ្យមានវត្ថុធានា ។ ពាណិជ្ជករ ឬឈ្មួញ ផ្តល់កំចីជាសាច់ប្រាក់ ឬជាវត្ថុ ក្នុងចំនួនផ្សេងៗសំរាប់ការប្រើប្រាស់ដ៏ជាក់លាក់ ហើយលក្ខខណ្ឌបង្វិលសងក៏ប្រែប្រួលខុសគ្នាច្រើនដែរ ។

បច្ចុប្បន្ន វិស័យស្ថាប័នរួមមាន ៩ ស្ថាប័នមីក្រូហិរញ្ញវត្ថុ និង ៤ ធនាគារឯកទេស ក្នុងនេះមានទាំងធនាគារអភិវឌ្ឍន៍ជនបទ (RDB) របស់រដ្ឋ និងធនាគារពាណិជ្ជជាច្រើន ដូចជា អេស៊ីលីដា ជាដើម ។ ស្ថាប័នមីក្រូហិរញ្ញវត្ថុកើតចេញពីសមាគមឥណទានតូចៗឧបត្ថម្ភដោយ NGO ហើយជារឿយៗបានរក្សាទុកសារធាតុខ្លះៗនៃរចនាសម្ព័ន្ធដើម (ឧ. ក្រុមតូចៗ) និងកម្មវត្ថុដើមរបស់ខ្លួន (ឧ. កំចីតូចៗសំរាប់អ្នកក្រ) ។ ស្ថាប័នមីក្រូហិរញ្ញវត្ថុទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា (NBC) ហេតុនេះពួកគេមានសិទ្ធិខ្ចីទុនពី RDB ។ តាមធម្មតា ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារនានា តំរូវឱ្យមានវត្ថុធានាក្នុងទំរង់ណាមួយ ហើយយកការប្រាក់ពី ៣-៥%/ខែ ។ ពួកគេអាចឱ្យខ្ចីសំរាប់តែគោលដៅដ៏ជាក់លាក់ ហើយមួយចំនួនបានកំណត់ទំហំកំចីអប្បបរមា ។ ថ្វីបើអត្រាការប្រាក់របស់ស្ថាប័នទាំងនេះវាទាបជាងខាងវិស័យក្រៅផ្លូវការភាគច្រើនក្តី (ដូចជា អ្នករកស៊ីចងការប្រាក់) ប៉ុន្តែ វានៅតែខ្ពស់ហួសពេកសំរាប់គ្រួសារមានចំណូលទាបជាច្រើន ជាពិសេសបើសិនត្រូវមានវត្ថុធានា និងបន្ទុកចំណាយលើការងារនេះ (ឧ. ចំនួនពេលធ្វើដំណើរការងារក្រដាសស្នាម) (Kang, 2002) ។

ក្នុងវិស័យផ្លូវការ ក៏មានប្រហែល ៩0 NGOs ផងដែរ ក្នុងនេះ ១៨ អង្គការបានចុះបញ្ជីនៅ NBC ។ Beresford *et al.*, (2004) បានធ្វើចំណាត់ថ្នាក់ប្រភពឥណទានទាំងនេះថាជា "ពាក់កណ្តាលផ្លូវការ" ជាមួយគ្នានឹងស្ថាប័នមីក្រូហិរញ្ញវត្ថុនានា, រីឯ Urashima (2002) ) បានដកស្ថាប័នមីក្រូហិរញ្ញវត្ថុចេញពីនិយមន័យស្ថាប័នពាក់កណ្តាលផ្លូវការរបស់គាត់ ។ ទោះបីមានចំណាត់ថ្នាក់ពិតប្រាកដជាស្ថាប័នឥណទានអ្វីក្តី ជាទូទៅក្រុមទាំងនេះទទួលការណែនាំ ការបណ្តុះបណ្តាល និងជំនួយទុនក្នុងលំនាំផ្សេងៗពី NGOs ឬអ្នកផ្តល់ជំនួយផ្សេងៗទៀត ដោយត្រូវផ្សារភ្ជាប់នឹងគំរោងអភិវឌ្ឍន៍សហគមន៍ផ្សេងទៀតជារឿយៗ ។ ពួកគេតែងផ្តល់កំចីខ្នាតតូចមានលក្ខខណ្ឌទន់ភ្លន់ (ឧ. អត្រាការប្រាក់ ១-៣%, វត្ថុធានាមានតិចតួចបំផុត ឬគ្មាន) ដែលអនុញ្ញាតឱ្យប្រជាជន អាចទទួលបានឥណទានសំរាប់បំរើគោលដៅផ្សេងៗ តាមបែបបទដែលអាចរ៉ាប់រងបានជាលក្ខណៈសេដ្ឋកិច្ច និងតាមទំរង់ដែលធ្លាប់ឃើញ ធ្លាប់ស្គាល់នៅក្នុងសង្គម ។ តាមមធ្យោបាយនេះ កម្មវិធីនានាបានបំពេញ "មុខងារជាស្ពាន" ដ៏សំខាន់ ដោយផ្តល់ឱ្យប្រជាជនជនបទនូវបទពិសោធន៍ធ្វើបែបបទខ្ចីឥណទានដែលមានរចនាសម្ព័ន្ធជាក់លាក់ ។

**ក្រាហ្វិក ១: របាយប្រភពឥណទាននានានៅកម្ពុជា**




---

* Brett Ballard គឺជាទីប្រឹក្សាបច្ចេកទេសផ្នែកកសិកម្ម និងអភិវឌ្ឍន៍ជនបទនៅ វិបសអ ។

*ប្រភពកំចី*

តារាង១ ខាងក្រោមបង្ហាញថា មានការប្រែប្រួលគួរកត់សំគាល់ក្នុងរបាយ បន្ដហូរហៀនៃប្រភពទុននេះ បានកើតមានឡើងតាំងពីឆ្នាំ១៩៩៦ ។ អង្កេត សេដ្ឋកិច្ច-សង្គមកិច្ច SESC 1996 (NIS, 1997) បានរកឃើញថា ៨១៣.១៤៨គ្រួសារនៅតាមជនបទ (ប្រហែល ៤៦%) ទទួលបានកំចីនៅឆ្នាំ១៩៩៤-៩៥, ដោយមាន ៨៨% នៃកំចីទទួលបានពីវិស័យក្រៅផ្លូវការ ។ អង្កេតជីវភាពប្រជាជនជនបទ (RLS) ឆ្នាំ២០០១ របស់ វបសអ បានរកឃើញថា គ្រួសារ ៥០-៥២% ទទួលបានកំចីជាសាច់ប្រាក់ក្នុងរដូវវស្សា និងរដូវប្រាំងមុន ដោយមានការប្រែប្រួលខ្លះទៅតាមរដូវ ។ កំចី ៧៧,៦% ទទួលបានពីវិស័យក្រៅផ្លូវការ ។ អង្កេត វបសអ ស្ដីពីការផ្ដល់កម្មសិទ្ធិដីធ្លី (LTS) លើ ១.២៣២គ្រួសារជនបទ នៅដើមឆ្នាំ២០០៤ បានរកឃើញថា គ្រួសារ ៥២,៧% ទទួលបានកំចីជាសាច់ប្រាក់ក្នុងរយៈ ៦ខែមុនពេលធ្វើការសិក្សាដោយប្រហែល ៦២,១%នៃកំចី ទទួលបានពីវិស័យក្រៅផ្លូវការ ។ ការថយចុះភាគរយនៃការខ្ចីពីវិស័យក្រៅផ្លូវការ គឺវាស៊ីគ្នានឹងកំណើននៃការខ្ចីពីប្រភពពាក់កណ្ដាលផ្លូវការ និងស្ថាប័នផ្លូវការពីឆ្នាំ១៩៩៦ (១១%) ដល់ ២០០៤ (៣៧,៩%) ។

**តារាង ១. ប្រភពឥណទាន (ភាគរយនៃកំចី)**

| អ្នកឱ្យខ្ចី | SESC – 1996 | ជីវភាពជនបទឆ្នាំ២០០១ | LTS 2004 |
|---|---|---|---|
| សាច់ញាតិ | 51 | 44.5 | 46.5 |
| មិត្តភក្ដិ | 15 | | |
| អ្នករកស៊ីចងការប្រាក់ | 15 | 33.1 | 15.6 |
| ឈ្មួញ | 7 | | |
| NGOs | 10 | 8.6 | 9.4 |
| MFIs | | | 22.9 |
| ACLEDA | | 7.1 | 5.6 |
| ផ្សេងៗ | 1 | 6.6 | |
| ធនាគារ | 1 | | |

អង្កេតទាំងពីររបស់ វបអស បានរកឃើញ ភាគរយប្រហាក់ប្រហែលគ្នានៃគ្រួសារទទួលបានកំចីជាសាច់ប្រាក់ (៥០% និង ៥២.៧%) ហើយភាគរយនេះវាខ្ពស់ជាងតួលេខនៃអង្កេត SES ឆ្នាំ១៩៩៦ ។ ប៉ុន្ដែអង្កេតទាំង២ ខុសប្លែកគ្នាក្នុងចំនួន (frequency) នៃកំចីពីប្រភពស្ថាប័នដែលកើនពី ១៥,៧%ក្នុងអង្កេត RLS ឆ្នាំ២០០១ ដល់ ៣៧,៩%ក្នុង LTS ២០០៤ ។ តួលេខនេះហាក់បញ្ជាក់ថា ប្រជាជនទៅខ្ចីប្រាក់មិនសូវញឹកញាប់ដូចមុនពីអ្នករកស៊ីចងការប្រាក់ និងប្រហែលពីឈ្មួញផងដែរ) និងខ្ចីច្រើនជាងមុនពីក្រុម NGOs និង MFIs ។ ប្រជាជនហាក់ដូចជាចូលចិត្តខ្ចីពីក្រុម NGO និង MFIs ជាងពីអ្នករកស៊ីចងការប្រាក់ គឺអាចមកពីការប្រាក់មានកំរិតទាបជាង សេវាកម្ម និងផលិតផលមានកាន់តែច្រើន ហើយបណ្ដាញអង្គការក៏បានទៅដល់កំរិតមូលដ្ឋាន ។

ក្នុងកាលៈទេសៈខ្លះៗ កត្ដាទាំងនេះក៏អាចពន្យល់បានគ្រប់គ្រាន់ថា ហេតុអ្វីបានជាប្រជាជនខ្ចីតិចតួចជាងមុនពីឈ្មួញ[1] ។ ប៉ុន្ដែ ការផ្លាស់ប្ដូរដូច្នោះអាចតំណាងឱ្យការប្រែប្រួលមួយរយៈខ្លីក្នុងវដ្ដទីផ្សារ ឬអាចជាប់ទាក់ទងនឹងទីតាំង និងប្រភេទនៃផលិតផលដែលធ្វើពាណិជ្ជកម្ម ។ ឧទាហរណ៍ អ្នកនេសាទ និងអ្នកដងជ័រទឹក ដែលមានជំរើសតិចតួចនូវឥណទានដែលអាចប្រើកើត គឺចូលចិត្តឥណទានជាសាច់ប្រាក់ ឬជាវត្ថុពីឈ្មួញដោយសារវាងាយជាង និងអស់សោហ៊ុយតិចក្នុងពេលសុំខ្ចី ។ របៀបរបបបែបនេះ អាចជួយធានាផងដែរដល់ការរកបានទីផ្សារសំរាប់ផលិតផលរបស់ពួកគេ (Prom and McKenney, 2003) ។ ប៉ុន្ដែ កសិករអាចចូលចិត្តឥណទានជាសាច់ប្រាក់ពីប្រភពស្ថាប័ន ដើម្បីទិញធាតុចូលបំរើផលិតកម្ម ជាជាងខ្ចីបុលធាតុចូលឬឥណទានពីពាណិជ្ជករ ឬឈ្មួញក្នុងអត្រាការប្រាក់ដ៏ខ្ពស់ ។

ប្រជាជនក្នុងគ្រប់កំរិតប្រាក់ចំណូល និង/ឬទំហំដីកាន់កាប់ មានខ្ចីពីច្រើនប្រភព ផ្អែកទៅតាមតំរូវការ និងកាលៈទេសៈ (ដូចជា ភាពបន្ទាន់, រដូវកាល) ។ ជាលទ្ធផល ការសំរេចចិត្តពីប្រភព និងការប្រើប្រាស់កំចី គឺជាបញ្ហាយុទ្ធសាស្ដ្រ (ដូចជា ការវិនិយោគ) និងយុទ្ធវិធី (ដូចជា តំរូវការប្រាក់ក្នុងគ្រួសារ) ។ ឧទាហរណ៍ ថ្វីបើប្រជាជនមួយចំនួនចូលចិត្តខ្ចីពី NGO ឬ MFIs, ភាពបន្ទាន់នៃការព្យាបាល ឬការមិនអាចរករបស់ដាក់ធានាបានដើម្បីខ្ចីធាតុចូលកសិកម្ម អាចបង្ខំឱ្យពួកគេបន្ដខ្ចីពីអ្នករកស៊ីចងការប្រាក់ ឬឈ្មួញ ។ ទីផ្សារហិរញ្ញវត្ថុជនបទ នៅកាត់ផ្ដាច់ជាចំណែកៗច្រើននៅឡើយ ដូច្នេះហើយ ការផ្លាស់ប្ដូរក្នុងរយៈពេលវែងពីប្រភពក្រៅផ្លូវការ ទៅកាន់ប្រភពផ្លូវការ អាចវិវត្ដទៅមុខដោយពុំមានក្នុងល្បឿនថេររហូតទេ (linear progression) ។

និន្នាការបានអង្កេតឃើញស្ដីពី កំណើនការខ្ចីពីប្រភពស្ថាប័ន អាចជាប់ទាក់ទងច្បាស់លាស់ជាងទៅនឹង កំណើនការផ្គត់ផ្គង់ឥណទានមានតំលៃទាបជាង និងចំនួនផលិតផល និងសេវាបំរើអតិថិជន ។ ឧទាហរណ៍ កំណើនរបស់អេស៊ីលីដាពី ១៤សាខា នៅក្នុង ៣៤ស្រុកនាឆ្នាំ២០០០ ដល់ ១៩សាខានៅក្នុង ៨២ស្រុក បានដើរស្របគ្នាជាមួយកំណើនចំនួនកំចីពី ១០២.៤៧៣កំចីនៅឆ្នាំ២០០០ ដល់ ១៥៩.៥១០កំចីនៅឆ្នាំ២០០៣ ឬកំណើន ៥៥,៦% ។ នៅក្នុងរយៈពេលដូចគ្នា ទំហំកំចីជាមធ្យមកើនពី ២៩៩ដុល្លារ ទៅដល់ ៤៦៦ដុល្លារ ។ ទន្ទឹមនឹងនេះ ក៏មានសញ្ញាមួយចំនួនបង្ហាញពីការរីកធំធាត់ក្នុងចំណោម MFIs ដែរ ។ ចំពោះ ៧ MFIs (ក្នុងចំណោម ៩ MFIs) ទិន្នន័យ NBC បានបង្ហាញពីចំនួនអ្នកខ្ចីសរុប ១៥១.១០២នាក់ នៅចុងឆ្នាំ២០០២ និង ១៨៤.៣៤៨នាក់ នៅខែមិថុនា ២០០៤ ឬកំណើន ២២,០% ។

សំរាប់ក្រុម NGOs វិញ គឺមានភស្ដុតាងបង្ហាញថា ការរីកធំធាត់មួយកំរិតបានកើតមានឡើងនៅក្នុងតំបន់មួយចំនួន ។ ឧទាហរណ៍ អង្គការបាដិករាយការណ៍ពី ១.៣៦៣កំចីឱ្យដល់សមាជិក ក្នុង ២២ក្រុម នៅខេត្តកំពង់ស្ពឺ ឆ្នាំ១៩៩៧ (Rao and Swift, 1998) ។ តាំងពីពេលនោះមក មានផ្ដល់ថែមទៀត ៤.៤២៩កំចីឱ្យដល់សមាជិក ក្នុង ៤៤៥ក្រុមជួយខ្លួនដោយខ្លួនឯងថ្មីៗ (SHGs) ក្នុង ៥ខេត្ត (Padek, forthcoming) ។ ប៉ុន្ដែ Beresford *et al.* (2004) ក៏បានសង្កេតឃើញដែរថា ក្រុម NGO មួយចំនួន គឺត្រឹម "រស់បានដោយត្រដ" ហើយអាចជិតដួលរលំហើយ ។ រឿងនេះបញ្ជាក់ថា អ្នកផ្ដល់ជំនួយត្រូវបំពេញបន្ថែមលើជំនួយហិរញ្ញវត្ថុរបស់ខ្លួននូវ ជំនួយបច្ចេកទេសថែមទៀត ដើម្បីជួយសមាគមឥណទានពាក់កណ្ដាលផ្លូវការ និង MFIs ឱ្យកែលំអររបៀបរបបគ្រប់គ្រង ។

មតិចុងក្រោយដ៏សំខាន់មួយ ជាប់ទាក់ទិននឹងផលប៉ះពាល់ដែលស្ថាប័នផ្លូវការ និងពាក់កណ្ដាលផ្លូវការ អាចបង្កលើអត្រាការប្រាក់ក្នុងវិស័យក្រៅផ្លូវការ នៅពេលស្ថាប័នពង្រីកប្រតិបត្ដិការរបស់ខ្លួននៅតំបន់ជនបទ ។ ការរាយរាប់ពីភស្ដុតាងមួយចំនួនបានផ្ដល់គំនិតថា អ្នករកស៊ីចងការប្រាក់ខ្លះបានបញ្ចុះអត្រាការប្រាក់ ដើម្បីប្រកួតប្រជែងនឹងស្ថាប័នផ្ដល់កំចី ។ ប៉ុន្ដែ របាយ និងផលប៉ះពាល់ចំពោះគ្រួសារជនបទនៃអត្ថប្រយោជន៍បានពីអត្រាការប្រាក់ក្រៅផ្លូវការទាបជាងមុន ដែលកើតចេញពីការប្រកួតប្រជែងបែប

នេះ គឺមិនទាន់ច្បាស់លាស់ទេ ។ ឧទាហរណ៍ Murshid (1998) and Sophal and Acharya (2002) បានកត់សំគាល់ឃើញថា គ្រួសារក្រីក្រតែងតែត្រូវបង់អត្រាការប្រាក់ខ្ពស់ជាងគ្រួសារអ្នកមាន ។ តើមានការកាត់បន្ថយអត្រាការប្រាក់ជាក់ស្តែងប៉ុន្មាន ហើយតើការកាត់បន្ថយនោះ បានធ្លាក់ទៅដល់គ្រួសារក្រីក្រប៉ុណ្ណាដែរ? ការស្រាវជ្រាវថែមទៀតទៅលើសំណួរទាំងនេះ ត្រូវមានយ៉ាងច្បាស់ ។

### *ការប្រើប្រាស់កំចី*

ដើម្បីវាយតំលៃពីរបាយការណ៍ប្រើប្រាស់កំចី គេត្រូវចងចាំថា ប្រជាជនជួនកាលផ្តល់មូលហេតុមួយដើម្បីខ្ចីប្រាក់ តែក្រោយមកបានប្រើប្រាស់ប្រាក់ក្នុងគោលដៅផ្សេងទៅវិញ ។ ភាពខុសប្លែកគ្នារវាងកំចីសំរាប់ផលិតកម្ម និងកំចីសំរាប់ប្រើប្រាស់ ជួនកាលក៏ស្រពិចស្រពិលដែរ ដូចជាក្នុងករណីកំចីសំរាប់ការដឹកជញ្ជូន ។ ទោះយ៉ាងនេះក្តី ការញែកចេញពីគ្នានៅតែមានប្រយោជន៍គួរសមសំរាប់រកមើលលំនាំទូទៅក្នុងការប្រើប្រាស់កំចី ។

ទិន្នន័យ LTS បង្ហាញថា កំចីសំរាប់វិនិយោគផលិតកម្ម មាន ៣៧,១% នៃសកម្មភាពឥណទានដែលបានរាយការណ៍ទាំងអស់ រួមទាំងការធ្វើស្រូវ និងដំណាំផ្សេងទៀត(១៦,២%) សកម្មភាពជាប់ទាក់ទិននឹងពាណិជ្ជកម្មតូចតាច (១១,៦%) និងការចិញ្ចឹមសត្វ(៩,៣%) ។ ចំណាយប្រើប្រាស់មានជិតដល់ ៤0% នៃសកម្មភាពឥណទានទាំងអស់ រួមទាំង "ការខ្ចីមានធុរៈបន្ទាន់" សំរាប់ការថែទាំសុខភាព (២0,៩%) និងកង្វះស្បៀងអាហារ (១៦,៨%) ។ ការធ្វើផ្ទះមាន ៦,៥% នៃកំចី ហើយសកម្មភាពផ្សេងទៀត (ដូចជា ពិធីបុណ្យ ការដឹកជញ្ជូន) មាន ១៨,៧% ។

តួលេខខាងលើផ្ទុយគ្នាពីការសិក្សា EMT (Benkirane, 2003) ដែលរកឃើញថា ៦៤% នៃកំចី គឺសំរាប់បំរើផលិតកម្ម ក្នុងនេះមានការដាំដុះ ២៨%, ការចិញ្ចឹមសត្វ ២៧,៦% និង "វិនិយោគ" ៨,៤% ដែលប្រហែលជារួមបញ្ចូលទាំងពាណិជ្ជកម្មខ្នាតតូចផង ។ កំចីប្រហែល ២0% គឺសំរាប់ការប្រើប្រាស់ ប៉ុន្តែការសិក្សាមិនបានបំបែកមុខចំណាយលំអិតថែមទៀតទេ ។ កំចីនៅសល់ ១៥,៩% គឺសំរាប់មូលហេតុផ្សេងទៀត ។ របាយនៃកំចីសំរាប់ការប្រើប្រាស់ និងផលិតកម្ម មានលំនាំប្រហែលគ្នានឹងរបាយដែលរកឃើញនៅក្នុង Padek SHGs តាំងពីឆ្នាំ២000 (Padek, forthcoming) ។

ភាពខុសប្លែកគ្នារវាងរបាយកំចីសំរាប់ផលិតកម្ម និងការប្រើប្រាស់នៅក្នុង LTS, និង របាយក្នុង EMT និង Padek SHGs, អាចពន្យល់បានមួយចំណែកទៅតាមតួនាទីដែលក្រុមនានាបានបំពេញក្នុងការវាយតំលៃពីការប្រើប្រាស់កំចីរបស់សមាជិកទាំងឡាយ ។ ថ្វីបើមានលក្ខខណ្ឌទន់ភ្លន់ខ្លះដែលអនុញ្ញាតឱ្យយកកំចីមកបំរើការប្រើប្រាស់ ប៉ុន្តែក្រុមទាំងនេះច្រើនតែសង្កត់ធ្ងន់លើសកម្មភាពរកប្រាក់ចំណូល ។ NGOs មួយចំនួន រួមទាំង Padek ផងក៏មានផ្តល់ផងដែរនូវសេវាផ្សព្វផ្សាយបច្ចេកទេស (ដូចជា ការគ្រប់គ្រងពាណិជ្ជកម្មខ្នាតតូច ការដាំដុះ និងសុខភាពសត្វចិញ្ចឹម) ដែលជួយទ្រទ្រង់ដល់កំចីសំរាប់បំរើផលិតកម្ម ។ ចំណាប់អារម្មណ៍នេះក៏ត្រឹមត្រូវដូចគ្នាសំរាប់ NGOs និង PRASAC នៅក្នុង LTS ដែលមានកំចីសំរាប់ផលិតកម្ម ៦៥,៩% និង ៦៤,0 រៀងគ្នា ។ ប៉ុន្តែ ក្នុងកំចី MFI មានតែ ៤២,៣% ប៉ុណ្ណោះដែលសំរាប់ផលិតកម្ម ។ ភាគរយខ្ពស់ជាង (៤0%) នៃកំចី MFI សំរាប់ចំណាយលើស្បៀងអាហារ និងសុខភាព អាចទាក់ទិននឹងបំរែបំរួលតាមរដូវកាល និងទីតាំង (សូមអានខាងក្រោម) ។

រឿងប្រើប្រាស់កំចី វាចោទបញ្ហាជាពិសេសនៅពេលដែលប្រជាជនខ្ចីប្រាក់សំរាប់ចំណាយលើពិធីផ្សេងៗក្នុងសង្គម (ដូចជា អាពាហ៍ពិពាហ៍) ឬធុរៈបន្ទាន់ (ដូចជា ការថែទាំសុខភាព កង្វះស្បៀង) ហើយក្រោយមកត្រូវលក់ទ្រព្យផលិតកម្ម ដូចជាសត្វចិញ្ចឹម ឬដីធ្លីដើម្បីសងគេវិញ ។ អ្នកស្រាវជ្រាវបានសង្កេតឃើញថា ការខ្ចីដោះធុរៈបន្ទាន់ក្នុងរយៈពេលខ្លី បានដាក់បន្ទុកយ៉ាងធ្ងន់ទៅលើអ្នកក្រីក្រ ហើយអាចច្រានចេញអស់នូវវិនិយោគសំរាប់បំរើផលិតកម្មជាសក្តានុពលនានា (Murshid, 1998, Chan and Acharya, 2002) ។ អ្នកស្រាវជ្រាវក៏បានតភ្ជាប់ចំណាយថែទាំសុខភាព ទៅនឹងការលក់ទ្រព្យសម្បត្តិដែរ (ដូចជា Biddulph, 2004) ។ ដូច្នេះ ការថែទាំសុខភាព និងសន្តិសុខស្បៀង គឺជាវិស័យពីរដែលត្រូវមានការចាប់អារម្មណ៍រួមគ្នា ដើម្បីញ៉ាំងឱ្យគោលនយោបាយសំរាប់ តំរង់ទិសធនធានហិរញ្ញវត្ថុទៅរកការប្រើប្រាស់មានផលិតភាពខ្ពស់បំផុតអាចទទួលបានជោគជ័យ ។

### *ទំហំកំចី*

**តារាង២. ទំហំកំចីតាម ប្រភពឥណទាន និងការប្រើប្រាស់ឥណទាន**

| គោលដៅ | សាច់ញាតិ/មិត្តភក្តិ | | អ្នករកស៊ីចងការប្រាក់ | | NGOs | | MFIs | | ACLEDA | | សរុប ** | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | ទឹកប្រាក់* | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ |
| កសិកម្ម | 62 | 17.7 | 27 | 20.5 | 23 | 15.4 | 22 | 24.8 | 7 | 53.6 | 147 | 22.5 |
| ពាណិជ្ជកម្ម | 29 | 57.8 | 15 | 23.5 | 14 | 20.8 | 26 | 21.3 | 16 | 128.2 | 105 | 49.7 |
| ស្បៀងអាហារ | 84 | 12.3 | 26 | 20.3 | 4 | 30.5 | 26 | 11.3 | 10 | 27.7 | 152 | 15.2 |
| សុខភាព | 99 | 29.7 | 24 | 20.6 | 9 | 35.9 | 47 | 13.2 | 7 | 45.0 | 189 | 25.6 |
| បសុសត្វ | 20 | 48.1 | 7 | 16.1 | 19 | 19.8 | 29 | 19.8 | 4 | 140.0 | 84 | 35.5 |
| លំនៅដ្ឋាន | 40 | 68.5 | 5 | 44.4 | 5 | 40.0 | 9 | 48.3 | 0 | 0.0 | 59 | 60.9 |
| ផ្សេងៗ | 87 | 33.6 | 37 | 32.8 | 11 | 39.4 | 23 | 31.4 | 7 | 107.9 | 169 | 47.7 |
| សរុប/មធ្យម | 421 | 31.8 | 141 | 24.7 | 85 | 24.7 | 182 | 20.6 | 51 | 85.0 | 905 | 32.1 |
| សរុបជា % | 46.5 | | 15.6 | | 9.4 | | 20.1 | | 5.6 | | | |

** ចំនួនជាមធ្យមគិតជាម៉ឺនរៀល ១0.000រៀល = ២,៥0ដុល្លារ.*

*** រួមទាំង ២៥កំចីPRASAC ដែលមិនបានបញ្ចូលក្នុង NGOs ទេ.*

ទិន្នន័យ LTS ក្នុង តារាង២ បង្ហាញថា ទំហំកំចីប្រែប្រួលខុសគ្នាទៅតាម ប្រភព និងការប្រើប្រាស់ ។ ប្រជាជនច្រើនទទួលបានកំចីធំៗពីប្រភពស្ថាប័ន ជាងពីប្រភពក្រៅផ្លូវការ ប៉ុន្តែ គេខ្ចីបានញឹកញាប់ជាងពីវិស័យក្រៅផ្លូវការ ។ កំចីធំៗគឺទទួលបានពីអេស៊ីលីដា ដែលមានទឹកប្រាក់ជាមធ្យម ៨៥ម៉ឺន រៀល ។ ទំហំជាមធ្យមនៃកំចី NGO និង MFI គឺ ២៤,៦៩ និង ២០,៦ម៉ឺន រៀលរៀងៗគ្នា ។ ប៉ុន្តែតួលេខនេះ មិនរាប់បញ្ចូល ២៥កំចីពី PRASAC NGO ទេ ដែលមានទំហំជាមធ្យម ៧៩,៦ម៉ឺនរៀល ។ ក្នុងវិស័យក្រៅផ្លូវការ ទំហំកំចីជាមធ្យមពីសាច់ញាតិ និងមិត្តភក្តិគឺ ៣២,៦ នឹង ១៩,៨ ម៉ឺនរៀល រៀងៗគ្នា ។ ទំហំកំចីជាមធ្យមពីអ្នករកស៊ីចងការប្រាក់ គឺ ២៤,៦៥ម៉ឺនរៀល គឺសឹងតែស្មើគ្នានឹងប្រភព NGOs ដែលមានកំរិត ២៤,៦៩ម៉ឺនរៀល ។ ដូច្នេះ ទិន្នន័យផ្តល់គំនិតថា នៅក្នុងប្រព័ន្ធតម្រូវការដឹកនៃឥណទាននេះ ប្រភពកំចីស្ថិត នៅកំរិតណាៗ គឺមិនមែនជាអាំងឌីកាទ័រដ៏ល្អនៃទំហំកំចីទេ ។

អេស៊ីលីដា មានផ្តល់កំចីធំៗបំផុត (៦៨,៥ម៉ឺនរៀល) នៅក្នុងអង្កេត 2002 RLS, បន្ទាប់មកអ្នករកស៊ីចងការប្រាក់ និងបន្ទាប់មកទៀតគឺសាច់ញាតិ និងមិត្តភក្តិ ។ រឿងនេះខុសពីលំនាំ LTS ដែលក្នុងនោះ កំចីជាមធ្យមបានពីសាច់ញាតិ និងមិត្តភក្តិ គឺធំជាងកំចីពីអ្នករកស៊ីចងការប្រាក់ ។ ទោះបីអង្កេត RLS មិនបានសំដៅជាពិសេសដល់ MFIs ឬ NGOs ក្តី ប៉ុន្តែការប្រែប្រួលនេះអាចឆ្លុះបញ្ចាំងពីការពិតដែលប្រជាជនកំពុងតែប្រើប្រាស់ការផ្គត់ផ្គង់ឥណទានកាន់តែច្រើនពីប្រភពស្ថាប័ន (MFIs និង NGOs) ដើម្បីទទួលបានកំចីមានតំលៃទាប ។ ការសង្កេតនេះបានបញ្ជាក់ទៀតថា ការផ្លាស់ប្តូរពីប្រភពក្រៅផ្លូវការទៅប្រភពស្ថាប័ន គឺមិនសុទ្ធតែមានការរីកលូតលាស់ថេរនោះទេ ។

កំចីធំៗបំផុតក្នុង LTS គឺសំរាប់លំនៅដ្ឋាន (៦០,៩ម៉ឺនរៀល) និងគោលដៅផលិតកម្ម ក្នុងនេះមានសកម្មភាពពាណិជ្ជកម្ម (៤៩,៧ម៉ឺនរៀល) បន្ទាប់មកការចិញ្ចឹមសត្វ (៣៥,៥ម៉ឺនរៀល) និងការដាំដុះស្រូវ និងដំណាំផ្សេងទៀត (២២,៥ម៉ឺនរៀល) ។ កំចីសំរាប់បំរើការប្រើប្រាស់ជាទូទៅមានទឹកប្រាក់តិចជាង គឺសំរាប់សុខភាព (២៥,៦ម៉ឺនរៀល) និងស្បៀងអាហារ (១៥,២ម៉ឺនរៀល) ។ កំចីធំៗបំផុតសំរាប់ការដាំដុះស្រូវ និងដំណាំផ្សេងទៀត ទទួលបានពីប្រភពស្ថាប័ន ប៉ុន្តែកំចីសំរាប់ការដាំដុះមានញឹកញាប់ជាងពីវិស័យក្រៅផ្លូវការ ។ ប្រជាជនខ្ចីញឹកញាប់ជាងពីសាច់ញាតិ និងមិត្តភក្តិ សំរាប់តំរូវការមានរយៈពេលខ្លី (ដូចជា ស្បៀងអាហារ និងសុខភាព) ប៉ុន្តែទឹកប្រាក់ជាមធ្យមស្ថិតក្នុងចន្លោះ អេស៊ីលីដា និង MFIs ។ ជាទូទៅ ការសង្កេតទាំងនេះ គឺស្របគ្នានឹងអង្កេត RLS ដែលផ្តល់គំនិតថា កំចីពីប្រភពស្ថាប័ន ជាទូទៅគឺធំៗជាង ព្រោះសំរាប់បំរើគោលដៅផលិតកម្ម រីឯកំចីពីប្រភពក្រៅផ្លូវការ ជាទូទៅដោះស្រាយតំរូវការក្នុងរយៈពេលខ្លី ឬតាមរដូវ ។

| តារាង ៣. របាយកំចីតាម ឃុំ និង ប្រភព (%) | | | | | |
|---|---|---|---|---|---|
| ឃុំ | ក្រៅផ្លូវការ | ពាក់កណ្តាលផ្លូវការ | ផ្លូវការ | សរុបកំចី | |
| | | | | ចំនួន | ចំនួន/គ្រួ |
| ត្រពាំងសាប | 52.7 | 13.7 | 33.6 | 131 | 1.03 |
| រវាង | 69.7 | 8.3 | 22.0 | 109 | 1.18 |
| ស្រយូវ | 58.1 | 11.8 | 30.1 | 93 | 1.50 |
| ទីពូ | 80.5 | 2.6 | 16.9 | 77 | .65 |
| សមបូរ | 70.2 | 0 | 29.8 | 114 | 1.16 |
| Srangle | 85.7 | 1.1 | 13.2 | 91 | 1.12 |

ទំនាក់ទំនងបែបនេះរវាងប្រភព ទំហំ និងការប្រើប្រាស់កំចី មិនមែនត្រឹមត្រូវរាល់លើកនោះទេ ។ ឧទាហរណ៍ ក្នុងអង្កេត LTS ប្រជាជនទទួលបានកំចីធំៗពី សាច់ញាតិ និងមិត្តភក្តិ សំរាប់ធ្វើលំនៅដ្ឋាន (៦៨,៥ ម៉ឺនរៀល) ជាជាងកំចីពី MFIs (៤៨,៣ម៉ឺនរៀល) ។ ក្នុងវិស័យពាណិជ្ជកម្ម កំចីធំៗបំផុត ទទួលបានពីអេស៊ីលីដា និង PRASAC (១២៨,២ និង ៥៩,0ម៉ឺនរៀល រៀងគ្នា) ។ ប៉ុន្តែប្រជាជនទទួលបានកំចីធំៗញឹកញាប់ជាងសំរាប់វិនិយោគក្នុងពាណិជ្ជកម្ម ពីសាច់ញាតិ និងមិត្តភក្តិ (៥៧,៨ម៉ឺនរៀល) ជាជាងពី NGOs និង MFIs (២០,៨ និង ២១,៣ ម៉ឺនរៀលរៀងគ្នា) ។ ការសង្កេតនេះអាចជួយគាំទ្រមួយកំរិតដល់សម្មតិកម្មរបស់ Kang (forthcoming) ដែលថានៅពេលចាប់ផ្តើមរកស៊ីដំបូង ប្រជាជនច្រើនតែខ្ចីទុនពីសាច់ញាតិ និងមិត្តភក្តិដែលទុកចិត្ត, ហើយទទួលបានកំចីធំៗពីប្រភពស្ថាប័ន សំរាប់បំរើដំណើរការ និង/ឬ ការពង្រីកពាណិជ្ជកម្ម ។ បើសិនជាដូច្នេះមែន ភស្តុតាងនៃកំណើនការខ្ចីពីប្រភពស្ថាប័ននៅពេលចាប់ផ្តើមរកស៊ី វាបង្ហាញពីជោគជ័យដ៏សំខាន់មួយក្នុងការអភិវឌ្ឍន៍ទីផ្សារហិរញ្ញវត្ថុជនបទ ។

## *បំរែបំរួលទីតាំង*

RLS បានសំគាល់ឃើញថា ប្រជាជនតែងមានខ្ចីច្រើននៅតាមភូមិដែលសកម្មភាពនានាមានលក្ខណៈពាណិជ្ជកម្មច្រើន ដោយសារទីផ្សារមានកំរិតធ្វើសមាហរណកម្មខ្ពស់ជាង ។ ប្រជាជនក៏មានខ្ចីទឹកប្រាក់ច្រើនៗក្នុងភូមិមួយចំនួន បើធៀបនឹងភូមិឯទៀតដែរ ។ Chan and Acharya (2002) ផ្តល់មតិថា ចំនួន ទំហំ និងការប្រើប្រាស់កំចី អាចទាក់ទិននឹងកំរិតធ្វើទំនើបកម្មកសិកម្ម ឬភាពមមាញឹកនៃសកម្មភាពមិនមែនកសិកម្ម ។

អង្កេត LTS ក៏បានរកឃើញការប្រែប្រួលខុសគ្នាមួយចំនួនក្នុងប្រភព និងការប្រើប្រាស់កំចី រវាងឃុំនានាដែរ ។ ឧទាហរណ៍ ត្រពាំងសាប(តាកែវ) ស្រយូវ(កំពង់ធំ) និងសំបួរ (កំពង់ចាម) គឺជាឃុំមានសេដ្ឋកិច្ចសកម្មជាងគេក្នុងគំរូតាងអង្កេត ដោយសារមានទីតាំងនៅតាមដងផ្លូវជាតិធំៗ និងនៅជិតមជ្ឈមណ្ឌលពាណិជ្ជកម្ម ។ ឃុំទាំង៣ ទទួលបាន ៣ចំណាត់ថ្នាក់ខ្ពស់ជាងគេលើចំនួនកំចី, ៣ចំណាត់ថ្នាក់ខ្ពស់ជាងគេលើអត្រាខ្ចីប្រាក់ (ចំនួនកំចីក្នុងមួយគ្រួសារដែលខ្ចីប្រាក់) និងមានភាគរយខ្ពស់ជាងគេនៃកំចីពីប្រភពផ្លូវការដែលក្នុងនេះមានទាំង MFIs និងអេស៊ីលីដា ផងដែរ ។ ទីពូ (កំពង់ធំ) ជាឃុំដែលធ្វើសមាហរណកម្មចូលទីផ្សារតិចជាងគេ និងមានការធ្វើចំរុះកម្មសេដ្ឋកិច្ចតិចដែរ ដោយសារទីតាំងឃុំ ។ ទីពូ ក៏មានចំនួនកំចីទាបជាងគេ និងមានភាគរយទាបបំផុតនៃកំចីពីប្រភពផ្លូវការដែរ ។

របាយនៃការខ្ចីសំរាប់ផលិតកម្ម និងការប្រើប្រាស់ ក៏ប្រែប្រួលទៅតាមឃុំដែរ ។ ឧទាហរណ៍ នៅ សំបួរ និង ស្រយូវ កំចីផលិតកម្មមាន ៥៦,១% និង ៣៦,៦% រៀងគ្នា ។ ប៉ុន្តែនៅ ទីពូ មានកំចីតែ ១៤,៣% ប៉ុណ្ណោះសំរាប់ផលិតកម្ម ហើយ ៦៣,៦% គឺសំរាប់ការប្រើប្រាស់ ។

## សេចក្តីសន្និដ្ឋាន

អ្នកខ្ចីនៅជនបទ ទំនងជាប្តូរកាន់តែច្រើនទៅរកប្រភពស្ថាប័ន ក្នុង ២-៣ ឆ្នាំខាងមុខនេះ ។ ល្បឿន និងទិសដៅដែលប្រជាជននឹងផ្លាស់ប្តូរក្នុងប្រព័ន្ធតម្រូវការដឹកនៃឥណទាន ទៅកាន់ប្រភពជាក់លាក់ណាមួយ នឹងផ្អែកទៅលើកត្តាផ្សេងៗដូចជា ១) ចំនួនជំរើសឥណទានដែលអាចរកបាន, ២) កំរិតនៃសកម្មភាពសេដ្ឋកិច្ច និងសមាហរណកម្មទីផ្សារ, ៣) ទំនោររបស់ប្រជាជន (ឧ. ទំនុកចិត្តលើស្ថាប័ន ផលចំណេញរំពឹងទុក ពតិមាន) និងសមត្ថភាព

(ឧ. កិរិតធនធាន ទ្រព្យសកម្ម មុខរបរ) ក្នុងការខ្ចី ។ ការចែកចាយផលប្រយោជន៍នៃកំណើនលទ្ធភាពទទួលបានឥណទានពីប្រភពស្ថាប័ន ជាពិសេសក្នុងចំណោមគ្រួសារក្រីក្រ ក៏ផ្អែកផងដែរទៅលើកត្តាជាច្រើនទៀត ជាអាទិ៍ សន្តិសុខស្បៀង និងលទ្ធភាពទទួលបានការថែទាំសុខភាពមានតំលៃថោកសមរម្យ ។

កម្មវិធីឥណទានរបស់ NGOs និង MFIs បានឈោងទៅដល់ប្រជាជនកាន់តែច្រើននៅតាមតំបន់ជនបទ ។ ប៉ុន្តែការឈោងដល់ទាំងនេះនៅមានកំរិតតូច ហើយទោះបីលក្ខខណ្ឌមានភាពទន់ភ្លន់ជាទូទៅក្តី ប៉ុន្តែកម្មវិធីមួយចំនួននៅមានចំណាយច្រើនពេកសំរាប់អ្នកក្រនៅជនបទ ។ អ្នកផ្តល់ជំនួយអាចបន្តដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍន៍ទីផ្សារឥណទានជនបទ ដោយបង្កើនការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុរបស់ខ្លួនដល់កម្មវិធីមីក្រូហិរញ្ញវត្ថុ ជាពិសេសនៅតាមតំបន់ដែលមិនទាន់មានជំរើសឥណទានស្ថាប័នផ្សេងទៀត ។ រដ្ឋាភិបាលក៏អាចជួយលើកកំពស់សមាគមឥណទាន ដោយបង្កើតស្ថានភាពស្របច្បាប់ និងបទប្បញ្ញត្តិផ្សេងៗដើម្បីអនុញ្ញាតឱ្យពួកគេអាចទទួលបានឥណទានពីធនាគារឯកទេស ឬធនាគារពាណិជ្ជ ដោយពុំមានអស់ចំណាយរដ្ឋបាល ដូចក្នុងគំរូ MFI បច្ចុប្បន្ន ។ រឿងនេះនឹងជួយលើកកំពស់ចិរភាព ព្រមទាំងធ្វើឱ្យអ្នកផ្តល់ជំនួយអាចរំដោះធនធាន យកទៅទ្រទ្រង់ដល់កម្មវិធីឥណទានជនបទថ្មីៗទៀត ។

ធនាគារឯកទេស និងធនាគារពាណិជ្ជ គួរបន្តពង្រីកប្រតិបត្តិការរបស់ខ្លួននៅតំបន់ជនបទ និងធ្វើសេរីភាវូបនីយកម្មលើ លក្ខខណ្ឌឥណទានរបស់ខ្លួន (ដូចជា បញ្ចុះអត្រាការប្រាក់ កែប្រែការតំរូវឱ្យដាក់របស់ធានា) ឱ្យបានសមស្រប ដើម្បីឱ្យប្រជាជនជនបទកាន់តែច្រើនអាចទទួលបានកំចី ។ ឧទាហរណ៏ RDB អាចបញ្ចុះអត្រាការប្រាក់លើកំចីផ្តល់ឱ្យ MFIs ហើយតាមនេះ MFIs នឹងអាចបញ្ចុះអត្រាការប្រាក់យកពីអតិថិជននៅជនបទ ។ ស្ថាប័នទាំងនេះ គួរបន្តកិច្ចប្រឹងប្រែងរបស់ខ្លួន ដើម្បីផ្តល់សេវា និងផលិតផលកាន់តែច្រើនទៅឱ្យអតិថិជននៅជនបទ ។ ការប្រកួតប្រជែងកាន់តែច្រើនក្នុងវិស័យឥណទានជនបទ ក៏អាចជំរុញឱ្យមានសេវាកម្ម និងលក្ខខណ្ឌកាន់តែប្រសើរសំរាប់អតិថិជន ។ រដ្ឋាភិបាលក៏មានតួនាទីសំខាន់ត្រូវបំពេញដែរ ដើម្បីធានាថា សេរីភាវូបនីយកម្ម និងការប្រកួតប្រជែង នឹងមិននាំឱ្យមានការឱ្យខ្ចីប្រាក់ដោយគ្មានការទទួលខុសត្រូវអ្វីសោះ ។

ចំពោះការកែលំអលទ្ធភាពទទួលបានឥណទានផ្លូវការ រដ្ឋាភិបាលបានចាត់វិធានការសំខាន់ៗជាច្រើនហើយ តាមការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដែលអាចប្រើការជារបស់ធានាបាន ។ កិច្ចប្រឹងប្រែងទាំងនេះគួរតែពង្រីក និងពន្លឿនថែមទៀត ជាពិសេសនៅតាមតំបន់ដែលមានស្ថាប័នឥណទានផ្លូវការ និងពាក់កណ្តាលផ្លូវការ ទាំងទីផ្សារដែលកំពុងអភិវឌ្ឍឡើង ។ កិច្ចប្រឹងប្រែងបែបនេះ អាចមានប្រសិទ្ធភាពខ្ពស់បំផុតនៅតាមតំបន់ដែលមានសេវាផ្សព្វផ្សាយបច្ចេកទេស (ដូចជាស្តីពីដំណាំ បសុសត្វ) និងសេវាខាងសង្គមកិច្ច (ការថែទាំសុខភាព) មានតំលៃថោកសមរម្យ ។

## កំណត់សំគាល់

១. ពាណិជ្ជករអាចមានបូកបញ្ចូលជាមួយអ្នករកស៊ីចងការប្រាក់ និងអ្នកផ្សេងទៀត នៅក្នុងអង្កេត RLS, ប៉ុន្តែពាណិជ្ជករគ្មានឃើញលើកឡើងសោះនៅក្នុងអង្កេត LTS ហើយរឿងនេះប្រហែលមកពីទិន្នន័យ LTS សំដៅដល់កំចីជាសាច់ប្រាក់ ជាជាងកំចីជាវត្ថុ ។

២. ក្នុងចំណោម MFIs ទាំង ៧ មាន ៤ MFIs បានចុះបញ្ជីជា NGOs នៅឆ្នាំ ២០០២ ហើយតាំងពីពេលនោះមក ក៏ក្លាយជា MFIs ដែលមានអាជ្ញាប័ណ្ណ ។

## ឯកសារយោង


Ballard, Brett and So Savanarith (2004); “Can Land Titles Help Reduce Rural Poverty in Cambodia?” *Cambodia Development Review*, Vol. 8, No. 3 (Phnom Penh: CDRI) pp. 1-5

Benkirane, Lamya (2003), EMT Client Assessment (Phnom Penh: CRS Cordaid Microfinance Alliance Fund Technical Assistance Component)

Beresford, Melanie, Nguon Sokha, Rathin Roy, Sau Sisovanna and Ceema Namazie (2004), *The Macroeconomics of Poverty Reduction in Cambodia* (Phnom Penh: UNDP)

Biddulph, Robin (2004), *Poverty and Social Impact Assessment of Social Land Concessions in Cambodia: Landlessness Assessment* (Phnom Penh: Oxfam GB)

Chan, Sophal and Sarthi Acharya (2002), *Facing the Challenge of Rural Livelihoods: A Perspective from Nine Villages in Cambodia*, Working Paper No. 25 (Phnom Penh: CDRI)

Kang, Chandararot (2002), “The Development of Micro Finance in Cambodia,” *Cambodia Development Review*, Vol. 6, No. 3 (Phnom Penh: CDRI) pp. 1–4.

Kang, Chandararot (forthcoming), *The Enabling Environment for Micro, Small and Medium Enterprises in Cambodia* (Phnom Penh: CDRI)

Murshid, K.A.S. (1998), Food Security in an Asian Transitional Economy: The Cambodian Experience, Working Paper No. 6 (Phnom Penh: CDRI)

NIS (1997), *Socio-Economic Survey of Cambodia 1996: Summary Results*, 2 vols. Phnom Penh; Ministry of Planning.

Padek (forthcoming) Research paper not yet titled, (Phnom Penh: Padek)

Prom, Tola and Bruce McKenney (2003), *Trading Forest Products in Cambodia: Challenges, Threats, and Opportunities for Resin*, Working Paper No. 28, (Phnom Penh: CDRI)

Rao, Jamarvhan and Peter Swift (1998), *Savings, Solidarity, Self-help: Padek’s Experience in Working with Self-help Groups in Cambodia* (Phnom Penh: Padek)

Urashima, Cheryl (2000), *Learning from Integrated Savings and Credit Programmes in Cambodia:*

# ការព្យាយាមស្វែងយល់ពីកិច្ចការពារខាងសង្គមកិច្ចនៅកម្ពុជា[១]

លោក ច័ន្ទ សុផល និងលោក អៀ សុផល បានពិភាក្សាពីបែបបទដែលហានិភ័យ និងភាពងាយរងគ្រោះ ត្រូវបានដោះស្រាយតាមរយៈកិច្ចប្រឹងប្រែងការពារខាងសង្គមកិច្ចនៅកម្ពុជា ។*

កិច្ចការពារខាងសង្គមកិច្ចសំដៅជាសំខាន់ ដល់ប្រព័ន្ធសុវត្ថិភាពជាផ្លូវការ និង/ឬក្រៅផ្លូវការ សំរាប់កាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះ ។ កិច្ចការពារខាងសង្គមកិច្ចអាចរួមបញ្ចូលវិធានការជាច្រើន ដូចជា អន្តរាគមន៍លើទីផ្សារពលកម្ម ការទ្រទ្រង់ប្រាក់ចំណូលតាមមុខសញ្ញា និងការជួយឧត្ថម្ភតាមទំរង់ផ្សេងទៀត ។ វិធានការទាំងនេះជួយដល់បុគ្គល គ្រួសារ និងសហគមន៍ ក្នុងការគ្រប់គ្រងហានិភ័យដែលគំរាមរុញច្រានពួកគេឱ្យធ្លាក់ក្រីក្រតោកយ៉ាកបំផុត ។ រដ្ឋាភិបាលកម្ពុជា អ្នកផ្ដល់ជំនួយ និង NGOs, សុទ្ធតែមានកម្មវិធីសំរាប់ ដោះស្រាយកិច្ចការពារខាងសង្គមកិច្ច ។

## កិច្ចប្រឹងប្រែងការពារខាងសង្គមកិច្ចរបស់រដ្ឋាភិបាល

រដ្ឋធម្មនុញ្ញកម្ពុជាមានមាត្រាចែងពីសិទ្ធិរបស់ប្រជាពលរដ្ឋ និងការទទួលខុសត្រូវរបស់រដ្ឋាភិបាល ។ មាត្រាមួយចំនួនជាប់ទាក់ទងផ្ទាល់នឹងកិច្ចការពារខាងសង្គមកិច្ច ។ ឧទាហរណ៍ មាត្រា៣៦ ចែងថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាពរបស់ខ្លួនតាមសេចក្ដីត្រូវការរបស់សង្គម... ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ចដែលមានចែងក្នុងច្បាប់..." ។ មាត្រា៧២ ចែងថា "សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា... ប្រជារាស្ត្រក្រីក្រ ត្រូវបានទទួលការពិនិត្យរោគដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ ..." ។

រដ្ឋធម្មនុញ្ញ បានកំណត់ឱ្យរដ្ឋាភិបាលអនុវត្តវិធានការការពារខាងសង្គមកិច្ចមួយចំនួនឱ្យដល់ប្រជាជន ។ ទោះបីមានឆន្ទៈល្អយ៉ាងណាក្ដី រដ្ឋាភិបាលមិនទាន់បំពេញបានតាមការតំរូវនៅក្នុងរដ្ឋធម្មនុញ្ញទេ ហើយបរិមាណ និងគុណភាពនៃមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ នៅខ្វះខាតយ៉ាងច្រើន ។

រដ្ឋាភិបាលបានបែងចែកថវិការបស់ខ្លួនមួយចំនួនធំគួរកត់សំគាល់សំរាប់អន្តរាគមន៍ខាងសង្គមកិច្ច ដែលស្ថិតក្នុងជំពូក៣១ នៃថវិកា "អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌" ។ ប្រាក់បែងចែកសំរាប់ឆ្នាំ២០០៣ មាន ៣១លានដុល្លារ ប៉ុន្តែចំណាយជាក់ស្ដែងឡើងដល់ ៣៨លានដុល្លារ ស្មើនឹង ១០%នៃចំណាយចរន្តសរុប ។ យើងគិតថា ជំពូកនេះជាប់ទាក់ទងខ្លាំងជាងគេដល់កិច្ចការពារខាងសង្គមកិច្ច ។ ប៉ុន្តែដូចក្នុងប្រទេសកំពុងអភិវឌ្ឍជាច្រើនទៀតដែរ រដ្ឋាភិបាលបានបង្រួមដែនអន្តរាគមន៍របស់ខ្លួនតែទៅលើវិស័យជាផ្លូវការ ហើយដោយសារកេរ្ដិ៍ដំណែលនៃការអភិវឌ្ឍន៍ដឹកនាំដោយរដ្ឋ រឿងនេះមានន័យថា អ្នកទទួលផលភាគច្រើន គឺជាមន្ត្រីរាជការ និងក្រុមគ្រួសារផ្ទាល់របស់ពួកគេ ។ កម្មវិធីភាគច្រើនដែលសំដៅកាត់បន្ថយភាពងាយរងគ្រោះរបស់ជនក្រីក្រ គឺផ្ដល់ថវិកាដោយជំនួយពីក្រៅប្រទេស ។

នៅឆ្នាំ២០០៣ ក្រសួងសង្គមកិច្ចការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា (ក្រសួងសង្គមកិច្ច)[២] និងក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន (ក្រសួងកិច្ចការនារី) បានទទួល៨លានដុល្លារ និង១៦លានដុល្លាររៀងៗគ្នា ។ ថវិកាភាគច្រើន បានចំណាយលើសោធននិវត្តន៍ ប្រាក់ឧបត្ថម្ភ និងប្រាក់កំរៃ ។ មានធនធានតិចតួចណាស់សំរាប់ចំណាយលើសកម្មភាពជាក់ស្ដែង ដូចជា កម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈជាដើម ។ ក្រសួងឯទៀត ក៏មានប្រាក់វិភាជន៍ ជំពូក៣១នេះដែរ ប៉ុន្តែវាមានទឹកប្រាក់មិនច្រើនទេ និងសំរាប់ដោះស្រាយចំណាយខាងសង្គមកិច្ច និងប្រាក់ឧបត្ថម្ភផ្សេងៗ ។ ឧទាហរណ៍ ព្រះបរមរាជវាំង ទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋសភា និងព្រឹទ្ធសភា មានប្រាក់វិភាជន៍ច្រើនក្នុងជំពូក៣១ ។ ចំណាយរបស់ស្ថាប័នទាំងនេះ អាចមានច្រើនគួរសមក្នុងទ្រង់ទ្រាយជាការផ្ដល់អំណោយ[៣] ដល់ជនក្រីក្រ និងជនរងគ្រោះដោយគ្រោះធម្មជាតិ ។

## សោធននិវត្តន៍សំរាប់មន្ត្រីរាជការ

សោធននិវត្តន៍គួរតែពិនិត្យឱ្យបានដិតដល់ ពីព្រោះវាជាទ្រង់ទ្រាយមួយនៃវិធានការការពារខាងសង្គមកិច្ចជាផ្លូវការ ដែលងាយសំគាល់ឃើញជាងគេ ។ មានការបែងចែកការទទួលខុសត្រូវខាងរដ្ឋបាល សំរាប់សោធននិវត្តន៍របស់អតីតយុទ្ធជន (ដែលស្ថិតនៅក្រោមនាយកដ្ឋានសោធននិវត្តន៍អតីតយុទ្ធជននៃក្រសួងកិច្ចការនារី) និងរបស់មន្ត្រីរាជការ (ដែលស្ថិតនៅក្រោមនាយកដ្ឋានសោធននិវត្តន៍ នៃក្រសួងសង្គមកិច្ច) ។

យោងតាមក្រសួងសង្គមកិច្ច មានមន្ត្រីរាជការចូលនិវត្តន៍ប្រមាណ ២២.០០០នាក់ (ក្នុងនេះមានទាំងជនពិការផង) ដែលទទួលបានជាមធ្យម ៧០.០០០រៀល (១៧,៥០ដុល្លារ)/ខែ ប៉ុន្តែមានអ្នកទទួលបានតិចត្រឹមតែ ២៧.០០០រៀល/ខែ ។តួលេខទាំងនេះស្មើនឹងកំរិតមធ្យមត្រឹម ០,៥៨ដុល្លារ/នាក់/ថ្ងៃ និងកំរិតអប្បបរិមា ០,២២ដុល្លារ/នាក់/ថ្ងៃ, ដោយសន្មតថា ទឹកប្រាក់ពេញត្រូវបានបើកផ្ដល់ជាក់ស្ដែង ។ ក្នុងករណីស្លាប់ អ្នកក្នុងបន្ទុករបស់មន្ត្រីនោះទទួលបានពី ៨ ទៅ ១០ខែនៃបៀវត្សរ៍របស់សាមីជនយោងទៅតាមរយៈពេលបានធ្វើការបំរើរដ្ឋ ។ បន្ថែមលើនេះទៀត កូនរបស់អ្នកស្លាប់ត្រូវបានផ្ដល់ឱ្យពី ៣.១០០រៀល ដល់ ៤.០០០រៀល (០,៨០-១,០០ដុល្លារ)/ខែ (ទឹកប្រាក់តិចគឺសំរាប់ ការស្លាប់មិនជាប់ទាក់ទងនឹងការងារ) រហូតដល់ពេលពេញវ័យ ឬក៏យូរជាងនេះទៀត ក្នុងករណីមានសេចក្ដីបញ្ជាក់ថាកំពុងបន្តការសិក្សា ។ ប្រពន្ធឬប្ដី បន្តទទួលបានប្រហែល ៤.០០០រៀល (១,០០ដុល្លារ)/ខែ ។ យោងតាមបន្ទាត់ក្រីក្រនៅកម្ពុជាស្មើនឹង ០,៥០ដុល្លារ/នាក់/ថ្ងៃ (ផ្អែកលើកំរិត ២.១០០កាឡូរី/ថ្ងៃ), ប្រាក់ផ្ដល់នេះ ពិតជាមិនគ្រប់គ្រាន់ទេ ។

កំណែទំរង់សោធននិវត្តន៍ បានលើកមកពិចារណាអស់មួយរយៈហើយ ពីព្រោះគេទទួលស្គាល់ជាទូទៅថា ប្រព័ន្ធសោធននិវត្តន៍បច្ចុប្បន្នដែលផ្អែកទាំងស្រុងលើការទទួលខុសត្រូវខាងរដ្ឋបាលរបស់រដ្ឋាភិបាល គឺគ្មានចីរភាពទេ ។ សំណើថ្មីគឺត្រូវផ្ទេរភារកិច្ចនេះទៅឱ្យស្ថាប័នផ្សេងទៀត ឬក្រុមហ៊ុនធានារ៉ាប់រងសុខភាពឯកជន ប៉ុន្តែរឿងនេះប្រហែលជាពុំមានជោគជ័យទេ បើសិនគ្មានធ្វើកំណែទំរង់ជាមុននូវប្រាក់បំណាច់ (compensation) របស់មន្ត្រីរាជការស៊ីវិល ។ ដោយសារបៀវត្សរ៍ដ៏ទាបរបស់មន្ត្រីរាជការស៊ីវិលមួយចំនួន (ទាបជាងទាំងកម្មកររោងចក្រកាត់ដេរ ដែលមានបៀវត្សរ៍អប្បបរមាតាមច្បាប់ ៤៥ដុល្លារ/ខែ) ការយកពេលទៅធ្វើការខាងក្រៅ និងការបង់ប្រាក់

* លោក ច័ន្ទ សុផល ជាអតីតអ្នកស្រាវជ្រាវនៅ វបសអ ឯលោក អៀ សុផល គឺជាបេក្ខជនថ្នាក់បណ្ឌិតនៅ University of California, Berkeley, and Center for Khmer Studies Fellow, e-mail: sophal@alumni.princeton.edu ។

**ចំណាយចរន្តលំអិតតាមជំពូក**

| ជំពូក | ច្បាប់ថវិកា ២០០៣ (លានដុល្លារ) | ចំណាយពិត ២០០៣ (លានដុល្លារ) | ចំណាយពិត២០០៣ (ចំណែកជា%) |
|---|---|---|---|
| ចំណាយចរន្តសរុប | | 442 | 100% |
| ជំពូក១០: បៀវត្សរ៍ | 155 | 147 | 39% |
| ជំពូក១១: ចំណាយប្រតិបត្តិការ | 145 | 114 | 30% |
| ជំពូក១២: ឧបត្ថម្ភធន ផ្តល់ឱ្យខេត្ត-ក្រុង | 26 | 25 | 7% |
| ជំពូក១៣: សកម្មភាពនៃកម្មវិធី ជាក់លាក់នានា (PAP) | 40 | 25 | 7% |
| ជំពូក២០: ការប្រាក់លើកំចី | 7 | 8 | 2% |
| ជំពូក៣០: អន្តរាគមន៏ក្នុង វិស័យសេដ្ឋកិច្ច | 8 | 14 | 4% |
| ជំពូក៣១: អន្តរាគមន៏ក្នុង វិស័យសង្គមកិច្ច | 31 | 38 | 10% |
| ជំពូក៣២: អន្តរាគមន៏ក្នុងវិស័យអន្តរជាតិៈ វិភាគទានឱ្យអង្គការអន្តរជាតិ | 2 | 2 | 0% |
| ជំពូក៤០: ចំណាយផ្សេងៗ | 24 | 4 | 1% |
| ជំពូក៤១: ចំនាយមិនបានគ្រោងទុក | 3 | - | - |

*ប្រភព: ការអនុវត្តន៏ថវិកាឆ្នាំ២០០៣, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ក្រៅផ្លូវការ គឺឃើញមានយ៉ាងច្រើន[៤] ។ កំណែទំរង់ប្រាក់បំណាច់របស់មន្ត្រីរាជការស៊ីវិល គឺជាសមាសធាតុមួយដ៏សំខាន់ ក្នុង ៧៣ចំណុចបានព្រមព្រៀងគ្នានៅក្នុងការចរចា ដែលបាននាំទៅដល់ការបង្កើតរដ្ឋាភិបាលបច្ចុប្បន្ន ប៉ុន្តែហាក់ដូចមានសញ្ញារីកចំរើនតិចតួចណាស់ក្នុងរឿងនេះ ។

## ការបណ្តុះបណ្តាលវិជ្ជាជីវៈ

ការបណ្តុះបណ្តាលវិជ្ជាជីវៈ ជាអន្តរាគមន៏ដ៏សំខាន់បំផុតទៅក្នុងទីផ្សារពលកម្ម និងជាចំណែកដ៏ចំបងមួយនៃកិច្ចការពារខាងសង្គមកិច្ច ។ មានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈពីរកន្លែងនៅភ្នំពេញ គឺមួយកន្លែងបានទទួលការទ្រទ្រង់ពីថៃ និងមួយកន្លែងទៀតឧបត្ថម្ភដោយកូរ៉េ, និងមានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈតូចៗ ៥កន្លែងទៀតនៅ ៥ខេត្តគឺ កំពត កោះកុង សៀមរាប កំពង់ធំ និងពោធិសាត់ ដែលកាលពីមុនស្ថិតនៅក្រោមក្រសួងសង្គមកិច្ច ។ មជ្ឈមណ្ឌលនៅតាមខេត្តទើបកើតមានក្នុង ២-៥ឆ្នាំនេះ និងមានទំហំតូច អាចទទួលសិស្សបានពី ១៥-២០នាក់ ឱ្យសិក្សាលើមុខជំនាញមួយចំនួនតូច ។ មជ្ឈមណ្ឌលទទួលបានការឧបត្ថម្ភគាំទ្រមានកំរិតពីអ្នកផ្តល់ជំនួយ និង NGOs ហើយ-តាមធម្មតាតែងមានគោលដៅផ្តោតសកម្ម- ភាពទៅលើអ្នកទទួលផល ឬក៏មុខជំនាញដ៏ជាក់លាក់មួយចំនួនប៉ុណ្ណោះ ។

គេមើលឃើញជាមុនថា បណ្តាមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈរបស់រដ្ឋនឹងត្រូវកែប្រែឱ្យទៅជាស្ថាប័នសាធារណៈ ដែលមានសិទ្ធិអំណាចយកកំរៃជាផ្លូវការ (នាបច្ចុប្បន្ន កំរៃក្រៅផ្លូវការអាចមានយក ឬក៏ពុំមានយកទេ) ដើម្បីដោះស្រាយកង្វះខាតថវិកា នឹងចីរភាពហិរញ្ញវត្ថុ ។ គេអាចជជែកវែកញែកថា នេះជាវិធីដ៏មានប្រសិទ្ធភាពសំរាប់គ្រប់គ្រងស្ថាប័ន ប៉ុន្តែមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈរដ្ឋ-ឯកជនបែបនេះ អាចមិនខុសគ្នាអ្វីពីមជ្ឈមណ្ឌលឯកជនសុទ្ធសាធនោះទេ ។ ដោយឡែក អ្នកក្រ និងជនងាយរងគ្រោះមុខជាត្រូវផាត់ចេញ លើកលែងតែមជ្ឈមណ្ឌលមានកំណត់ជាក់លាក់ យកពួកគេជាគោលដៅ ឬជួយចេញថ្លៃសិក្សាឱ្យពួកគេ ដោយប្រើប្រាស់ប្រាក់កំរៃប្រមូលបានពីសិស្សដែលមានលទ្ធភាពបង់ថ្លៃសិក្សា ។

## កិច្ចការអតីតយុទ្ធជន

សង្គ្រាមច្រើនទសវត្សរ៍ បានបន្សល់ទុកឱ្យប្រទេសកម្ពុជានូវទាហានស្លាប់ និងពិការរាប់ម៉ឺននាក់ ។ យោងតាមនាយកដ្ឋានកិច្ចការអតីតយុទ្ធជន រដ្ឋាភិបាលបានទទួលខុសត្រូវជួយឧបត្ថម្ភតាមការផ្តល់ប្រាក់ប្រចាំខែដល់ (១) មនុស្សក្នុងបន្ទុក ២៩៣.៥០០នាក់ (ស្ថិតក្នុងប្រភេទ ប្តី/ប្រពន្ធ, កូន និងឪពុកម្តាយ) នៃទាហាន និងប៉ូលីសដែលស្លាប់ (២) ទាហាន និងប៉ូលីសពិការ ៣១.៥០០នាក់ បូកនឹង ប្តី/ប្រពន្ធ និងកូនរបស់ពួកគេ ១៦០.១៨៣នាក់ (៣) ទាហាន និងប៉ូលីសចូលនិវត្តន៏ ៤.៧១២នាក់ និងប្តី/ប្រពន្ធ និងកូន ១៦.៤៦៥នាក់ទៀត (៤) ១.១៩៥ទាហានបាត់បង់សមត្ថភាពធ្វើការ ប្តី/ប្រពន្ធ និងកូនពួកគេចំនួន៣.៦៩៧នាក់ ។ សរុបមកមានមនុស្ស ៤៧១.២៥២នាក់ ។

ចំណាយសរុបលើប្រាក់ឧបត្ថម្ភនេះគឺ ១៣,៧លានដុល្លារសំរាប់ឆ្នាំ២០០៣ ឬជាមធ្យម ២៩ដុល្លារ/នាក់/ឆ្នាំ ។ ចំនាយសរុបគឺជាបន្ទុកមួយធំគួរសមសំរាប់រដ្ឋាភិបាល ប៉ុន្តែចំពោះគ្រួសារនីមួយៗ ប្រាក់ឧបត្ថម្ភនេះវាតិចតួចណាស់ មិនអាចទាំងទ្រទ្រង់ជីវភាពក្នុងកំរិតអប្បបរមាមួយបានផង ជាពិសេសសំរាប់អ្នកនៅក្នុងបន្ទុករបស់ទាហានស្លាប់ ។ ប្តី/ប្រពន្ធ ឬឪពុកម្តាយរបស់ទាហាន ស្លាប់ទទួលបានប្រាក់ឧបត្ថម្ភ ៣.២០០រៀល(០,៨០ដុល្លារ)/ខែ រីឯកូនក្រោមអាយុ១៨ឆ្នាំ (ឬកូនពេញវ័យ បើសិនមានលិខិតបញ្ជាក់ថា កំពុងសិក្សា) រដ្ឋផ្តល់ឱ្យ៤.០០០រៀល(១ដុល្លារ)/១ខែ (ប្រាក់ឧបត្ថម្ភសំរាប់អ្នកនៅក្នុងបន្ទុកមិនបានកើនទេ តាំងពីពេលគេកំនត់វាឡើងក្នុងទសវត្សរ៏១៩៨០មក) ។ គួររំលឹកទៀតថា ប្រាក់ឧបត្ថម្ភនេះទាបខ្លាំងណាស់ បើធៀបនឹងបន្ទាត់ក្រីក្ររបស់កម្ពុជា (០,៥០ដុល្លារ/ថ្ងៃ) ហើយទោះបីរដ្ឋបើកផ្តល់វាបានពេញលេញត្រឹមត្រូវក៏ដោយ ក៏វាអាចបំពេញតំរូវការកាឡូរីជាអប្បបរមារបស់អ្នកក្នុងបន្ទុក (២.១០០កាឡូរី/នាក់) បានតែមួយឬពីរថ្ងៃប៉ុណ្ណោះ ។ ជាការពិតណាស់ ដោយសារមូលហេតុជាច្រើន ជាពិសេសការបង់ប្រាក់ក្រៅផ្លូវការ និងការធ្លាយបាត់ប្រាក់ផ្សេងៗ អ្នកទទួលផលគឺទទួលបានតែប្រហែល ៥០% នៃតួលេខចារឹកនៃប្រាក់ឧបត្ថម្ភប្រចាំខែរបស់ខ្លួនប៉ុណ្ណោះ ។

## សេវាសុខាភិបាលសាធារណៈសំរាប់ជនក្រីក្រ

នៅកម្ពុជា ចំណាយលើសុខភាពមានចំណែកធំគួរកត់សំគាល់នៅក្នុងចំណាយសរុបរបស់គ្រួសារនីមួយៗ និងតំណាងឱ្យ ៧៥-៨៥%នៃថវិកាសរុបខាងសុខាភិបាល (២០-៣០ដុល្លារ/នាក់/ឆ្នាំ)។ ដោយទទួលសំពាធពីសហគមន៏អ្នកផ្តល់ជំនួយ និងដោយបានទទួលស្គាល់ពីកង្វះខាតធ្ងន់ធ្ងរក្នុងការផ្តល់សេវាថែទាំសុខភាពសាធារណៈ រដ្ឋាភិបាលក្នុងប៉ុន្មានឆ្នាំចុងក្រោយបានបង្កើនគួរកត់សំគាល់នូវថវិកាបែងចែកទៅខាងសុខាភិបាល។ ប៉ុន្តែ នៅមានបញ្ហាចោទច្រើននៅឡើយ មួយចំណែក គឺដោយសារចំណាយជាក់ស្តែងតែងតែតិចជាងចំនួនកំណត់ក្នុងគំរោងថវិកា ។ ជាលទ្ធផល ចំណាយចេញពីហោប៉ៅផ្ទាល់ខ្លួននៅតែមានកំរិតខ្ពស់ ជាពិសេសសំរាប់អ្នកក្រ ។

គំរោងពីរដែលជាប់ទាក់ទងផ្ទាល់នឹងកិច្ចការពារខាងសង្គមកិច្ច បានដំណើរការខ្លះហើយ នោះគឺការធានារ៉ាប់រងសុខភាពសង្គម និងមូលនិធិសមធម៌ (Equity Funds) ដែលក្រសួងសុខាភិបាលបានបង្កើតឡើងនាពេល

ថ្មីៗនេះ ។ ការធានារ៉ាប់រងសុខភាពសង្គម មានគោលដៅធានានូវគ្រោះថ្នាក់លើ សុខភាពរបស់ប្រជាជនកម្ពុជា ហើយមូលនិធិសមធម៌ ត្រូវបានរចនារៀបចំ សំរាប់ជួយដល់អ្នកក្រីក្របំផុត តាមរយៈការប្រមូលផ្តុំប្រាក់ទទួលពីរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ សំរាប់ដោះស្រាយចំណាយថែទាំសុខភាព ។

ជាការប្រសើរបំផុត បើសិនអាចតំរូវឱ្យដាក់អនុវត្តបាននូវគំរោងធានារ៉ាប់រងសុខភាពសង្គម សំរាប់មន្ត្រីរាជការស៊ីវិល និងកម្មកររោងចក្រ (ក្នុងពេលនេះ វាត្រូវផ្តោតជាសំខាន់ទៅលើកម្មកររោងចក្រកាត់ដេរ) ប៉ុន្តែ ចំពោះមន្ត្រីរាជការស៊ីវិល រឿងនេះតំរូវឱ្យរដ្ឋាភិបាលតំលើងប្រាក់បៀវត្សរ៍ដោយផ្អែកលើខ្នាតប្រៀបធៀបទីផ្សារ និងការវិភាគពីមុខងារ (ការកសាងឯកសារពិពណ៌នាការងារជាក់ស្តែង) ។ កំណែទំរង់រដ្ឋបាលស៊ីវិល គឺជាលក្ខខណ្ឌចាំបាច់ដូចបានលើករួចហើយ ។ ចំពោះកម្មកររោងចក្រវិញ ទាំងថ្នាក់ដឹកនាំ និងកម្មករ គួរតែចូលរួមនៅក្នុងគំរោង ។ នាបច្ចុប្បន្ន គ្មានការធានារ៉ាប់រងសុខភាពបែបនេះទេ សំរាប់មន្ត្រីរាជការស៊ីវិលធម្មតា និងបុគ្គលិកផ្នែកឯកជនពីព្រោះច្បាប់ស្តីពីគំរោងសន្តិសុខសង្គម សំរាប់បុគ្គលដែលកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់ការងារ គឺមិនទាន់បានអនុវត្តនៅឡើយទេ ។

ដើម្បីបំរើដល់អ្នកក្រីក្រណាស់ ក្រសួងសុខាភិបាលបានបង្កើតមូលនិធិសមធម៌ ដែលមានថវិកាសរុប ២០លានដុល្លារសំរាប់រយៈពេលបីឆ្នាំដំបូង (២០០៣-២០០៥) ប៉ុន្តែមកទល់សព្វថ្ងៃ ផែនការរដ្ឋសំរាប់មូលនិធិនេះ មិនទាន់អនុវត្តបានមួយចំណែកណាទេ ។ ជោគជ័យនៃមូលនិធិសមធម៌ គឺត្រូវពឹងផ្អែកលើរឿងថាតើ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព នឹងអាចផ្តល់សេវាបានសក្តិសិទ្ធិប៉ុណ្ណា ខណៈដែលប្រាក់បៀវត្សរ៍ និងប្រាក់លើកទឹកចិត្តសំរាប់បុគ្គលិកនៅខ្វះខាតច្រើនបែបនេះ ។

## កិច្ចការពារខាងសង្គមកិច្ចដោយអ្នកផ្តល់ជំនួយ និង NGOs

ក្នុងលក្ខណៈជាប្រទេសពឹងផ្អែកលើជំនួយ កម្ពុជាទទួលបានជំនួយបរទេសមានទំហំប្រហែល ៤០% នៃចំណាយថវិកាសរុបរបស់ខ្លួន។ ខណៈដែលចំណាយចរន្តមិនទាន់លើសពី ៤០០លានដុល្លារនៅឡើយ, ជំនួយបរទេស *សរុប* ប្រចាំឆ្នាំមានប្រហែល ៥០០លានដុល្លារ ក្នុងនេះប្រហែល ៤០លានដុល្លារផ្តល់ដោយ NGOs ។ ដោយកម្ពុជាមានប្រជាជន ៣៦% ស្ថិតក្រោមបន្ទាត់ក្រីក្រ ប្រទេសអ្នកផ្តល់ជំនួយ និង NGOs បានប្រឹងប្រែងជួយបំពេញនូវចន្លោះខ្វះខាតនៃកម្មវិធីកាត់បន្ថយភាពក្រីក្រ ដែលភាគច្រើនសំដៅដោះស្រាយដោយផ្ទាល់នូវតំរូវការរបស់អ្នកក្រីក្រណាស់ ក្រុមចាញ់ប្រៀបគេ និងក្រុមងាយរងគ្រោះ។

បញ្ហាមួយចំនួនដូចជា លក្ខណៈត្រៀមទប់ទល់នឹងគ្រោះមហន្តរាយ ជំនួយមនុស្សធម៌ និងជំនួយសង្គ្រោះបន្ទាន់ វាស្ថិតទាំងស្រុងក្នុងកិច្ចការពារខាងសង្គមកិច្ច ។ វិស័យផ្សេងទៀតដែលជាប់ទាក់ទងនឹងកិច្ចការពារខាងសង្គមកិច្ច មានជាអាទិ៍ កសិកម្ម ធនធានធម្មជាតិ ការអប់រំ សុខាភិបាល និងការអភិវឌ្ឍន៍សង្គម ពីព្រោះវិស័យទាំងនេះសំដៅជាសំខាន់ ជួយទ្រទ្រង់ ឬការពារជនក្រីក្រ កុំឱ្យធ្លាក់ទៅក្នុងភាពក្រីក្របំផុត ។

នៅឆ្នាំ១៩៩៣ ជំនួយមនុស្សធម៌ និងសង្គ្រោះបន្ទាន់ មានជិតដល់ ១៧% នៃជំនួយអភិវឌ្ឍន៍សរុប ហើយពីឆ្នាំ១៩៩៤ ដល់១៩៩៨ វាធ្លាក់ចុះគួរកត់សំគាល់ដល់កំរិតជាមធ្យម ៥,២% នៅពេលប្រទេសកម្ពុជាឈានពីការស្តារ និងកសាងទៅដល់ការអភិវឌ្ឍន៍ ។ ប៉ុន្តែជំនួយមនុស្សធម៌ និងសង្គ្រោះបន្ទាន់ស្ទុះឡើងវិញដល់ជិត ១២% ជាមធ្យមនៃជំនួយអភិវឌ្ឍន៍ប្រចាំឆ្នាំចាប់ពីឆ្នាំ ១៩៩៩ដល់២០០២ ដោយសារមានគ្រោះរាំងស្ងួតនិងទឹកជំនន់យ៉ាងធ្ងន់ធ្ងរ ។

ជារួម ក្នុងឆ្នាំ២០០១ (ឆ្នាំមានទិន្នន័យថ្មីបំផុត) ប្រហែល២៣%នៃជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេសសរុប ឬជិត១១០លានដុល្លារ ត្រូវបានប្រើក្នុងកិច្ចការពារខាងសង្គមកិច្ច គឺវាច្រើនឆ្ងាយណាស់ជាងចំណាយរបស់រដ្ឋាភិបាលសំរាប់កិច្ចការនេះដែលមានត្រឹមតែ ៣៨លានដុល្លារនៅឆ្នាំ២០០៣ ។

## ភាពសក្តិសិទ្ធិនៃអន្តរាគមន៍ពីខាងក្រៅលើកិច្ចការពារខាងសង្គមកិច្ច

កម្មវិធីទាំង ៥០០ របស់ NGOs និងអ្នកផ្តល់ជំនួយ (របាយការណ៍ខ្លះថាមានដល់១០០០) គឺច្រើនហួសពេក ដើម្បីអាចបង្ហាញច្បាស់ថា អន្តរាគមន៍បែបណាលើកិច្ចការពារខាងសង្គមកិច្ចនៅកម្ពុជាដែលបានជោគជ័យ ឬបរាជ័យ ។ ដូច្នេះហើយក៏បានជ្រើសយកវិស័យ និង NGOs សំខាន់ៗមកជំនួស ឱ្យកម្មវិធីទាំងនេះវិញ ដើម្បីបង្ហាញពីភាពសក្តិសិទ្ធិនៃអន្តរាគមន៍ ។

## ជំនួយឧបត្ថម្ភដល់ស្ត្រី និងកុមារ

ជំនួយឧបត្ថម្ភដល់ស្ត្រី និងកុមារ គឺជាផ្នែកមួយទៀតនៃកិច្ចការពារខាងសង្គមកិច្ច ដែលអ្នកផ្តល់ជំនួយ និង NGOs បានធ្វើសកម្មភាព។ ដោយសារហេតុផលជាច្រើនខាងសង្គមកិច្ច និងវប្បធម៌ ស្ត្រី ជាពិសេសស្ត្រីមេគ្រួសារ ឬស្ត្រីមេម៉ាយ គឺងាយរងគ្រោះជាងបុរស។ កុមារត្រូវគេបោះបង់ចោល ឬកុមារកំព្រា ដែលចុងក្រោយក្លាយជាក្មេងអនាថា មានលទ្ធភាពរីតតែតិចតួចថែមទៀតដើម្បីបានរួចរស់ជីវិត ។ ការងាររបស់ UNICEF និង NGOs (ឧ. អង្គការមិត្តសំលាញ់ និងសប្បុរស) បានជួយយ៉ាងច្រើន ក្នុងការបង្ហាញពីស្ថានភាពរបស់ស្ត្រីនិងកុមារ និងពីភាពសក្តិសិទ្ធិនៃកម្មវិធីការពារខាងសង្គមកិច្ចនាពេលថ្មីៗ ។

UNICEF ជាអង្គការមួយសកម្មក្នុងការបង្កើតគោលនយោបាយ ព្រមទាំង ជួយគាំទ្រដល់ស្ថាប័នឯទៀតក្នុងការអនុវត្តន៍គោលនយោបាយទាំងនោះ ។ វិស័យដែល UNICEF បានធ្វើអន្តរាគមន៍នៅកម្ពុជារួមមាន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្សេងៗក្នុងសង្គម ការជួញដូរកុមារ ក្មេងអនាថា និង ចរិយារបស់ក្មេងដែលប្រឈមគ្រោះថ្នាក់ (ការប្រើគ្រឿងញៀន កាំភ្លើង ជំងឺអេដស៍) ។ UNICEF បានជួយកសាងសមត្ថភាពផងដែរ ឱ្យដល់បុគ្គលិក របស់ក្រសួងសង្គមកិច្ច ។ ស្របគ្នានេះ UNICEF ក៏មានកម្មវិធីមួយចំនួន សំរាប់ជួយដល់ស្ត្រី និងកុមារ-ក្រីក្រ តាមរយៈរដ្ឋាភិបាល និង NGOs ។

អង្គការមិត្តសំលាញ់ ដែលកកើតឡើងនៅឆ្នាំ១៩៩៤ ជា NGO សំរាប់ជួយដល់ក្មេងអនាថារស់នៅតាមចិញ្ចើមថ្នល់ ហើយបច្ចុប្បន្នមាន ១៣ កម្មវិធីកំពុងដំណើរការនៅភ្នំពេញ និងខេត្តកណ្តាល ។ ដោយមានក្រសួងសង្គមកិច្ចជាដៃគូជាផ្លូវការ អង្គការមិត្តសំលាញ់បានទទួលជោគជ័យធំធេងក្នុងការអប់រំក្មេងអនាថាយ៉ាងច្រើន និងរៀបចំឱ្យពួកគេបានចូលទៅរួមរស់ក្នុងសង្គម សាលារៀន និងគ្រួសារវិញ។ អង្គការបានជួយអភិវឌ្ឍន៍ជំនាញអាជីពឱ្យក្មេងអនាថា និងណែនាំឳពុកម្តាយក្មេងឱ្យយល់ដឹងកាន់តែប្រសើរឡើងពីផែនការគ្រួសារ និងការអភិវឌ្ឍន៍សហគមន៍ ។

អង្គការសប្បុរស ជាឧទាហរណ៍មួយបង្ហាញពីរបៀបដែល NGO អាចចូលរួមផ្តល់កិច្ចការពារខាងសង្គមកិច្ចដល់អ្នកក្រីក្រណាស់ ។ អង្គការ NGO ក្នុងស្រុកនេះ កកើតឡើងនៅឆ្នាំ១៩៩៣ ដោយមានទីតាំងនៅខេត្តបាត់ដំបងនឹងមានគោលដៅចំបងជួយការពារស្ត្រីក្រីក្រ ដែលមានជីវភាពមិនមាំទាំ កុំឱ្យក្លាយជាស្ត្រីរកស៊ីផ្លូវភេទ ។ ក្នុង ៥គំរោងរបស់អង្គការសប្បុរសដែលសុទ្ធតែជាប់ទាក់ទងនឹងកិច្ចការពារខាងសង្គមកិច្ច អ្នកទទួលផលជាគោលដៅ គឺជនក្រីក្របំផុតនៅក្នុងសហគមន៍ ។ គំរោងបានជួយដោះស្រាយកន្លែងមើលក្មេងនៅពេលថ្ងៃ ការអភិវឌ្ឍន៍ជនបទ ការបណ្តុះបណ្តាលវិជ្ជាជីវៈ រោងជាង

កាត់ដេរសហគមន៍ និងមីក្រូឥណទាន ។

គំរោងបណ្ដុះបណ្ដាលវិជ្ជាជីវៈរបស់អង្គការសប្បុរស មានលក្ខណៈខុសប្លែកពីគេនៅកម្ពុជា ហើយជាគោលគំនិតពីដំបូងដែលនាំឱ្យមានការបង្កើតអង្គការនេះ ។ ចាប់ពីឆ្នាំ១៩៩៣ មក អង្គការបានបណ្ដុះបណ្ដាល "ស្ត្រីក្រីក្រណាស់" មានអាយុពី ១៦-៣០ឆ្នាំ ជាង ៨០០នាក់លើមុខជំនាញបី គឺកាត់ដេរ ជំនាញកែសម្ផស្ស និងធ្វើនំ ។ ស្ត្រីទាំងនេះ ត្រូវបានជ្រើសយកពី ១២ខេត្ត តាមរយៈ NGOs ដែលធ្វើសកម្មភាពតាមមូលដ្ឋាន។ ក្រោយពីការបណ្ដុះបណ្ដាលអស់រយៈពេល ៩ខែ អង្គការសប្បុរស ផ្ដល់កំចី ១០០ដុល្លារទៅឱ្យស្ត្រីសិក្ខាកាម ដើម្បីចាប់ផ្ដើមមុខរបរផ្ទាល់ខ្លួនតូចមួយ ហើយអង្គការសប្បុរសនៅឃ្លាំមើលការងាររបស់ពួកគេជាបន្តទៀត ។

## ការអភិវឌ្ឍន៍សហគមន៍គ្រប់ជ្រុងជ្រោយ

អង្គការលូថេរ៉ានបំរើពិភពលោក (LWS) បានមកដល់កម្ពុជានៅឆ្នាំ១៩៧៩ ។ លក្ខណៈពិសេសរបស់ LWF គឺលទ្ធភាពផ្ដោតសកម្មភាពលើសហគមន៍ឆ្ងាយដាច់ស្រយាល ។ នៅឆ្នាំ២០០២ អង្គការបានជួយដល់ប្រជាជន ៣៧.២៥០គ្រួសារ ឬ ១៧៩.៤៨៣នាក់ដែលរស់នៅក្នុង ៣១១ ភូមិ ។ នៅឆ្នាំ២០០៣ ចំនួនអ្នកទទួលផលកើនដល់ ៣៣១.១៩៥នាក់ ។

សំរាប់ LWF បញ្ហាចោទមិនចេះចប់ គឺការថ្លឹងថ្លែងឱ្យបានត្រឹមត្រូវរវាងវិធីសាស្ត្រផ្ដោតលើដំណើរការ និងវិធីសាស្ត្រផ្ដោតលើលទ្ធផល ។ បច្ចុប្បន្ន អង្គការមាននិន្នាការខិតទៅខាងលទ្ធផល ដោយធ្វើការអភិវឌ្ឍន៍ព្រមគ្នាផងដែរនូវវិធីសាស្ត្រផ្អែកលើសិទ្ធិ ។

## សេចក្ដីសន្និដ្ឋាន

នៅកម្ពុជា ភាពក្រីក្រគឺធ្ងន់ធ្ងរជាងកង្វះខាតសិទ្ធិអំណាចខាងសេដ្ឋកិច្ចទៅទៀត ។ វាជាប់ទាក់ទងយ៉ាងច្រើនទៅនឹងភាពងាយរងគ្រោះ ពិការភាព និងភាពអស់សង្ឃឹមដែលបង្កដោយសង្គ្រាមស៊ីវិលរ៉ាំរ៉ៃ និងបរាជ័យរបស់រដ្ឋដែលអូសបន្លាយអស់រយៈបីទសវត្សរ៍ ។ ពិតហើយ វិស័យជាផ្លូវការមានទ្រង់ទ្រាយតូច ខណៈដែលតំរូវការជំនួយទ្រទ្រង់ខាងសង្គមកិច្ចមានកំរិតខ្ពស់ខ្លាំង វាធ្វើឱ្យមានការពឹងផ្អែកកាន់តែច្រើន ទៅលើជំនួយបរទេស និងប្រព័ន្ធសុវត្ថិភាពក្រៅផ្លូវការ ជាជាងទៅលើធនធានរបស់ជាតិសំរាប់កិច្ចការពារខាងសង្គមកិច្ច ។

ការធានារ៉ាប់រងជាផ្លូវការនៅកម្ពុជា មានលក្ខណៈក្មេងខ្ចីនៅឡើយ ។ មានមនុស្សតិចណាស់ដែលរកចំណូលបានគ្រប់គ្រាន់ អាចទិញការធានារ៉ាប់រងដោយស្ម័គ្រចិត្តបាន។ ទោះយ៉ាងនេះក្ដី កន្លងមកមានការចាត់វិធានការមួយចំនួនដើម្បីអនុម័តចេញនូវច្បាប់ធានារ៉ាប់រង និងសេចក្ដីព្រាងអនុក្រឹត្យនានាសំដៅបង្កើតក្របខ័ណ្ឌច្បាប់ដ៏សមស្របមួយ ។ មានការពិចារណាផងដែរពីគោលនយោបាយផ្សេងៗ ដើម្បីទទួលបាន គំរោង ប្រាក់ឧបត្ថម្ភ និងស្ថាប័នផ្ដល់ការធានារ៉ាប់រងដែលមានចីរភាព ។ ជោគជ័យនៃគំនិតផ្ដួចផ្ដើមនេះ ពឹងផ្អែកយ៉ាងខ្លាំងទៅលើកត្តាមួយចំនួន ជាអាទិ៍ អភិបាលកិច្ចល្អ និងជាពិសេសប្រព័ន្ធប្រាក់បៀវត្សរ៍ និងគ្រឿងលើកទឹកចិត្តដ៏សមស្រប (កំណែទំរង់រដ្ឋបាលស៊ីវិល) ។ ទាំងអស់នេះ គឺជាការពិចារណាថ្លឹងថ្លែងខាងសេដ្ឋកិច្ច នយោបាយដែលស្ថិតនៅក្រោមសំពាធខាងសង្គមកិច្ច និងប្រវត្តិសាស្ត្រ (ទំនាក់ទំនងអ្នកឧបត្ថម្ភ-អ្នកទទួលផល និងបណ្ដាញក្រៅផ្លូវការ) ។

មូលនិធិយ៉ាងច្រើនរបស់អ្នកផ្ដល់ជំនួយ និង NGOsបានផ្ទេរទៅឱ្យកម្មវិធីផ្សេងៗដែលផ្ដល់កិច្ចការពារខាងសង្គមកិច្ច ជាចំណែកមួយនៃជំនួយបរទេសដែលបានជួយបំពេញចន្លោះខ្វះខាតរបស់រដ្ឋាភិបាល ។ និយាយជារួម ជិតប្រហែលពាក់កណ្ដាលនៃប្រាក់សរុប ៥០០លានដុល្លារដែលទទួលបានពីអ្នកផ្ដល់ជំនួយនិង NGOs អាចចាត់ទុកថា ត្រូវបានប្រើប្រាស់ពាក់ព័ន្ធនឹងកិច្ចការពារខាងសង្គមកិច្ច ដោយក្នុងនេះមានបូកទាំងចំណាយគ្រប់គ្រង និងចំណាយដឹកជញ្ជូន និងប្រគល់/ទទួលផង ហើយតួលេខនេះវាខ្ពស់ឆ្ងាយណាស់ ជាងប្រាក់ ៣៨លានដុល្លារដែលរដ្ឋាភិបាលបានបើកផ្ដល់ ។ NGOsហាក់ដូចធ្វើការបានសក្តិសិទ្ធិល្អក្នុងការឈោងដល់អ្នកក្រីក្របំផុត និងអ្នកដែលត្រូវការកិច្ចការពារខាងសង្គមកិច្ចច្រើនជាងគេ ។ ប៉ុន្តែរឿងដែលអ្នកផ្ដល់ជំនួយ និង NGOs ជួយបំពេញតួនាទីច្រើនបែបយ៉ាងជំនួសរដ្ឋាភិបាល បានធ្វើឱ្យរដ្ឋាភិបាលបែងចែកថវិកាជាតិទៅប្រើប្រាស់ក្នុងផ្នែកផ្សេងទៀត ដែលមិនសុទ្ធតែមានផលិតភាពល្អនោះទេ ។

បច្ចុប្បន្ន កិច្ចការពារខាងសង្គមកិច្ចនៅកម្ពុជា ដើរតួយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ដែលជាគោលដៅចំបងគេនៅក្នុងរបៀបវារៈជាតិ និងសាកល ។ មានសល់ចន្លោះជាច្រើនសំរាប់ធ្វើអន្តរាគមន៍លើកិច្ចការពារខាងសង្គមកិច្ច ។ ប៉ុន្តែដើម្បីមានប្រសិទ្ធភាពល្អ ត្រូវធ្វើការស្រាវជ្រាវសំរាប់អនុវត្តជាក់ស្ដែងបន្ថែម សំដៅប្រៀបធៀបនូវប្រសិទ្ធភាពចំណាយនៃមធ្យោបាយ និងវិធីសាស្ត្រផ្សេងៗ សំរាប់អនុវត្តកម្មវិធីការពារខាងសង្គមកិច្ច។

## កំណត់សំគាល់

១. អត្ថបទនេះ រៀបចំសំរួលចេញពីរបាយការណ៍ដែលមានចំណងជើងថា "កម្ពុជា: ការវិភាគ និងការបូកសរុបពីចំណាយលើកិច្ចប្រឹងប្រែងការពារខាងសង្គមកិច្ច" ដែលបានបង្ហាញក្នុងសិក្ខាសាលាស្ដីពី "កិច្ចសន្ទនាពីបញ្ហាការពារខាងសង្គមកិច្ចនៅកម្ពុជា" ដែលធនាគារពិភពលោក បានរៀបចំធ្វើនៅភ្នំពេញ ។ របាយការណ៍នេះត្រូវបានចុះកិច្ចសន្យាឱ្យធ្វើឡើងដើម្បីជួយរួមចំណែកដល់ការរៀបចំ *ឯកសារយុទ្ធសាស្ត្រនៃកិច្ចការពារខាងសង្គមកិច្ចនៅកម្ពុជា* របស់ធនាគារពិភពលោកដែលនឹងចេញផ្សាយក្នុងពេលខាងមុខ ។ របកគំហើញ ការបកស្រាយ និងការសន្និដ្ឋានផ្សេងៗនៅក្នុងអត្ថបទនេះ គឺជារបស់ក្រុមអ្នកនិពន្ធ និងមិនអាចចាត់ទុកតាមបែបបទណាមួយថាជារបស់ធនាគារពិភពលោក អង្គការជាខ្សែរយៈនានា សមាជិកនៃក្រុមប្រឹក្សានាយក ឬប្រទេសនានាដែលពួកគេតំណាងឱ្យនោះទេ ។ ក្រុមអ្នកនិពន្ធសូមអរគុណដល់រដ្ឋាភិបាល, តំណាង NGOs ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អវិសេសនៅក្នុងពេលធ្វើការស្រាវជ្រាវ ។ ដោយឡែក Dena Ringold, Maryam Salim, Minna Hahn, បានផ្ដល់មតិដ៏ប្រសើរលើសំណៅដំបូងៗនៃរបាយការណ៍ ។ M.S. Shivakumar បានផ្ដល់ការគាំទ្រឥតងាករេនៅក្នុងដំណើរការទាំងមូល ។ កំហុស ឬការភ្លេចភ្លាំងដែលនៅសេសសល់ គឺជាការទទួលខុសត្រូវរបស់ក្រុមអ្នកនិពន្ធ ។

២. ក្នុងពេលថ្មីៗ ក្រសួងទាំងនេះត្រូវបានរៀបចំឡើងវិញជា ៣ក្រសួងគឺក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងក្រសួងកិច្ចការនារី

៣. ការផ្ដល់អំណោយនៅកម្ពុជា គឺជាចំណុចផ្ដោតនៃការសិក្សាជិតចេញផ្សាយរបស់លោកស្រី Caroline Hughes ដែលក្នុងនោះ គាត់ពិភាក្សារិះគន់ថា របៀបរបបនេះ បាននិវត្តន៍ពីរូបភាព "ប្រពៃណី"ជានិមិត្តរូបទៅជារូបភាពមួយដែលមានសមាសធាតុជាការគំរាមកំហែង និងបង្ខិតបង្ខំ ។

៤. តាមអង្កេតលើ ៨០០សហគ្រាសនៅកម្ពុជា, ៥,២% នៃចំណូលសរុបបានប្រើប្រាស់ជាប្រាក់បង់ក្រៅផ្លូវការ (សូមមើលឯកសារ World Bank, *Seizing the Global Opportunity: Investment Climate Assessment*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

ទោះបីកំណើនសេដ្ឋកិច្ចសហរដ្ឋអាមេរិក (US) និង ជប៉ុន ថយចុះក្តី ប៉ុន្តែសេដ្ឋកិច្ចប្រទេសអាស៊ីភាគច្រើន នៅតែលូតលាស់បានលឿនជាងកាលពី ត្រីមាសមុន ។ ប៉ុន្តែប្រេងនៅដែលឡើងថ្លៃយ៉ាងខ្លាំង និងកំរិតថ្លៃនៃផលិតផលផ្សេងទៀត នាំឱ្យមានការបារម្ភពីអតិផរណាក្នុងប្រទេសភាគច្រើន ។

### កំណើនសេដ្ឋកិច្ចពិភពលោក

យោងតាមអាំងឌីការទ័រសេដ្ឋកិច្ចដែលចងក្រងដោយការិយាល័យវិភាគសេដ្ឋកិច្ច, សេដ្ឋកិច្ច US បានថយកំណើនមកត្រឹម ៤,៧% នៅត្រីមាសទី២ ២០០៤ ធៀបនឹងកំណើន ៥,០% នៅត្រីមាសទី១ ។ តួលេខនេះឆ្លុះបញ្ចាំងជាសំខាន់ពីការធ្លាក់ចុះចំណាយប្រើប្រាស់ផ្ទាល់ខ្លួន និង ចំណាយប្រើប្រាស់របស់រដ្ឋាភិបាល ប៉ុន្តែមានការប៉ះប៉ូវវិញមួយចំណែក ដោយសារកំណើនការនាំចេញ និងវិនិយោគជាប់លាប់លើផ្ទះស្នាក់នៅ ។ នៅត្រីមាសទី២ ២០០៤ ចំណាយប្រើប្រាស់ផ្ទាល់ខ្លួន ថយកំណើនដល់ ៣,៤% គិតពីមួយឆ្នាំទៅមួយឆ្នាំ ធៀបនឹងកំរិត ៤,២%កាលពីត្រីមាសទី១ ។ ការថយចុះនេះបណ្តាលជាសំខាន់ពីការចុះខ្សោយ តំរូវការយានយន្ត និងការប្រើប្រាស់ថាមពល ដែលត្រូវបានប៉ះពាល់ជាបន្តដោយថ្លៃថាមពល (ប្រេងឥន្ធនៈ) ។

ក្នុងរយៈពេលដដែល កំណើនចំណាយប្រើប្រាស់របស់រដ្ឋាភិបាល បានថយចុះដល់ ៣,៨% ពីកំរិត ១២,១% កាលពីត្រីមាសមុន ។ ទោះបីសេដ្ឋកិច្ច US បានថយកំណើនក្នុងត្រីមាសទី២ក្តី ប៉ុន្តែធនាគារកណ្តាល US នៅមានសុទិដ្ឋិនិយមដែលបកស្រាយតាមការតំលើងអត្រាការប្រាក់គោលពី ១% ដល់ ១,២៥%នៅខែមិថុនា និង ១,៥%នៅខែសីហា ២០០៤ ។ បើសិនប្រេងនៅនៅតែឡើងថ្លៃថែមទៀត វាពិតជានឹងប៉ះពាល់ដល់លទ្ធភាពលូតលាស់ក្នុងត្រីមាសទី៣ និងទី៤ នៃឆ្នាំនេះ ។

ផសស នៅតំបន់អឺរ៉ូ លូតលាស់បានលឿនជាងដល់ ២,២%នៅត្រីមាសទី២ ២០០៤ ធៀបនឹង ១,៥%នៅត្រីមាសទី១, គឺវាត្រូវបានជំរុញយ៉ាងខ្លាំងដោយសារតំរូវការទាំងនៅក្នុងស្រុក និងនៅក្រៅប្រទេស ។ យោងតាមការប្រកាសពត៌មានមួយរបស់គណៈកម្មការអឺរ៉ុប (EC) តំរូវការក្នុងស្រុកកើន ១,៣%នៅត្រីមាសទី២ ២០០៤ ឬ ០,២% លឿនជាងកាលពីត្រីមាសទី១ ។ ក្នុងរយៈពេលដដែល ការនាំចេញកើន ៨,១% ធៀបនឹងកាលពីឆ្នាំមុន ឬ ៣,៥%បើធៀបនឹងត្រីមាសមុន ។ ដោយសារការលូតលាស់សេដ្ឋកិច្ចយឺតក្នុងប្រទេសមួយចំនួននៅតំបន់អឺរ៉ូ (គឺមាន អ៊ីតាលី ក្រិច អេស្ប៉ាញ) ធនាគារកណ្តាលអឺរ៉ុបបានសំរេចទុកនយោបាយរូបិយវត្ថុនៅដដែល ដោយរក្សាអត្រាផ្តល់ហិរញ្ញប្បទានបន្ត នៅកំរិតទាបបំផុតក្នុងរយៈ៦ទសវត្សរ៍ គឺ ២% ។

សេដ្ឋកិច្ចជប៉ុនបានរីកលូតលាស់ ៤,២%គិតពីមួយឆ្នាំទៅមួយឆ្នាំនៅត្រីមាសទី១ ២០០៤ ឬ ១,៤%ទាបជាងកាលពីត្រីមាសមុន ដោយសារជាសំខាន់ការថយចុះ ស្តុកទំនិញក្នុងវិស័យឯកជន និងចំណាយរបស់រដ្ឋាភិបាល។ យោងតាម Bloomberg News ស្តុកទំនិញឯកជនថយចុះដោយសារការថយចុះតំរូវការក្នុងសេដ្ឋកិច្ចរបស់ US និងចិន ដែលជាទីផ្សារសំខាន់បំផុតសំរាប់ជប៉ុន ។ កំណើនសេដ្ឋកិច្ចយឺតក្នុងប្រទេសទាំងពីរ គួបផ្សំនឹងការឡើងថ្លៃប្រេង គឺជាសញ្ញាមិនល្អទេសំរាប់សេដ្ឋកិច្ចជប៉ុន ។

ជាលទ្ធផលនៃការរឹតបន្តឹងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច សេដ្ឋកិច្ចចិនបានថយកំណើនបន្តិចមកត្រឹម ៩,៦%នៅត្រីមាសទី២ ២០០៤ ធៀបនឹង ៩,៧%នៅត្រីមាសទី១ ។ សំរាប់ឆ្នាំ២០០៤ទាំងមូល អត្រាកំណើនអាចថយចុះទៀត ដោយសារប្រេងឡើងថ្លៃ អតិផរណាកើនឡើង នឹងតំរូវការថយចុះ ។ យោងតាម Channel News Asia កំណើនអាចថយចុះមកត្រឹម ៩,០% ធៀបនឹងអត្រាទស្សទាយ ៩,៨% ។

ធៀបនឹងត្រីមាសទី២ ២០០៣ ដែលមានការរាលដាលជំងឺ SARS ក្នុងទូទាំងតំបន់ សេដ្ឋកិច្ចសិង្ហបុរីមានការរីកលូតលាស់ខ្លាំងដោយមានអត្រាកំណើនប្រចាំឆ្នាំ ១២,៥% នៅត្រីមាសទី២ ២០០៤ ធៀបនឹង ៧,៥% នៅត្រីមាសទី១ ។ ក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មសិង្ហបុរី បានរាយការណ៍ថា តំរូវការក្រៅប្រទេសបានកើនគួរឱ្យកត់សំគាល់ (ដល់ ២៦,៣%) ធៀបនឹងឆ្នាំមុន ហើយវានៅតែជាក្បាលម៉ាស៊ីនចំបងនៃកំណើនដដែល ។ ក្នុងរយៈពេលដូចគ្នា ការនាំចេញទំនិញ និងសេវាកម្ម បានកើនគួរកត់សំគាល់ដល់ទៅ ២៥,៧% ។ យោងតាមអង្កេតប្រចាំត្រីមាសចុងក្រោយរបស់អាជ្ញាធររូបិយវត្ថុសិង្ហបុរី, ផសស រំពឹងថានឹងកើនតាមអត្រាប្រចាំឆ្នាំ ៧,៧% នៅត្រីមាសទី៣ និង ៨,៤% សំរាប់ឆ្នាំ២០០៤ទាំងមូល ។ សេដ្ឋកិច្ចម៉ាឡេស៊ីកើនតាមអត្រាប្រចាំឆ្នាំ ៨,០% នៅត្រីមាសទី២ ២០០៤ ដែលជាកំណើនធំបំផុត គិតតាំងពីត្រីមាសទី២ ២០០០មក ដែលនៅពេលនោះសេដ្ឋកិច្ចលូតលាស់បាន ៨,១% ។ យោងតាមធនាគារកណ្តាលម៉ាឡេស៊ី វិស័យនាំមុខនៃការរីកលូតលាស់គឺ វិស័យកម្មន្តសាលកម្ម និងសេវាកម្ម ដែលមានអត្រាកំណើនប្រចាំឆ្នាំ ១២,១% និង ៧,៤% ។ ប៉ុន្តែគេរំពឹងថា វានឹងធ្លាក់ចុះវិញនៅចុងឆ្នាំ ដោយសារការឡើងថ្លៃប្រេង និងការថយចុះការនាំចេញអង្គធាតុពាក់កណ្តាលចម្លង (semiconductor) ។ ដូចគ្នាដែរ សេដ្ឋកិច្ចហុងកុង រីកលូតលាស់ ១២,១% នៅត្រីមាសទី២ ២០០៤ ធៀបនឹង ៦,៨% នៅត្រីមាសមុន ។ មូលហេតុចំបង គឺហាក់ដូចជាកំណើនការប្រើប្រាស់ក្នុងស្រុកដែលជួយជំរុញដោយការថយចំនួនអ្នកអត់ការងារធ្វើ និងកំណើនទេសចរណ៍ ។ សេដ្ឋកិច្ចហុងកុងក៏រំពឹងថានឹងចុះខ្សោយនៅឆមាសទី២ដែរ ដោយសារការថយកំណើនសេដ្ឋកិច្ចចិន និងការតំលើងអត្រាការប្រាក់នៅ US ។

ខុសពីប្រទេសអាស៊ានឯទៀតៗ សេដ្ឋកិច្ចថៃកើនឡើងតាមអត្រាប្រចាំឆ្នាំ ៦,៣%នៅត្រីមាសទី២ ២០០៤ ដោយថយចុះពីកំរិត ៦,៦%នៅត្រីមាសទី១ ។ ការធ្លាក់ចុះសេដ្ឋកិច្ចនេះបណ្តាលជាសំខាន់មកពី ជំងឺផ្តាសាយបក្សី និងការឡើងថ្លៃប្រេង យោងតាមពត៌មានពី ក្រុមប្រឹក្សាអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចជាតិ ។ ដោយមានការឆ្លងរាលដាលជំងឺ និងការរាំងស្ងួតគួបផ្សំគ្នា វិស័យកសិកម្មបានរួមចុះថែមទៀតនៅត្រីមាសទី១ ២០០៤ ។

### អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

ថ្លៃប្រេងនៅខ្ពស់ បានបង្កសំពាធអតិផរណាក្នុងប្រទេសជាច្រើន ។ នៅត្រីមាសទី២ ២០០៤ ថ្លៃទំនិញប្រើប្រាស់នៅ US ស្ទុះឡើង ២,៩%ខ្ពស់ជាងឆ្នាំមុន ឬ ១,២%ខ្ពស់ជាងត្រីមាសទី១ ។ នៅត្រីមាសទី២ នេះដែរ ថ្លៃទំនិញប្រើប្រាស់នៅតំបន់អឺរ៉ូ កើនតាមអត្រាប្រចាំឆ្នាំ ២,១% ធៀបនឹង ១,៦%នៅត្រីមាសមុន ។ ផ្ទុយទៅវិញ ថ្លៃទំនិញប្រើប្រាស់នៅជប៉ុនបន្តធ្លាក់ចុះថែមទៀតនៅត្រីមាសទី២ ២០០៤ ។ ដើម្បីដោះស្រាយបរិត្តផរណាមិនចេះចប់នេះ ធនាគារជាតិជប៉ុន បានសំរេចរក្សាគោលនយោបាយពង្រីកការផ្គត់ផ្គង់សាច់ប្រាក់ ក្នុងសម័យប្រជុំរបស់ខ្លួននៅខែកក្កដា ។ រីឯនៅហុងកុង សំពាធបរិត្តផរណាបន្ធូរស្រាល ដោយសារធ្លាក់ថ្លៃទំនិញប្រើប្រាស់បានថយល្បឿន ។ គិតពីមួយឆ្នាំទៅមួយឆ្នាំ ថ្លៃទំនិញប្រើប្រាស់នៅសង្ហបុរី កើន ១,៨%នៅត្រីមាសទី២ ២០០៤ ហើយវាឆ្លុះបញ្ចាំងមួយភាគធំនូវកំណើនថ្លៃ

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

សេវា និងទំនិញប្រើប្រាស់ ។

នៅត្រីមាសទី២ ២០០៤ ដុល្លារ US ឡើងថ្លៃ ២,៣% និង ៥% ខ្ពស់ជាងត្រីមាសមុន ទល់នឹងប្រាក់ យ៉េន និង អឺរ៉ូ ។ ថ្វីបើ ដុល្លារ US ស្ថិតក្រោមសំពាធ (គឺចុះថ្លៃទល់នឹងប្រាក់ យ៉េន និង អឺរ៉ូ) ដោយសារ គណនីចរន្តរបស់ US មានឱនភាពកំរិតខ្ពស់បំផុតក្ដី ប៉ុន្តែឥទ្ធិពលនៃសេចក្ដីប្រកាសតំលើងអត្រាការប្រាក់របស់ធនាគារកណ្ដាលUS និងកង្វះទំនុកចិត្តពីការរើបសេដ្ឋកិច្ចរហ័សនៅជប៉ុន បានជួយរក្សាឱ្យដុល្លារ US នៅរឹងប៉ឹងគួរសមក្នុងត្រីមាសនេះទាំងមូល ។ ក្នុងរយៈពេលដដែល ដុល្លារ US ឡើងថ្លៃ ៣% និង ០,៦% ទល់នឹង ប្រាក់បាតថៃ និងដុល្លារសិង្ហបុរី ។

### ថ្លៃផលិតផលក្នុងទីផ្សារពិភពលោក

នៅត្រីមាសទី២ ២០០៤ ថ្លៃផលិតផលភាគច្រើន មានកំរិតខ្ពស់ជាងកាលពីត្រីមាសទី១ ។ ថ្លៃអង្ករលេខ១ នៅទីផ្សារអន្តរជាតិក្រុងបាងកក កើនបានពីរត្រីមាសជាប់គ្នា ដល់ ២៣៩,៨ដុល្លារ/តោន ឬកើន ៨,៧% ធៀបនឹងត្រីមាសទី១ ។ ថ្លៃកៅស៊ូនៅទីផ្សារអន្តរជាតិម៉ាឡេស៊ី កើនឡើង ៧% ដល់ ១.៣៣៣,៤ដុល្លារ/តោននៅត្រីមាសទី២ ធៀបនឹង១.២៤៦,៤ដុល្លារ/តោន នៅត្រីមាសមុន ។ ក្នុងរយៈពេលដដែល ថ្លៃសណ្ដែកសៀងបន្តកើនឡើងបានពីរត្រីមាសជាប់គ្នា ដល់ ២៤៩,៧ដុល្លារ/តោន ឬកើនតែ ១,៦% ទេ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។ ថ្លៃប្រេងឆៅកើនយ៉ាងគំហុកដល់ ៣៣,៣០ដុល្លារ/ធុងជាមធ្យមនៅត្រីមាសទី២ ឬកើន ១៣,៦% ខ្ពស់ជាងត្រីមាសមុន ។

---

## តពីទំព័រ ៣ ជំរើសសំរាប់...

ផ្ទាល់នីមួយៗរបស់ឃុំ ការកសាងសមត្ថភាពនិងការគាំទ្រសំរាប់ការគ្រប់គ្រងប្រភពចំណូលថ្មីៗទាំងនេះនៅកំរិតឃុំ រចនាសម្ព័ន្ធនៃប្រភពចំណូលថ្មីៗ (ឧ. ភាគរយពន្ធប៉ាតង់ដែលត្រូវចែករំលែកឱ្យឃុំ, ប្រភេទផ្សារដែលត្រូវនៅក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ), និងបញ្ហាថា តើតំបន់ទីក្រុង និងជនបទគួរមានរចនាសម្ព័ន្ធចំណូលខុសគ្នាឬយ៉ាងណា ។

សរុបមក ក្នុងការបង្កើតចំណូលពីប្រភពផ្ទាល់របស់ឃុំ នឹងមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ នៅពេលប្រភពថ្មីៗនៃចំណូលឃុំត្រូវបានដាក់អនុវត្តសាកល្បង និងអនុម័តយក គឺមាន:

- តំរូវការប្រមូលពត៌មានបន្ថែមទៀត ដើម្បីកសាងសេចក្ដីណែនាំលំអិតសំរាប់អនុវត្តសាកល្បងនូវជំរើសចំណូលថ្មីៗ
- ការរៀបចំប្រភពថ្មីៗតាមបែបបទមួយដែលមិនបង្កើនបន្ទុកដល់អ្នកគ្មានលទ្ធភាពបង់
- ការកសាងសមត្ថភាពក្រុមប្រឹក្សាឃុំ ដើម្បីគ្រប់គ្រងប្រភពចំណូលថ្មីៗឱ្យបានសក្ដិសិទ្ធិ
- ការធានាឱ្យមានតំលាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រងមូលនិធិ
- ការអប់រំប្រជាជនក្នុងឃុំពីគោលដៅ និងការប្រើប្រាស់ប្រភពចំណូលថ្មីៗ
- ការកាត់បន្ថយការប្រមូលចំណូលក្រៅផ្លូវការដែលបានស្រូបយកធនធានដែលឃុំត្រូវការ ។

ការសិក្សានេះ បានជួយជំរុញឱ្យគំរោងសាកល្បងអាចធ្វើកើតមួយចំនួនអាចឈានទៅមុខ ថ្វីបើនៅមានចំណោទ និងបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយនៅក្នុងដំណើរការបង្កើតចំណូលប្រភពផ្ទាល់របស់ឃុំ ។ គេរកឃើញថា ត្រូវធ្វើការសិក្សាបន្តតាមក្រោយជាច្រើនទៀត ដើម្បីដោះស្រាយបញ្ហាផ្សេងៗដែលការសិក្សានេះមិនបានផ្ដល់ចំលើយគឺមាន: ១) ការវាយតំលៃពីការឆ្លើយតប និងគណនេយ្យភាពរបស់ឃុំ ក្រោយការដាក់អនុវត្តនីចំណូលប្រភពផ្ទាល់របស់ឃុំ, ២) អាំងឌីការទ័រសំរាប់វាស់វែងលទ្ធផល និងផលប៉ះពាល់ ចំពោះការកែលំអជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្រ, ៣) ការវាយតំលៃពីបន្ទុកពន្ធលើប្រជាជន និងអាជីវកម្មក្នុងមូលដ្ឋាន, ៤) ប្រសិទ្ធភាព និងភាពសក្ដិសិទ្ធិនៃការប្រមូលពន្ធ បើប្រៀបធៀបកំរិតខេត្តជាមួយឃុំ, ៥) ការរកមើល និងការវាយតំលៃនូវជំរើសចំណូលពីប្រភពផ្ទាល់របស់ឃុំផ្សេងទៀតដែលអាចអនុវត្តបាន និង ៦) ការវាយតំលៃពីការបែងចែក និងការលៃចែកចំណូលនានាពីប្រភពផ្ទាល់របស់ឃុំ ។

### កំណត់សំគាល់

១. ពន្ធលើអាជ្ញាប័ណ្ណធ្វើអាជីវកម្មប្រចាំឆ្នាំ ប្រមូលលើគ្រប់សហគ្រាសអាជីវកម្ម
២. កំរៃផ្សារប្រចាំថ្ងៃប្រមូលពីអ្នកលក់ដូរ
៣. ចំនួនតាមផែនការគឺជាចំនួនចំណូលពន្ធដែលសាខាពន្ធដារខេត្តនីមួយៗមានភារកិច្ចត្រូវប្រមូល ។ ចំនួននេះផ្អែកលើចំណូលក្នុងឆ្នាំមុនដែលត្រូវបានកែតំរូវទៅតាមការប្រែប្រួលក្នុងមូលដ្ឋានយកពន្ធ ។
៤. តាមច្បាប់ស្ដីពីសារពើពន្ធ (១៩៩៧) របបកំណត់ពន្ធគឺជាប្រព័ន្ធមួយ

---

## តពីទំព័រ ២០ ពត៌មាន...

នៅឆមាសទី២ ២០០៤ មជ្ឈមណ្ឌលដើម្បីសន្តិភាព និងអភិវឌ្ឍន៍ (CPD) បានផ្ដោតទៅលើសិក្ខាសាលាបំប៉នបន្ត រយៈ២ថ្ងៃ និងការបោះពុម្ពផ្សាយសន្ទានុក្រម "ការកសាងសន្តិភាព" ។ ជាកិច្ចបន្តលើការបណ្ដុះបណ្ដាលពីការកសាងសន្តិភាពរបស់ CPD នៅក្នុងតំបន់ផ្សះផ្សារ, CPD នឹងមានធ្វើការវាយតំលៃតាមក្រោយមួយនៅស្រុកវាលវែង ខេត្តពោធិសាត់នៅដើមខែធ្នូ ។ CPD បានដំណើរការវគ្គបណ្ដុះបណ្ដាលស្នូលស្ដីពី "ការកសាងសន្តិភាព" ដែលមាន ៤ភាគ ចាប់ពីខែមិថុនា ដល់វិច្ឆិកា ២០០៤ ដោយមានសិក្ខាកាមចូលរួម ២៧នាក់ មកពី NGOs ក្នុងស្រុកនិងអន្តរជាតិ ក្រសួងមហាផ្ទៃ សាលាក្រុងភ្នំពេញ ខាងយោធា និងប៉ូលីស ។

### បណ្ណាល័យ

នៅឆ្នាំ២០០៤ បណ្ណាល័យ វបសអ បានពង្រីកប្រជុំឯកសារទាក់ទងនឹងប្រទេសកម្ពុជា លើបញ្ហាពាក់ព័ន្ធនឹង ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច និងបានធ្វើការពន្យល់ណែនាំពីបណ្ណាល័យ ដល់និស្សិត/អ្នកស្រាវជ្រាវជាតិ និងអន្តរជាតិ ៤ក្រុម ។ បណ្ណាល័យ នឹងបោះពុម្ពផ្សាយ កាតាឡុកសៀវភៅ

## តារាង១. កំនើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើសពីឆ្នាំ២០០០-២០០៤ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2000 | 2001 | 2002 | 2003 | | | | 2004 | | 2003 |
|---|---|---|---|---|---|---|---|---|---|---|
| | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 7.3 | 6.7 | - | - | - | - | - | - | - | 5.0 |
| ឥណ្ឌូនេស៊ី | 4.4 | 3.8 | 3.8 | 3.4 | 3.8 | 3.9 | 4.3 | 4.5 | 4.3 | 4.1 |
| ម៉ាឡេស៊ី | 8.7 | 0.5 | 5.4 | 4.0 | 4.4 | 3.5 | 6.4 | 7.6 | 8.0 | 5.3 |
| សិង្ហបុរី | 9.5 | -2.3 | 3.0 | 1.6 | -4.2 | 1.7 | 3.7 | 7.5 | 12.5 | 1.1 |
| ថៃ | 4.4 | 1.9 | 6.0 | 6.7 | 5.8 | 6.6 | 7.8 | 6.5 | 6.3 | 6.7 |
| វៀតណាម | | 6.0 | - | - | 6.9 | - | - | - | - | 7.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 8.0 | 7.5 | 8.1 | 9.9 | 6.7 | 9.1 | 9.9 | 9.7 | 9.6 | 9.1 |
| ហុងកុង | 10.2 | 0.5 | 4.8 | 4.4 | -0.6 | 4.0 | 4.9 | 6.8 | 12.1 | 3.2 |
| កូរ៉េខាងត្បូង | 9.1 | 3.0 | 6.8 | 3.7 | 1.9 | 2.3 | 3.9 | 5.3 | 5.5 | 3.1 |
| តៃវ៉ាន់ | 5.8 | -2.2 | 4.2 | 3.2 | -0.4 | 4.2 | 5.4 | 6.3 | 7.7 | 3.2 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១២ | 3.5 | 1.4 | 1.3 | 0.8 | 0.2 | 0.3 | 0.6 | 1.5 | 2.2 | 0.6 |
| ជប៉ុន | 2.8 | 0.4 | 1.7 | 2.7 | 2.1 | 1.9 | 3.1 | 5.6 | 4.4 | 2.5 |
| សហរដ្ឋអាមេរិក | 5.0 | 1.2 | 2.8 | 2.1 | 2.4 | 3.6 | 4.3 | 5.0 | 4.7 | 3.1 |

## តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៤ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | 2003 | | | | 2004 | | 2003 |
|---|---|---|---|---|---|---|---|---|---|---|
| | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | -0.3 | -0.4 | 3.0 | 1.8 | 1.6 | 0.7 | 0.5 | 0.8 | 2.2 | 1.5 |
| ឥណ្ឌូនេស៊ី | 3.7 | 11.3 | 10.3 | 7.7 | 6.5 | 5.6 | 3.7 | 4.8 | 6.7 | 5.8 |
| ម៉ាឡេស៊ី | 1.5 | 1.4 | 1.9 | 1.3 | 0.9 | 1.0 | 1.1 | 0.9 | 1.2 | 1.0 |
| សិង្ហបុរី | 1.4 | 1.0 | 0.1 | 0.7 | 0.1 | 0.5 | 0.7 | 1.4 | 1.8 | 0.5 |
| ថៃ | 1.6 | 1.8 | 1.4 | 2.0 | 1.7 | 1.8 | 1.5 | 1.9 | 2.7 | 1.8 |
| វៀតណាម | -1.7 | 0.0 | 3.7 | 2.2 | 2.3 | 3.5 | 2.2 | - | - | 3.1 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 0.3 | 1.0 | -0.6 | 0.5 | 0.6 | 0.8 | 2.7 | 2.8 | - | 1.2 |
| ហុងកុង | -3.7 | -1.5 | -2.9 | -2.0 | -.25 | -3.7 | -2.5 | -1.2 | -0.7 | -2.5 |
| កូរ៉េខាងត្បូង | 2.3 | 4.3 | 3.2 | 4.1 | 3.3 | 3.1 | 3.5 | 3.2 | 3.3 | 3.5 |
| តៃវ៉ាន់ | 1.3 | -0.01 | -0.5 | 0.3 | -0.1 | - | - | - | - | -0.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១២ | 2.3 | 2.6 | 2.3 | 2.4 | 2.0 | 2.0 | 1.9 | 1.6 | 2.1 | 2.1 |
| ជប៉ុន | -0.6 | -0.5 | -0.5 | -0.3 | - 0.2 | -0.3 | 0 | -0.1 | -0.3 | -0.2 |
| សហរដ្ឋអាមេរិក | 3.4 | 2.9 | 2.2 | 2.9 | 2.1 | 2.2 | 1.9 | 1.7 | 2.8 | 2.3 |

## តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៤ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | 2003 | | | | 2004 | | 2003 |
|---|---|---|---|---|---|---|---|---|---|---|
| | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3,871 | 3,935 | 3,948 | 3,948 | 4,008 | 4,015 | 3,999 | 3,991 | 4,016 | 3,992 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 8,421 | 10,261 | 9,054 | 8,905 | 8,479 | 8,441 | 8,482 | 8,469 | 9,001 | 8,577 |
| ម៉ាឡេស៊ី (រីងហ្គិត) | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.72 | 1.79 | 1.77 | 1.74 | 1.75 | 1.75 | 1.72 | 1.69 | 1.7 | 1.74 |
| ថៃ (បាត) | 40.1 | 44.4 | 43.4 | 42.7 | 42.2 | 41.3 | 39.7 | 39.1 | 40.3 | 41.5 |
| វៀតណាម (ដុង) | 14,168 | 14,725 | 15,376 | 15,426 | 15,472 | 15,522 | 15,618 | 16,208.6 | 15,733 | 15,510 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ន់) | 8.28 | 8.28 | 8.28 | 8.27 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 |
| ហុងកុង (ដុល្លារហុងកុង) | 7.80 | 7.80 | 7.80 | 7.80 | 7.80 | 7.79 | 7.75 | 7.77 | 7.80 | 7.78 |
| កូរ៉េខាងត្បូង (វ៉ុន) | 1,131 | 1,291 | 1,219 | 1,202 | 1,207 | 1,174 | 1,182 | 1,171 | 1,163 | 1,192 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 31.8 | 34.1 | 34.8 | 34.7 | 35.0 | 34.2 | 34.0 | 33.4 | 33.3 | 34.5 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១២ (អឺរ៉ូ) | 1.08 | 1.12 | 1.00 | 0.93 | 0.88 | 0.88 | 0.84 | 0.79 | 0.83 | 0.88 |
| ជប៉ុន (យ៉េន) | 108 | 122 | 123.0 | 118.8 | 118.4 | 117.6 | 108.9 | 107.2 | 109.7 | 115.9 |

## តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ ២០០០-២០០៤ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | 2003 | | | | 2004 | | 2003 |
|---|---|---|---|---|---|---|---|---|---|---|
| | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | |
| ឈើមូលប្រភេទរឹង - ម៉ាឡេស៊ី ($/ម៣) | 190.1 | 160.1 | 181.2 | 186.3 | 182.1 | 183.0 | 197 | 197.7 | 195 | 187.1 |
| ឈើអារប្រភេទរឹង - ម៉ាឡេស៊ី ($/ម៣) | 599.2 | 488.3 | 565.4 | 550.4 | 552.4 | 552.0 | 545.5 | 547.8 | 576.9 | 550.2 |
| កៅស៊ូ - ម៉ាឡេស៊ី ($/តោន) | 720.8 | 602.0 | 834.1 | 945.5 | 975.8 | 1,017.4 | 1,261.4 | 1,246.4 | 1,333.4 | 1,050 |
| អង្ករ - បាងកក ($/តោន) | 203.7 | 172.6 | 189.6 | 198.3 | 197.5 | 199.6 | 196 | 215.3 | 235.8 | 197.8 |
| សណ្ដែកសៀង - សហរដ្ឋអាមេរិក ($/តោន) | 211.3 | 195.6 | 239.0 | 243.3 | 245.7 | 244.3 | 219.7 | 238.5 | 249.7 | 238.3 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 26.1 | 22.8 | 26.2 | 29.3 | 24.5 | 26.5 | 27 | 29.3 | 33.3 | 26.8 |
| មាស – London ($/troy ounce) | 279.0 | 279.0 | 317.8 | 352.1 | 346.7 | 363.3 | 391.9 | 408.5 | 393.1 | 363.5 |

*ប្រភព: តារាង ១: The Economist, Far Eastern Economic Review, ការិយាល័យស្ថិតិជាតិ និងធនាគារកណ្ដាលនានា . តារាង ២.IMF, The Economist, តារាង ៣ : IMF , The Economist, NBC. តារាង ៤: IMF, Far Eastern Economic Review.*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

ជាទូទៅក្នុងចន្លោះពីត្រីមាសទី១ ទៅ ទី២ ២០០៤ សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ បានថយចុះ ។ តំលៃនៃសកម្មភាពសាងសង់បានថយចុះ រីឯខាងទេសចរណ៍បានរក្សាភាពនឹងន ។ ម្យ៉ាងទៀត ឱនភាពពាណិជ្ជកម្មជាទូទៅបានកើនឡើង ក្នុងរយៈពេលនេះ ។ ការថយល្បឿនលូតលាស់ក្នុងសកម្មភាពទាំងនេះ បានកាត់បន្ថយឥទ្ធិពលនៃកំណើននៅក្នុងវិនិយោគឯកជន ។

ចំនួនភ្ញៀវចូលសរុប (ភ្ញៀវអន្តរជាតិ និងភ្ញៀវក្នុងស្រុក) សឹងតែគ្មានប្រែប្រួលនៅត្រីមាសទី២ ។ ដោយឡែក ភ្ញៀវបរទេសថយចុះ ២៤% ដល់ ១៩៣.៨០២នាក់ ប៉ុន្តែទេសចរក្នុងស្រុកកើនយ៉ាងខ្លាំង បាន ៦៩,៤% ដល់ ១៤៩.៩៨៤នាក់ ។ យោងតាមក្រសួងទេសចរណ៍, ទេសចរក្នុងស្រុកជាបណ្តើរៗកាន់តែមានចំណែកធំឡើងក្នុងវិស័យទេសចរណ៍នៅកម្ពុជា ហើយនិន្នាការនេះបានពិនិត្យឃើញច្បាស់តាំងពីដើមឆ្នាំ២០០៤ មក ។ នៅត្រីមាសទី២ ២០០៤ ទេសចរក្នុងស្រុកមានចំណែក ៤៤% ក្នុងនេះអ្នកធ្វើដំណើរតាមផ្លូវគោក និងផ្លូវទឹកកើន ៧២% ដល់ ១៤៦.៨៥៣នាក់ រីឯអ្នកធ្វើដំណើរតាមផ្លូវអាកាសនៅថេរត្រឹមប្រហែល ៣.១៣០នាក់ ។

តាមធម្មតា ភ្ញៀវអន្តរជាតិចូលមកកម្ពុជា តែងថយចុះនៅត្រីមាសទី២ ហើយនៅត្រីមាសទី២ ២០០៤ បានថយចុះដល់ ១៩៣.៨០២នាក់ ធៀបនឹង ២៥៤.៤៣៧នាក់នៅត្រីមាសមុន ប៉ុន្តែបានកើន ៨៩% បើធៀបនឹងត្រីមាសទី២ ២០០៣ ។

ខាងវិស័យសាងសង់ក៏ធ្លាក់ចុះដែរនៅត្រីមាសទី២ បើធៀបនឹងត្រីមាសទី១ ។ យោងតាមមន្ទីរសុរិយោដី និងភូមិសាស្ត្រក្រុងភ្នំពេញ តំលៃសរុបនៃសំណង់បានអនុម័តសំរាប់ក្រុងភ្នំពេញ បានធ្លាក់ចុះ ៣៣,៤% ដល់ ៤៨,៥ លានដុល្លារ ក្នុងចន្លោះពេលពីត្រីមាសទី១ ដល់ត្រីមាសទី២ ទោះបីចំនួនគំរោងអនុម័តបានកើនពី ២២៩ ដល់ ២៣៧ ក្តី ។ ក្នុងនេះផ្ទះល្វែងគិតជាតំលៃថយចុះ ៤១% ហើយ "សំណង់ផ្សេងទៀត" ថយចុះ ៣៤% ប៉ុន្តែ សំណង់ភូមិគ្រឹះកើន ១៥% ។ តំលៃសរុបនៃសំណង់បានអនុម័ត បានធ្លាក់ចុះ ៤៣,២% បើធៀបនឹង ត្រីមាសទី២ ឆ្នាំមុន ដែលមានដល់ ៨៥,៥លានដុល្លារ ។

ឱនភាពពាណិជ្ជកម្មកម្ពុជាកើនដល់ ១១២,២លានដុល្លារនៅត្រីមាសទី២ ២០០៤ ធៀបនឹង ៥៩,៣លានដុល្លារនៅត្រីមាសទី១ ។ ការនាំចេញ កើន ២៣,៨% ដល់ ៤៩៤,៧លានដុល្លារ ។ ការនាំចេញក្នុងមុខសំលៀកបំពាក់តែឯងបានកើន ២៥% ដល់ ៤៧៩,៤លានដុល្លារ ។ ការនាំចេញកសិផលថយចុះ ៤,៤% ដល់ ១៥,៣លានដុល្លារ ។ ធៀបនឹងកាលពីមួយឆ្នាំមុន ការនាំចេញសរុបកើន ២១% ពីកំរិត ៤០៨,៥លានដុល្លារ ។

ការនាំចូលសរុបឡើងដល់ ៦០៦,៩លានដុល្លារ ក្នុងនេះការនាំចូលរបស់វិស័យឯកជនមាន ២៣១,៨លានដុល្លារ និងរបស់វិស័យសាធារណៈ ៣៧៥ លានដុល្លារ ។ ធៀបនឹងត្រីមាសទី១ ការនាំចូលសរុបកើន ៣២,៣% ពីកំរិត ៤៥៨,៩លានដុល្លារ ។ ក្នុងចំណោមមុខទំនិញនាំចូលចំបងៗ ដែកកើនខ្លាំងជាងគេដល់ ៩៨,៤%, បន្ទាប់មក គឺបារីដែលកើន ៤៥,៥% និងប្រេងសាំង ២១% ។ បើប្រៀបធៀបនឹងត្រីមាសទី២ឆ្នាំមុន ការនាំចូលសរុប បានកើន ១៩,៦% ។

ធៀបនឹងត្រីមាសទី២ ២០០៣ គំរោងវិនិយោគឯកជនដែលត្រូវបានអនុម័តសរុប បានកើនជាងពីរដង ដោយកើនយ៉ាងខ្លាំងក្នុង ៣វិស័យចំបងៗ គឺ ទេសចរណ៍ ឧស្សាហកម្ម និងកសិកម្ម ។ ចំពោះចំនួនការងារ វិស័យឧស្សាហកម្មគ្រោងជួលនិយោជិតចូល ១១.៥១០នាក់ (៩.៩៣៨នាក់សំរាប់ខាងកាត់ដេរ) នៅត្រីមាសទី២ ។ ប៉ុន្តែឥទ្ធិពលបង្កើតការងារនៅក្នុងវិស័យសេវាកម្ម និងកសិកម្ម រំពឹងថាមានកំរិតតូចគឺ ១.៣៩៧នាក់ និង ២២៥នាក់ រៀងៗគ្នា ។

នៅត្រីមាសទី២ ២០០៤ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអនុម័ត ១៩ គំរោងវិនិយោគឯកជនដែលមានតំលៃ ១១៣,៣លានដុល្លារ ឬ ៧៩%ច្រើនជាងនៅត្រីមាសទី១ ។ កំណើននេះជាប់ទាក់ទង នឹងកំណើនគំរោងវិនិយោគបានអនុម័តក្នុងវិស័យសេវាកម្ម និងវត្តមានគំរោងវិនិយោគបានទទួលការអនុម័តក្នុងកសិកម្ម ។ ការអនុមតិគំរោងវិនិយោគសំរាប់វិស័យសេវាកម្មកើនពី ៩,៥លានដុល្លារ ដល់ ៧៦លានដុល្លារ នៅក្នុងនេះមាន ៥២% (៣៩,២លានដុល្លារ) នៅខាងទេសចរណ៍ ។ នៅពេលជាមួយគ្នា វិនិយោគខាងកសិកម្មកើនពី សូន្យ ដល់ ៩,៤លានដុល្លារ រីឯខាងឧស្សាហកម្មមានការធ្លាក់ចុះ ៤៨% ដល់ ២៨លានដុល្លារ ។ ក្នុងអនុវិស័យកាត់ដេរ នៅត្រីមាសទី២ មានការធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរអស់ ៨០% ដល់កំរិតដ៏ក្សត់ខ្សោយត្រឹម ១០,១លានដុល្លារ ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី២ ឱនភាពថវិកាឡើងដល់ ១៨០,២ពាន់លានរៀល គឺខ្ពស់ជាងត្រីមាសទី១ ដែលមានឱនភាពត្រឹមតែ ១២៣,២ពាន់លានរៀល យោងតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ក្នុងនេះចំណូលថវិកាសរុបបានធ្លាក់ចុះ ៦,៧% ដល់ ៤៨៨,៦ពាន់លានរៀល រីឯចំណាយថវិកាសរុបកើន ៣,៦% ដល់ ៦៦៨,៧ពាន់លានរៀល ។

នៅត្រីមាសទី២ ការប្រមូលពន្ធដែលជាប្រភពចំណូលធំបំផុតមានកំរិត ១៥% ទាបជាងនៅត្រីមាសមុន ។ ដូចគ្នាដែរ ចំណូលពន្ធគយ និងអាករពិសេស បានធ្លាក់ចុះ ទោះបីតំលៃសរុបនៃការនាំចេញ និងនាំចូល កើនឡើងក្នុងពេលនោះក្តី ។ ធៀបនឹងត្រីមាសទី២ ឆ្នាំមុន ចំណូលសរុបកើន ២៩% (ពីកំរិត ៣៧៩ពាន់លានរៀល) ដែលនាំមុខដោយកំណើនក្នុងចំណូលមិនមែនពន្ធ ដូចជា កំរៃទិដ្ឋាការ និងចំណូលទេសចរណ៍ជាដើម ។ នៅឆមាសទី១ ២០០៤ ចំណូលប៉ាន់ស្មានសរុបគឺ ១.០១២,៥ពាន់លានរៀល ឬ ៤៨% នៃផែនការក្នុងច្បាប់ថវិកាឆ្នាំ២០០៤ ។

នៅត្រីមាសទី២ ចំណាយថវិកាសរុប រួមទាំងកំណែតំរូវចំណាយផង កើនដល់ ៦៦៨,៧ពាន់លានរៀល ពីកំរិត ៦៤៥,៣ពាន់លានរៀល នៅត្រីមាសទី១ ។ ក្នុងនេះ ចំណាយចរន្តកើន ៦,២% ហើយចំណាយជាមូលធនកើនបន្តិចបន្តួចត្រឹម ០,៥% ។ ចំណាយចរន្តមានសមាសធាតុចំបងៗ៣គឺការពារជាតិ និងសន្តិសុខ, រដ្ឋបាលស៊ីវិល និងការប្រាក់លើកំចី ។ ដូច្នេះ កំណើនចំណាយចរន្ត មានជាប់ទាក់ទងនឹង កំណើនក្នុងចំណាយលើរដ្ឋបាលស៊ីវិល (កើន ៦%) និងការបង់ការប្រាក់ (កើន ៩៩%) ។

## អតិផរណា និង អត្រាការប្រាក់

គិតពីមួយត្រីមាសទៅមួយត្រីមាស ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញកើន ១,៥%នៅត្រីមាសទី២ ធៀបនឹង ០,៤៦%នៅត្រីមាសទី១ យោងតាមវិទ្យាស្ថានជាតិស្ថិតិ ។ កំណើនថ្លៃទំនិញប្រើប្រាស់នៅត្រីមាសទី២ ឆ្លុះបញ្ចាំងពីកំណើនក្នុងថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍(៣,៦%) និងម្ហូបអាហារ (៣%)

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

ប៉ុន្តែថ្លៃសំលៀកបំពាក់ និងស្បែកជើងថយចុះ ១,៤% ។ នៅត្រីមាសទី២ ២០០៤ នេះ ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញកើន ២,២% បើធៀបនឹងត្រីមាសទី២ ២០០៣ ។

ក្រោយឡើងថ្លៃបាន ០,២%ទល់នឹងដុល្លារ US នៅត្រីមាសទី១ ប្រាក់រៀលបានចុះថ្លៃ ០,៦%នៅត្រីមាសទី២ ។ ប៉ុន្តែប្រាក់រៀលបានឡើងថ្លៃបន្តិចទល់នឹងប្រាក់បាតថៃ ដោយប្តូរបាន ១០០,៥រៀល/បាតនៅត្រីមាសទី២ ធៀបនឹង ១០១,៩រៀល/បាតនៅត្រីមាសមុន ។ ក្នុងពេលនេះដែរ អត្រាប្តូរប្រាក់រៀល-ដុងវៀតណាម មានកំរិតប្រហែល ២៤,៧រៀល/១០០ដុង គឺវានៅថេរក្នុងរយៈ៤ត្រីមាសជាប់គ្នា ។

## ការវិវត្តន៍រូបិយវត្ថុ

នៅចុងត្រីមាសទី២ រូបិយវត្ថុទូទៅ (M2) របស់កម្ពុជា កើនដល់ ៣.៨៤៤ ពាន់លានរៀល ឬ ៥% ខ្ពស់ជាងត្រីមាសទី១ យោងតាមធនាគារជាតិនៃកម្ពុជា ហើយកត្តាចំបងគឺកំណើន ៤,៧%ក្នុងប្រាក់បញ្ញើជារូបិយវត្ថុបរទេស និងកំណើនការផ្គត់ផ្គង់ប្រាក់រៀលប្រហែល ៤% ។

ប្រាក់បញ្ញើជារូបិយវត្ថុបរទេស ដែលមានប្រហែល៧០% នៅក្នុងរូបិយវត្ថុ ទូទៅបានស្ទុះដល់ ៦៧២,៤លានដុល្លារនៅត្រីមាសទី២ ធៀបនឹង ៦៤២,៥ លានដុល្លារនៅត្រីមាសទី១ (កើន ៤,៧%) ។ សមាសភាគជារៀលកើនដល់ ១.១៣៨ពាន់លានរៀលនៅត្រីមាសទី២ (កើន ៣,៩% ពីកំរិត ១.០៩៥ពាន់លានរៀលនៅត្រីមាសមុន) ក្នុងនេះ ១២% ជាប្រាក់រៀលផ្ញើនៅធនាគារ និង ៨៨% ជាប្រាក់រៀលធ្វើចរាចរនៅខាងក្រៅប្រព័ន្ធធនាគារ ។

## ស្ថានភាពក្រីក្រ និងប្រាក់ចំណូលរបស់ពលករងាយរងគ្រោះ

អង្កេតលើពលករងាយរងគ្រោះធ្វើនៅថ្ងៃ ២-២០សីហា ២០០៤ បានបង្ហាញពីការថយចុះក្នុងប្រាក់ចំណូលរបស់ អ្នកធាក់ស៊ីក្លូ អ្នកស៊ីឈ្នួលធ្វើស្រែ កម្មកររោងចក្រកាត់ដេរ អ្នករត់ម៉ូតូឌុប និង កម្មករសំណង់គ្មានជំនាញ បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។ អ្នករត់ម៉ូតូឌុប និង កម្មករសំណង់គ្មានជំនាញ ថយចំណូលខ្លាំងជាងគេ បន្ទាប់មកគឺ អ្នកធាក់ស៊ីក្លូ ។

នៅខែសីហា ២០០៤ ចំណូលប្រចាំថ្ងៃជាតួលេខចារិករបស់កម្មកររោងចក្រកាត់ដេរ ធ្លាក់ចុះបន្តិចអស់ ១,៣% ដល់ ១១.១៦៣រៀល ធៀបនឹង ១១.៣០០រៀលនៅខែសីហា ២០០៣ ។ ២/៣ នៃកម្មករកាត់ដេរដែលឆ្លើយសំភាសន៍ បានអះអាងថា សកម្មភាពរោងចក្របានថយចុះ ហើយ ១/៣ ទៀតបានលើកឡើងផ្ទុយពីនេះ ។ ប៉ុន្តែចំណូលប្រចាំថ្ងៃនេះមានកំណើន ៤,៣% បើធៀបនឹងអង្កេតលើកមុននៅខែឧសភា ២០០៤ ។

កម្មករកាត់ដេរប្រហែល ៤៨% ជានារីនៅលីវ អាយុពី ២០-២៥ឆ្នាំ ។ អ្នកឆ្លើយសំភាសន៍ភាគច្រើន (៦៥%) មានទីលំនៅជាប់លាប់នៅខេត្តកំពង់ចាម កណ្តាល ព្រៃវែង និងស្វាយរៀង ។ កម្មករជាងពាក់កណ្តាលរាយការណ៍ថា បានរៀនដល់មធ្យមសិក្សា ឬខ្ពស់ជាង ។ ពួកគេចំណាយជាមធ្យម ២.១២៤រៀល/ថ្ងៃ (២០%នៃចំណូលប្រចាំថ្ងៃ) លើម្ហូបអាហារ ។

សាំងឡើងថ្លៃខ្ពស់ បានប៉ះពាល់យ៉ាងច្បាស់ដល់ប្រាក់ចំណូលរបស់អ្នករត់ម៉ូតូឌុប ។ ចំណូលប្រចាំថ្ងៃរបស់ពួកគេធ្លាក់ចុះដល់ ៩.៧០០រៀលនៅខែសីហា ២០០៤ ឬចុះ ១១% ធៀបនឹងកាលពីមួយឆ្នាំមុន ។ម្យ៉ាងទៀតកំណើនចំនួនអ្នករត់ម៉ូតូឌុប ក៏បានកាត់បន្ថយចំណូលនេះមួយកំរិត ដោយសារមានការប្រកួតប្រជែងគ្នាកាន់តែខ្លាំង ។ អ្នករត់ម៉ូតូឌុបប្រហែល ៦០% ជាអ្នកមកពីខេត្ត ហើយ ៤២% ស្នាក់នៅតាមផ្ទះជួល ។ អ្នករត់ម៉ូតូឌុបសឹងគ្រប់គ្នារាយការណ៍ថា ត្រូវពឹងផ្អែកជាសំខាន់លើចំណូលប្រចាំថ្ងៃរបស់ខ្លួនគាត់ដើម្បីទ្រទ្រង់ជីវភាពក្រុមគ្រួសារ និងមានជាងពាក់កណ្តាលប្រាប់ថា បានរៀនចប់មធ្យមសិក្សា ។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់គ្មានជំនាញ និងអ្នកធាក់ស៊ីក្លូថយចុះអស់ ១១,៨% និង ១០,៣% រៀងៗគ្នាបើធៀបនឹងខែសីហា ២០០៣ ហើយវាធ្លាក់ចុះបន្តិច បើធៀបនឹងអង្កេតលើកមុននៅខែឧសភា ២០០៤ ។ កម្មករសំណង់គ្មានជំនាញភាគច្រើនអះអាងថា ក្នុងរយៈពេលសព្វថ្ងៃពួកគាត់មានចំនួនច្រើនជាងកាលពី រយៈពេលបានរាយការណ៍ពីលើកមុន ។ ដូចគ្នាដែរ អ្នកធាក់ស៊ីក្លូភាគច្រើនអះអាងថា ចំនួនពួកគាត់កើនឡើងក្នុងប៉ុន្មានខែថ្មីៗ ។ កម្មករសំណង់គ្មានជំនាញ និងអ្នកធាក់ស៊ីក្លូ ភាគច្រើនជាអ្នកមកពីខេត្តព្រៃវែង និងស្វាយរៀង ។ ថ្វីបើ កម្មករសំណង់គ្មានជំនាញ និង អ្នកធាក់ស៊ីក្លូ ជាង ៨០% រាយការណ៍ថា មានដីច្រើនជាងមួយហិកតាក្តី ប៉ុន្តែពួកគាត់ត្រូវចាកចេញពីកសិដ្ឋានដោយសារការរាំងស្ងួត ។ អ្នកធាក់ស៊ីក្លូរាយការណ៍ថា គាត់ចំណាយអស់ប្រហែល ៣.៥៤៥រៀល/ថ្ងៃលើម្ហូបអាហារ ចំណែកឯកម្មករសំណង់គ្មានជំនាញចំណាយអស់ ៣.០៥៧រៀល ។ ប្រហែល ២/៣ នៃកម្មករសំណង់គ្មានជំនាញ និងអ្នកធាក់ស៊ីក្លូ រាយការណ៍ថា បានរៀនចប់បឋមសិក្សា ។ ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកស៊ីឈ្នួលធ្វើស្រែ បានធ្លាក់ចុះតិចជាងគេបំផុតក្នុងចំណោមក្រុមពលករទាំងនេះ គឺថយចុះតែ ៤,៨% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់មានជំនាញ កើនឡើងជាបណ្តើរៗតាំងពីដើមឆ្នាំមក ឬ កើន ១៧,៥%បើធៀបនឹងកាលពីមួយឆ្នាំមុន ឬកើន ២០% បើធៀបនឹងអង្កេតលើកមុននៅខែឧសភា ២០០៤ ។ រឿងនេះកើតមានឡើងជាសំខាន់ដោយសារកំណើនក្នុងសកម្មភាពសាងសង់ ។ ជាការគួរឱ្យភ្ញាក់ផ្អើល មានអ្នកឆ្លើយសំភាសន៍ក្នុងគំរូតាងតែ ៣០% ប៉ុណ្ណោះដែលប្រាប់ថា ប្រាក់ចំណូលប្រចាំថ្ងៃរបស់ខ្លួនបានកើនឡើង ហើយមាន ៥២% អះអាងថា គ្មានការប្រែប្រួលទេ ។ ជាងពាក់កណ្តាលនៃកម្មករសំណង់មានជំនាញ បានរៀនចប់មធ្យមសិក្សា ។

ចំពោះក្រុមពលករឯទៀតៗ ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកលីសែងកើនបន្តិចបាន ១%នៅខែសីហា ២០០៤ ធៀបនឹងខែដូចគ្នាឆ្នាំ២០០៣ ។ ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកបំរើតាមភោជនីយដ្ឋាន អ្នកលក់បន្លែតូចតាច និងអ្នករើសអេតចាយ មានកំណើន ១២%, ៧,២%, និង ៧% រៀងៗគ្នា ។ ភាគច្រើននៃអ្នកបំរើតាមភោជនីយដ្ឋាន (៧៥%) រាយការណ៍ថាបានរៀនចប់មធ្យមសិក្សា ហើយប្រហែល ៥០%នៃ អ្នករើសអេតចាយ និងអ្នកលក់បន្លែតូចតាច រាយការណ៍ថាបានរៀនចប់បឋមសិក្សា ។ កំណើនក្នុងចំណូលប្រចាំថ្ងៃរបស់អ្នករើសអេតចាយ អាចឆ្លុះបញ្ចាំងនូវជំនួយការងារអំពីកូនចៅរបស់ពួកគាត់ ដោយសារអង្កេតបានធ្វើចំពេលវិសមកាល ។ គួរកត់សំគាល់ថាកុមារម្នាក់ៗអាចរកបានពី ១.០០០-២.០០០រៀល/ថ្ងៃ គឺ ច្រើនជាងកាលពីប្រាំឆ្នាំមុន ដល់ទៅពីរដង ។

*ដោយលោកស្រី ប៊ុន ដូរីណា*

# តាមដានសេដ្ឋកិច្ច ~ សន្ទស្សន៍សេដ្ឋកិច្ច

## តារាង១. គំរោងវិនិយោគឯកជនដែលបានអនុម័ត ឆ្នាំ១៩៩៦-២០០៤

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 Q2 | Q3 | Q4 | 2004 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ចំនួនគំរោងវិនិយោគ* | | | | | |
| សរុប | 300 | 136 | 140 | 96 | 96 | 188 | 37 | 14 | 17 | 15 | 15 | 19 |
| កាត់ដេរ | 144 | 48 | 84 | 44 | 52 | 76 | 15 | 7 | 12 | 6 | 11 | 9 |
| | | | | | | | មូលធនបានចុះបញ្ជី (លានដុល្លារ) | | | | | |
| សរុប | 391.2 | 278 | 416.4 | 246.8 | 102.4 | 129.2 | 48.9 | 10.4 | 4.0 | 15.4 | 11.9 | 10.0 |
| កាត់ដេរ | 156.8 | 34.4 | 91.6 | 55.6 | 25.6 | 60 | 12.6 | 4.1 | 1.0 | 5.8 | 8.4 | 1.0 |
| | | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | |
| សរុប | 746.8 | 761.6 | 849.2 | 474 | 266.4 | 217.2 | 239.6 | 48.3 | 95.1 | 62.1 | 63.3 | 113.3 |
| កាត់ដេរ | 158.4 | 38.8 | 120.8 | 79.6 | 76.8 | 100 | 18.0 | 10.5 | 43.3 | 14.5 | 49.9 | 10.1 |

*ប្រភព: ក្រុមប្រឹក្សាវិនិយោគកម្ពុជា (១៩៩៥-២០០៣) ។ * ក្នុងនេះមានទាំងគំរោងពង្រីកគំរោងវិនិយោគដែលមានស្រាប់ ។*

## តារាង២. គំរោងសំណង់នៅភ្នំពេញដែលបានអនុម័ត ឆ្នាំ១៩៩៦-២០០៤

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 Q2 | Q3 | Q4 | 2004 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ភូមិគ្រឹះ | 205 | 179 | 143 | 136 | 111 | 108 | 159 | 39 | 25 | 48 | 52 | 47 |
| ផ្ទះល្វែង | 537 | 528 | 678 | 864 | 520 | 499 | 535 | 104 | 148 | 116 | 157 | 161 |
| ផ្សេងៗ | 116 | 117 | 132 | 74 | 64 | 57 | 75 | 23 | 17 | 22 | 20 | 29 |
| សរុប | 858 | 824 | 953 | 1074 | 695 | 664 | 769 | 166 | 190 | 186 | 229 | 237 |

*ប្រភព: នាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ក្រុងភ្នំពេញ ។*

## តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ១៩៩៦-២០០៤

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 Q2 | Q3 | Q4 | 2004 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | លានដុល្លារ | | | | | |
| ការនាំចេញសរុប | 387.1 | 493.4 | 784.4 | 941.1 | 1055.5 | 1267.0 | 1453.7 | 408.5 | 492.3 | 475.7 | 399.5 | 494.7 |
| រួមមាន: - សំលៀកបំពាក់ | 78.8 | 227.2 | 378 | 554 | 962.1 | 1201.0 | 1356.2 | 389.9 | 475.2 | 448.5 | 383.6 | 479.4 |
| • ទៅសហរដ្ឋអាមេរិក | 0.4 | 107.2 | 74.1 | 486 | 714.1 | 840.9 | 943.8 | 267.8 | 303.2 | 298.2 | 255.8 | 306.3 |
| • ប្រទេសផ្សេងទៀត | 78.4 | 120 | 82 | 68 | 248.0 | 360.1 | 412.4 | 122.1 | 172.0 | 150.3 | 127.8 | 173.1 |
| - កសិកម្ម | - | - | - | - | 90.5 | 66.0 | 97.5 | 18.7 | 17.0 | 27.2 | 16.0 | 15.3 |
| • កៅស៊ូ | - | - | - | - | 29.6 | 25.9 | 29.7 | 6.7 | 10.0 | 12.1 | 8.0 | 6.6 |
| • ឈើ | - | - | - | - | 32.5 | 22.3 | 16.0 | 2.8 | 2.1 | 2.4 | 1.8 | 2.8 |
| • ជលផល | - | - | - | - | 5.4 | 6.0 | 4.3 | 0.7 | 0.6 | 0.7 | 0.8 | 1.2 |
| • ផ្សេងៗ | - | - | - | - | 26.0 | 11.8 | 47.5 | 8.5 | 4.3 | 12.0 | 5.4 | 4.8 |
| ការនាំចូលសរុប | 1114.4 | 1094.5 | 1112.2 | 1237.4 | 1417.7 | 1501.4 | 1707.8 | 507.3 | 436.2 | 487.6 | 458.8 | 606.9 |
| រួមមាន: - សាំង | - | - | - | - | - | - | 25.9 | 8.0 | 5.8 | 9.0 | 7.1 | 8.6 |
| - ម៉ាស៊ូត | - | - | - | - | - | - | 100.8 | 34 | 25.7 | 24.5 | 30.4 | 27.7 |
| - សំភារ:សំណង់ | - | - | - | - | - | - | 12.9 | 4.8 | 3.9 | 4.4 | 4.0 | 6.3 |
| - ផ្សេងៗ | - | - | - | - | - | - | 1568.2 | 460.6 | 400.9 | 449.6 | 417.4 | 564.3 |
| ជញ្ជីងពាណិជ្ជកម្ម | -727.3 | -601.2 | -327.8 | -296.3 | -362.2 | -234.0 | -254.1 | -98.8 | 56.1 | -11.9 | -59.3 | -112.2 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 198 | 188 | 66 | 47 | 74 | 24.8 | 12.9 | 34.7 | 10.1 | 16.4 | 21.9 | 22.9 |
| ការនាំចេញសរុប | 2.1 | 27.5 | 58.9 | 12.4 | 19.7 | 20 | 14.7 | 30.0 | 9.0 | 15.2 | 20.5 | 21.1 |
| ការនាំចូលសរុប | 1.2 | -1.8 | 1.6 | 11.3 | 14.5 | 5.9 | 13.7 | 7.8 | -10.0 | 19.6 | 16.5 | 19.6 |

*ប្រភព: ក្រសួងពាណិជ្ជកម្ម នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, ទីចាត់ការគយ និងរដ្ឋាករ, រួមទាំង ការលើកលែងពន្ធ ។*

## តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ១៩៩៦-២០០៤

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 Q2 | Q3 | Q4 | 2004 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | អ្នកដំណើរពាន់នាក់ | | | | | |
| ទិដ្ឋាការទេសចរ | 194.4 | 163.0 | 141.9 | 199.6 | 209.6 | 335.4 | 447.4 | 83.8 | 132.0 | 209.1 | 230.7 | 165.3 |
| តាមយន្តហោះ | 194.4 | 163.0 | 141.9 | 199.6 | 209.6 | 335.4 | 447.4 | 44.4 | 76.2 | 131.3 | 139.6 | 99.6 |
| តាមផ្លូវគោក និងទឹក | - | - | - | - | - | - | - | 39.4 | 55.8 | 77.7 | 91.1 | 65.8 |
| ទិដ្ឋាការជំនួញ | 58.4 | 48.6 | 37.6 | 55.4 | 46.9 | 62.4 | 58.3 | 14.7 | 20.3 | 15.5 | 15.8 | 20.8 |
| តាមយន្តហោះ | 58.4 | 48.6 | 37.6 | 55.4 | 46.9 | 62.4 | 58.3 | 11.2 | 16.3 | 15.5 | 11.5 | 16.9 |
| តាមផ្លូវគោក និងទឹក | - | - | - | - | - | - | - | 3.5 | 4.0 | - | 4.3 | 3.9 |
| ទិដ្ឋាការរដ្ឋការ | 7.6 | 7.2 | 6.8 | 7.9 | 95.2 | 10.6 | 17.3 | 4.6 | 5.9 | 6.1 | 7.9 | 7.6 |
| តាមយន្តហោះ | 7.6 | 7.2 | 6.8 | 7.9 | 95.2 | 10.6 | 17.3 | 4.0 | 5.1 | 6.1 | 6.8 | 6.3 |
| តាមផ្លូវគោក និងទឹក | - | - | - | - | - | - | - | 0.6 | 0.8 | - | 1.1 | 1.3 |
| សរុបតាមអាកាស | | | 186.3 | 262.9 | 351.7 | 408.4 | 523.0 | 59.6 | 97.6 | 152.9 | 157.9 | 122.8 |
| សរុបតាមផ្លូវគោក និងទឹក | - | - | 100..2 | 104.8 | 114.7 | 196.5 | 263.5 | 43.5 | 60.6 | 77.7 | 96.5 | 71.0 |
| សរុបអ្នកដំណើរ | 260.4 | 218.8 | 286.5 | 367.7 | 466.4 | 604.9 | 786.5 | 103.1 | 158.2 | 230.6 | 254.4 | 193.8 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុបអ្នកដំណើរ | 18.5 | -15.9 | 30.9 | 28.3 | 26.8 | 29.7 | 30 | -37.4 | -8.9 | -14.2 | 21.8 | 87.9 |

*ប្រភព: ក្រសួងទេសចរណ៍ ។*

## តារាង៥. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) អត្រាប្ដូរប្រាក់ និងថ្លៃមាស ឆ្នាំ១៩៩៦-២០០៤ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | | | 2004 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q2 | Q3 | Q4 | Q1 | Q2 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ខេត្ត | - | 6.1 | 16.3 | 6.2 | 5.4 | 0.9 | 0.3 | 5.9 | -1.9 | 1.8 | 4.6 | 11.5 |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 7.1 | 8.0 | 14.8 | 4.0 | -0.8 | -0.6 | 3.3 | 1.6 | 0.8 | 0.5 | 0.8 | 2.2 |
| - ម្ហូបអាហារ | 7.6 | 6.7 | 14.1 | 7.6 | -3.3 | -2.8 | 1.8 | 2.3 | 1.5 | -0.04 | 0.6 | 3.4 |
| - ថាមពល | 20.7 | 20.0 | 15.1 | 3.5 | 6.6 | -1.1 | 0.3 | 5.2 | 5.1 | 5.1 | 4.8 | 8.1 |
| | អត្រាប្ដូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 2,666 | 3,029 | 3824 | 3832 | 3,879 | 3,935 | 3,926 | 4008 | 4015 | 3999 | 3991 | 4016.5 |
| រៀលក្នុង ១ បាតថៃ | 105 | 98 | 88 | 101 | 96.3 | 88 | 91.3 | 94.9 | 96.9 | 100.5 | 101.9 | 100.5 |
| រៀលក្នុង ១០០ ដុងវៀតណាម | 24.0 | 25.6 | 28.6 | 27.8 | 27.4 | 26.6 | 25.7 | 25.9 | 24.9 | 24.8 | 24.6 | 24.7 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 46.3 | 40.4 | 36.0 | 34.0 | 33.3 | 32.7 | 36.8 | 40.0 | 41.5 | 44.4 | 46.0 | 46.0 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 779 | 883 | 1,065 | 1,105 | 1,329 | 1,521 | 1508 | 1683 | 1683 | 1700 | 1867 | 1983 |
| ថ្លៃសាំង (រៀល/លីត្រ) | 1,118 | 1,378 | 1,613 | 1,760 | 2,113 | 2,084 | 2150 | 2383 | 2367 | 2400 | 2567 | 2767 |

## តារាង៦. ស្ថានភាពរូបិយវត្ថុ ឆ្នាំ១៩៩៦-២០០៤ (តួលេខនៅចុងការិយបរិច្ឆេទ)*

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | | | 2004 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q2 | Q3 | Q4 | Q1 | Q2 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 881 | 1,177 | 1,726 | 2,019 | 2,589 | 3,080 | 3737 | 3,594 | 3624 | 4027 | 4265 | 4337 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 31 | -114 | -496 | -576 | -759 | -876 | -849 | -641 | -617 | -698 | -606 | -493 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | 128 | 54 | 178 | 103 | 3 | -75 | -119 | -19 | 18 | -128 | -133 | -130 |
| ឥណទានចំពោះផ្នែកឯកជន | 435 | 637 | 655 | 763 | 898 | 936 | 1059 | 1,224 | 1287 | 1337 | 1389 | 1499 |
| រូបិយវត្ថុទូទៅ M2 | 912 | 1,063 | 1,230 | 1,443 | 1,831 | 2204 | 2888 | 2,953 | 3007 | 3328 | 3659 | 3844 |
| រូបិយវត្ថុ M1 | 329 | 385 | 543 | 531 | 540 | 609 | 813 | 871 | 886 | 937 | 1007 | 1040 |
| រូបិយវត្ថុផ្សេងៗ | 583 | 678 | 687 | 911 | 1,291 | 1,594 | 2075 | 2,082 | 2121 | 2391 | 2652 | 2804 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 40.3 | 16.6 | 15.7 | 17.3 | 26.9 | 20.4 | 31.0 | 11.5 | 9.3 | 15.2 | 21.8 | 30.2 |
| រូបិយវត្ថុ M1 | 18.3 | 17 | 41 | -2.2 | 1.7 | 12.8 | 33.5 | 16.4 | 14.9 | 15.3 | 21.5 | 17.4 |
| រូបិយវត្ថុផ្សេងៗ | 57.1 | 16.3 | 1.3 | 32.6 | 41.7 | 23.5 | 30.2 | 9.5 | 7.1 | 15.2 | 21.9 | 36.7 |

## តារាង៧. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ១៩៩៦-២០០៤ (ពាន់លានរៀល)*

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | | | | 2004 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q2 | Q3 | Q4 | Q1 | Q2 |
| ចំណូលសរុប | 748 | 880 | 920 | 1326 | 1528 | 1529 | 1744 | 379 | 401 | 557 | 523.9 | 488.6 |
| ចំណូលចរន្ត | - | - | - | - | - | 1521 | 1728 | 377 | 399 | 557 | 523.3 | 475.6 |
| ចំណូលពន្ធ | 536 | 596 | 676 | 956 | 1096 | 1096 | 1227 | 287 | 273 | 387 | 409.3 | 348.4 |
| ពន្ធគយ | 344 | 348 | 376 | 432 | 376 | 376 | 424 | 94 | 92 | 117 | 137 | 108.4 |
| ចំណូលមិនមែនពន្ធ | 176 | 272 | 204 | 348 | 424 | 424 | 501 | 90 | 126 | 170 | 113.9 | 127.1 |
| អាជីវកម្មព្រៃឈើ | 28 | 36 | 20 | 36 | 28 | 29 | 15 | 1 | 4 | 1 | 0.9 | 0.3 |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 64 | 84 | 88 | 108 | 124 | 122 | 123 | 18 | 33 | 50 | 16.1 | 23.1 |
| ចំណូលជាមូលធន | 40 | 12 | 36 | 12 | 8 | 9 | 16 | 2 | 1 | 0 | 0.6 | 13.0 |
| ចំណាយសរុប | 1440 | 1260 | 1296 | 1792 | 2332 | 2332 | 2948 | 688 | 683 | 746 | 647.1 | 668.7 |
| ចំណាយជាមូលធន | 628 | 452 | 368 | 624 | 976 | 977 | 1388 | 299 | 301 | 306 | 295.6 | 295.4 |
| ចំណាយចរន្ត | 812 | 808 | 980 | 1164 | 1356 | 1355 | 1560 | 388 | 382 | 440 | 351.5 | 373.3 |
| អប់រំ និងសុខាភិបាល | 124 | 128 | 132 | 280 | 344 | 343 | 454 | 88 | 122 | 227 | 31.4 | 80.6 |
| ការពារជាតិ និងសន្តិសុខ | 408 | 420 | 448 | 464 | 404 | 405 | 438 | 119 | 75 | 147 | 67.6 | 66.0 |
| ក្រសួងផ្សេងៗទៀត | 284 | 260 | 332 | 412 | 636 | 637 | 668 | 182 | 184 | 65 | 252.6 | 226.7 |
| ឱនភាពជាទូទៅ | -692 | -380 | -380 | -476 | -804 | -803 | -1204 | -309 | -282 | -189 | -123.2 | -180.2 |
| ហិរញ្ញប្បទានក្រៅប្រទេស | 680 | 444 | 268 | 416 | 768 | 766 | 1249 | 228 | 251 | 295 | -223 | 195.4 |
| ហិរញ្ញប្បទានក្នុងស្រុក | 12 | -64 | 112 | 60 | 36 | 37 | -45 | 81 | 31 | -106 | 99.8 | -15.2 |

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមរបស់ពលករងាយរងគ្រោះ ឆ្នាំ១៩៩៧-២០០៤

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1997 | 2002 | 2003 | | | 2004 | | | | 2004 | | |
| | មុនកក្កដា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ ០៤ | ឧសភា ០៤ | សីហា | កុម្ភៈ | ឧសភា | សីហា |
| អ្នកធាក់ស៊ីក្លូ | 12,250 | 8,878 | 9,200 | 7,000 | 9,380 | 9,817 | 9,500 | 8,425 | 8420 | 3.26 | 20.36 | -10.25 |
| អ្នកលីសែង | 9,675 | 6,312 | 7,600 | 6,225 | 7,240 | 6,500 | 8,700 | 7,847 | 7310 | 14.47 | 26.06 | 0.91 |
| អ្នកលក់បន្លែតូចតាច | 7,050 | 7,158 | 7,250 | 6,162 | 6,860 | 6,700 | 7,400 | 7,625 | 7337 | 2.07 | 23.74 | 6.95 |
| អ្នករើសអេតចាយ | 4,155 | 4,012 | 3,875 | 3,605 | 4,900 | 3,900 | 4,800 | 4,600 | 5262 | 23.87 | 27.60 | 7.17 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | – | 4,000 | 4,600 | 4,380 | 4,520 | 4,435 | 4,900 | 4,500 | 5065 | 6.52 | 2.74 | 12.01 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | – | 4,219 | 4,180 | 3,712 | 4,600 | 4,450 | 4,700 | 4,300 | 4380 | 12.44 | 15.84 | -4.78 |
| កម្មកររោងចក្រកាត់ដេរ | – | 10,000 | 10,127 | 9,123 | 10,300 | 10000 | 9,675 | 9,740 | 10163 | -4.46 | 6.76 | -1.33 |
| អ្នករត់ម៉ូតូឌុប | – | 12,075 | 11,400 | 9372 | 10900 | 10000 | 11,200 | 9,000 | 9700 | -1.75 | -3.97 | -11.01 |
| កម្មករសំណង់គ្មានជំនាញ | – | 5,850 | 6,162 | 7100 | 7600 | 6200 | 7,200 | 6,900 | 6725 | 16.85 | -3.16 | -11.73 |
| កម្មករសំណង់មានជំនាញ | – | 13,350 | 12,500 | 12,050 | 12,700 | 16,900 | 13,800 | 12,450 | 14925 | 10.40 | 3.32 | 17.52 |

*សំគាល់: ចំនួនអ្នកបំរើតាមភោជនីយដ្ឋាន អ្នកស៊ីឈ្នួលធ្វើស្រែ កម្មករកាត់ដេរ អ្នកម៉ូតូឌុប និងកម្មករសំណង់មាននិងគ្មានជំនាញ ចាប់ធ្វើអង្កេតពីខែកុម្ភៈ២០០០ ។ *ចំនួលអ្នកបំរើតាមហាងមិនរាប់បញ្ចូលអាហារ និងការស្នាក់នៅដែលម្ចាស់ភោជនីយដ្ឋានផ្ដល់ឱ្យទេ។ ប្រភព: តារាង៥: វិបសអ, IMF, NIS ក្រសួងផែនការ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ / តារាង៦: ធនាគារជាតិនៃកម្ពុជាQ4* 2003 បានកែតំរូវ / តារាង៧: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, * 2002, Q2, Q3, Q4, 2003 បានកែតំរូវ, និង Q2 2004 ជាតួលេខបណ្ដោះអាសន្ន / តារាង៨: វិបសអ ។*

# ពត៌មានថ្មីៗ ពី វបសអ

## ផ្នែកគ្រប់គ្រង

នៅខែកញ្ញា ២០០៤, គណៈប្រតិភូរបស់វបសអ សំរាប់ការរៃអង្គាសមូលនិធិ និងកសាងភាពជាដៃគូ បានទៅធ្វើទស្សនកិច្ចនៅអឺរ៉ុបក្រោមការឧបត្ថម្ភរបស់ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (SIDA) ។ គណៈប្រតិភូបានធ្វើទស្សនកិច្ចតាមស្ថាប័នជាង២០កន្លែង នៅប្រទេសហុលឡង់ អាឡឺម៉ង់ ដាណឺម៉ាក ណ័រវ៉េ ស៊ុយអែត និងចក្រភពអង់គ្លេស ។ សព្វថ្ងៃ វបសអ កំពុងបន្តពិនិត្យភាពជាដៃគូជាសក្តានុពលល្អៗ សំរាប់កិច្ចសហការក្នុងការស្រាវជ្រាវ ការផ្តល់ជំនួយបច្ចេកទេសដល់កម្មវិធីស្រាវជ្រាវគន្លឹះៗ និងឱកាសសំរាប់ការអប់រំ និងអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈដល់បុគ្គលិក វបសអ ។

នាយកប្រតិបត្តិនៃ វបសអ បានចូលរួមក្នុងកិច្ចប្រជុំដំបូងរបស់អនុគណៈកម្មាធិការសំរាប់ពាណិជ្ជកម្ម និងវិនិយោគអន្តរជាតិ នៃ គណៈកម្មការសង្គម និងសេដ្ឋកិច្ចអាស៊ីប៉ាស៊ីហ្វិក (ESCAP) នៅទីក្រុងបាងកកក្នុងខែតុលា ២០០៤ ។ កិច្ចប្រជុំដែលមានលើកឡើងពីការចាប់ផ្តើមអនុវត្តនូវបណ្តាញស្រាវជ្រាវនិងបណ្តុះបណ្តាលនៅអាស៊ីប៉ាស៊ីហ្វិក (ARTNET) និងត្រូវបានរៀបចំឡើងដោយលេខាធិការដ្ឋានរបស់ UNESCAP និងឧបត្ថម្ភដោយមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) ។ វបសអ នឹងក្លាយជាស្ថាប័នស្រាវជ្រាវកម្ពុជាដែលមានឋានៈជាសមាជិកសំខាន់របស់ ARTNET ។ បណ្តាញនេះនឹងជំរុញការស្រាវជ្រាវដោយរួមសហការគ្នា លើបញ្ហាពាណិជ្ជកម្ម និង WTO នៅតំបន់អាស៊ីប៉ាស៊ីហ្វិក ព្រមទាំងជួយទ្រទ្រង់ដល់ការអភិវឌ្ឍន៍ សមត្ថភាពពាក់ព័ន្ធនឹងពាណិជ្ជកម្មរបស់ស្ថាប័នស្រាវជ្រាវនៅបណ្តាប្រទេស អភិវឌ្ឍន៍តិចបំផុត (CDCs) ដូចប្រទេសកម្ពុជា ជាដើម ។

នៅខែវិច្ឆិកា ២០០៤, វបសអ នឹងចាប់ផ្តើមសាងសង់អគារថ្មីមួយកំពស់ពីរជាន់ដែលមានតំរូវការជាខ្លាំង សំរាប់ធ្វើជាការិយាល័យខាងស្រាវជ្រាវ និងបន្ទប់ប្រជុំ នៅក្នុងទីតាំងរបស់អង្គការនៅទួលគោក ។ អគារនេះនឹងសាងសង់រួចរាល់ បានទាន់ពេលបុណ្យចូលឆ្នាំខ្មែរនៅដើមខែមេសា ២០០៥ ។

## ផ្នែកស្រាវជ្រាវ

នៅឆមាសទី២ ឆ្នាំ២០០៤ ផ្នែកស្រាវជ្រាវនៃ វបសអ បានរីកចំរើនយ៉ាងលឿន ដោយមានការជ្រើសរើសអ្នកស្រាវជ្រាវថ្មី ៧នាក់ ចូលជាបុគ្គលិកបន្ថែម ។ ពួកគេមកពីប្រភពផ្សេងៗ ដូចជា សេដ្ឋកិច្ច យេនឌ័រនិងការអភិវឌ្ឍន៍ រដ្ឋបាលសាធារណៈ និងការសិក្សាពីសន្តិភាព ។ ការវិវត្តន៍នេះឆ្លុះបញ្ចាំងពីកម្មវិធីស្រាវជ្រាវកាន់តែធំ ដែលមានគំនិតផ្តួចផ្តើមថ្មីៗអំពីភាពក្រីក្រ អភិបាលកិច្ចនិងវិមជ្ឈការ ការផ្តល់កម្មសិទ្ធិដី ការផ្តល់សេវាការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍន៍សមត្ថភាពសំរាប់រដ្ឋបាលសាធារណៈ ។ ការសិក្សាមួយចំនួនត្រូវបានបញ្ចប់ និងទទួលបានការយល់ព្រមឱ្យបោះពុម្ព រីក៏កំពុងត្រូវបានត្រួតពិនិត្យឡើងវិញ ។ ការងារទាំងនេះរួមមាន របាយការណ៍ស្តីពីព្រៃឈើមានតំលៃខ្ពស់ លទ្ធផលសេដ្ឋកិច្ចឆ្នាំ២០០៣ ការផ្តល់កម្មសិទ្ធិដី វិមជ្ឈការសារពើពន្ធ តួនាទីរបស់សហគ្រាសខ្នាតតូចនិងមធ្យម និងសេដ្ឋកិច្ចឆ្លងកាត់ព្រំដែន ។ ក្នុងបេសកកម្មទៅអឺរ៉ុប គណៈប្រតិភូរៃអង្គាសមូលនិធិ និងកសាងភាពជាដៃគូរបស់ វបសអ បានទៅធ្វើទស្សនកិច្ចនៅសាកលវិទ្យាល័យ/ស្ថាប័នស្រាវជ្រាវនៅអឺរ៉ុប និងអង់គ្លេស មានជាអាទិ៍ សាកលវិទ្យាល័យ Uppsala (Stockhom), ISS (Hague), IDS (Sussex) និង ODI (London) ដើម្បីស្រាវជ្រាវពីលទ្ធភាពធ្វើសហការរវាងស្ថាប័ន ។

## មជ្ឈមណ្ឌលដើម្បីសន្តិភាព និងអភិវឌ្ឍន៍

*តទៅទំព័រទី ១៤*

ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា ក៏មានផ្សាយជាភាសាអង់គ្លេសដែរ ។

***Cambodia Development Review*** **is also available in English.**

**ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា**

*ឯកសារបោះពុម្ពផ្សាយរបស់ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី៨ លេខ៤ ខែតុលា-ធ្នូ ឆ្នាំ២០០៤

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
អាសយដ្ឋានប្រៃសណីយ: ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@camnet.com.kh / pubs@cdri.forum.org.kh
website: http://www.cdri.org.kh

***ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា***
បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង/មួយឆ្នាំជាភាសាខ្មែរ និងអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

***ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា*** ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ ***អត្ថបទតាមដានសេដ្ឋកិច្ច*** ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

***ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា*** ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិតត្រូវចុះហត្ថលេខា ប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹង ត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

គ្រឹះស្ថានផ្សាយ: វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
គ្រប់គ្រងកែសំរួល: អែម សូវ៉ានី
កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា / អ្នកបកប្រែ: យូ សិទ្ធីរិទ្ធ
រោងពុម្ពជប៉ុន ភ្នំពេញ រូបភាពទំព័រមុខ: អាន សុវត្ថា

**រក្សាសិទ្ធិ ២០០៤** វិទ្យាស្ថានបណ្តុះបណ្តាលនិង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

**ISSN 1560-7615**

ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។
ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។